ក្រសួងអប់រំ យុវជន និងកីឡា

សម្រាប់លក់

# សិក្សាសង្គម









៥

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

ក្រសួងអប់រំ យុវជន និងកីឡា

# សិក្សាសង្គម

## ថ្នាក់ទី ៥


បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៤៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

**គណៈកម្មការនិពន្ធ** លោកស្រី វ៉ាន់ សុភី លោក ងិន សុតារា
លោក គង់ ហាក់ លោក យិន សុធា

**អ្នកវាយអត្ថបទ** លោក ខែម ម៉ារី

**វិចិត្រករ** លោក ឡុង សុវណ្ណា

**អ្នករៀបរៀង** លោក សុក វុទ្ធី

**អ្នករចនាទំព័រ** លោក ខែម ម៉ារី

**គណៈកម្មការពិនិត្យ** លោកស្រី ប្រាក់ សូលីដា លោកស្រី អ៊ឹង គីមសាន

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ៦៦១ អយក.ប្រក. ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពឆ្នាំ ២០១៦

ISBN 9-789-995-001-322

# អារម្ភកថា

សួស្តីប្អូនៗសិស្សានុសិស្សទាំងអស់ជាទីស្នេហា!

សៀវភៅ " សិក្សាសង្គមថ្នាក់ទី5 " នេះជាកម្រងខ្លឹមសារសំខាន់ៗដែលមានទំនាក់ទំនងទៅនឹងជីវភាពរស់នៅក្នុងសង្គមជាក់ស្តែង ។ ខ្លឹមសារទាំងអស់នឹងជួយអភិវឌ្ឍចំណេះដឹង បំណិន ឥរិយាបថ និងតម្រូវការចាំបាច់ដើម្បីឱ្យការរស់នៅរបស់ប្អូនៗទទួលបានជោគជ័យ និងថ្លៃថ្នូរ ។

សៀវភៅនេះមានរូបភាពនិងខ្លឹមសារដែលបង្ហាញពីតម្លៃសីលធម៌ វប្បធម៌ ប្រពៃណីជាតិ ប្រវត្តិសាស្ត្រ ភូមិសាស្ត្រដើម្បីឱ្យប្អូនៗងាយសិក្សានិងងាយអនុវត្ត ព្រោះប្អូនអាចធ្វើលំហាត់ ធ្វើការសន្ទនា ស្រាវជ្រាវព័ត៌មានប្លែកៗ និងពណ៌នាពីខ្លឹមសារមេរៀនដោយខ្លួនឯងបាន ។

គណៈកម្មការនិពន្ធសង្ឃឹមថាសៀវភៅ " សិក្សាសង្គមថ្នាក់ទី5 " នេះជាសៀវភៅអប់រំទំនើប ដែលអាចធ្វើឱ្យសតិបញ្ញារបស់ប្អូនៗរីកចម្រើនតាមសម័យកាលនៃសតវត្សថ្មីពិតប្រាកដ ។

សូមឱ្យការសិក្សារបស់ប្អូនទទួលបានជោគជ័យនិងអភិវឌ្ឍន៍ដូចសេចក្តីប្រាថ្នា ។

គណៈកម្មការនិពន្ធ

# បញ្ជីអត្ថបទ

ទំព័រ


**ជំពូកទី 1 : ឥរិយាបថល្អ....................................1**

មេរៀនទី1 : ការកំណត់គោលដៅ....................................2

មេរៀនទី 2 : គោលដៅនៅក្នុងការសិក្សា....................................10

មេរៀនទី 3 : ឥរិយាបថនិងតម្លៃ....................................16

មេរៀនទី 4 : សិទ្ធិនិងការទទួលខុសត្រូវ....................................26

មេរៀនទី 5 : ការបង្កើតថ្មីនិងគំនិតច្នៃប្រឌិត....................................34

**ជំពូកទី 2 : ឥរិយាបថប្រកបដោយសុវត្ថិភាព....................................39**

មេរៀនទី1 : ការចៀសវាងទង្វើដែលនាំឱ្យមានគ្រោះថ្នាក់....................................40

មេរៀនទី 2 : ការរក្សាសុវត្ថិភាពនៅពេលដើរនិងពេលជិះកង់ ....................................48

**ជំពូកទី 3 : ជីវភាពសង្គមបច្ចុប្បន្ន....................................53**

មេរៀនទី1 : ការថែរក្សាចម្រៀងនិងរបាំខ្មែរ....................................54

មេរៀនទី 2 : ពិធីបុណ្យប្រពៃណីជាតិ....................................60

មេរៀនទី 3 : ការងារប្រចាំថ្ងៃ....................................68

មេរៀនទី 4 : អំណាចនីតិបញ្ញត្តិ....................................76

មេរៀនទី 5 : ការប្រើប្រាស់ដីនៅតាមទីតាំងនានា....................................82

**ជំពូកទី 4 : ជីវភាពសង្គមពីអតីតកាល....................................89**

មេរៀនទី1 : គំនូរក្បាច់បុរាណខ្មែរ....................................90

មេរៀនទី 2 : ការថែរក្សាឧបករណ៍ភ្លេងប្រពៃណី....................................96

មេរៀនទី 3 : សំណង់អគារបុរាណ....................................102

មេរៀនទី 4 : សម័យចេនឡា....................................108

មេរៀនទី 5 : សម័យអង្គរ....................................116

ជំពូកទី

# 1 ឥរិយាបថល្អ



កុមារគ្រប់ៗរូបត្រូវអនុវត្តនិងរៀបចំឥរិយាបថឱ្យបានល្អប្រពៃរៀងរាល់ថ្ងៃ ដូចជាការគោរពដឹងគុណម្ដាយឪពុក ជីដូនជីតា ការស្ដាប់តាមការទូន្មានរបស់អ្នកគ្រូលោកគ្រូ ការចេះសហការធ្វើការងារជាមួយមិត្តភក្តិជាដើម ។

កុមារត្រូវរៀបចំឥរិយាបថល្អៗ ដើម្បីឱ្យសម្រេចគោលដៅជីវិតដោយផ្ដើមចេញពីការសម្រេចគោលដៅក្នុងការសិក្សាជាមុន ហើយបន្ទាប់មកពួកគេត្រូវបន្តគំនិតច្នៃប្រឌិតនិងការទទួលខុសត្រូវខ្ពស់ក្នុងទង្វើរបស់ខ្លួនប្រកបដោយគុណធម៌និងសីលធម៌រស់នៅល្អ ។

មេរៀនទី

# 1 ការកំណត់គោលដៅ

មនុស្សម្នាក់ៗតែងមានបំណងឱ្យជីវិតរបស់ខ្លួនរីកចម្រើនល្អប្រសើរជានិច្ច ។ ដើម្បីឈានដល់ការរីកចម្រើន មនុស្សត្រូវកំណត់គោលដៅសម្រាប់ជីវិតរបស់ខ្លួនឱ្យបានច្បាស់លាស់ ។



ការកំណត់គោលដៅ គឺជាការកំណត់មធ្យោបាយសម្រាប់ធ្វើកិច្ចការ ដើម្បីធ្វើឱ្យលទ្ធផលការងារសម្រេចបានជោគជ័យ ។

## 1. គោលដៅ

មនុស្សគ្រប់រូបតែងមានគំនិតថា ចង់មានទ្រព្យសម្បត្តិ បុណ្យស័ក្តិ ដើម្បីលើកតម្កើងជីវភាពនិងឋានៈខ្លួនឱ្យខ្ពង់ខ្ពស់សមតាមគោលដៅកំណត់ទុក ។

ក្នុងបឋមវ័យ យើងត្រូវខិតខំសិក្សារៀនសូត្រមុខវិជ្ជាផ្សេងៗសម្រាប់បន្តការសិក្សាឱ្យបានពូកែនិងឱ្យបានប្រសើរឡើង ។ ក្នុងមជ្ឈិមវ័យ យើងត្រូវសង្វាតគិតខំរិះរកមុខរបរវិជ្ជាជីវៈរបស់ខ្លួនដែលត្រូវចាប់យកមកបំពេញជីវិតតាមផែនការ តាមសមត្ថភាព ។ លុះដល់បច្ឆិមវ័យ យើងត្រូវខំកសាងកុសល ធ្វើទានទុកជាសម្បត្តិសម្រាប់ជាតិក្រោយទៀត ។ ដូចនេះគោលដៅ គឺអ្វីដែលមនុស្សចង់បានសម្រាប់ជីវិតរបស់ខ្លួននៅពេលអនាគត ។

## 2. ការកំណត់គោលដៅ

ការកំណត់គោលដៅ ជាការកំណត់នូវគោលបំណងសំខាន់ៗនៃសកម្មភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបំណងប្រាថ្នានៃការងាររបស់ខ្លួន ។ ជាទូទៅការកំណត់គោលដៅត្រូវមានសំណួរសួរខ្លួនឯងថា ៖

- តើយើងមានគោលដៅអ្វី ?
- ដើម្បីឱ្យគោលដៅបានសម្រេច តើយើងត្រូវធ្វើអ្វីខ្លះ ?
- តើត្រូវអនុវត្តសកម្មភាពនៅពេលណាខ្លះ ?
- តើគោលដៅនោះនឹងមានឧបសគ្គអ្វីខ្លះ ?
- តើយើងត្រូវជម្នះឧបសគ្គទាំងនោះដូចម្តេច ?
- តើកិច្ចការសម្រាប់គោលដៅនោះធ្វើបានដែរឬទេ ?

ដើម្បីធ្វើអ្វីមួយឱ្យទទួលបានជោគជ័យ គេត្រូវកំណត់គោលដៅនិងកំណត់វិធីដែលត្រូវធ្វើជាមុនសិន ។

ដូចនេះ គោលដៅត្រូវមានឈ្មោះជាក់លាក់ មានផែនការច្បាស់លាស់ មានវិធីជម្នះឧបសគ្គ និងមានសមត្ថភាពក្នុងការអនុវត្តគោលដៅប្រកបដោយប្រសិទ្ធភាព ។

## ៣. ការកំណត់គោលដៅក្នុងការរស់នៅ

គោលដៅក្នុងការរស់នៅ ជាការដៅ ឬកត់ចំណាំទុក ហើយគេត្រូវរៀបផែនការ ឬវិធីដើម្បីអនុវត្តឱ្យសម្រេចគោលដៅនោះ ។

ឧទាហរណ៍ ៖ ការកំណត់គោលដៅក្នុងការរស់នៅ ។




ចូរចម្លងល្បះខាងក្រោមចូលក្នុងសៀវភៅរបស់អ្នក រួចគូសរង្វង់ជុំវិញលេខពីមុខល្បះណាដែលអ្នកយល់ថា ជាគោលដៅក្នុងការរស់នៅដ៏ល្អសម្រាប់អ្នក ។

1. ខ្ញុំត្រូវរស់នៅដោយមានក្ដីសង្ឃឹម ។
2. ខ្ញុំរស់នៅដើម្បីរស់ប៉ុណ្ណោះ ។
3. ខ្ញុំរស់នៅពិតជាសំខាន់សម្រាប់គ្រួសារ សម្រាប់មិត្តភក្ដិ ។
4. ខ្ញុំត្រូវរៀបចំខ្លួនឯងឱ្យក្លាយជាកូនល្អ មិត្តល្អ និងសិស្សល្អ ។
5. ខ្ញុំរស់នៅដោយសង្ឃឹមលើទេវតា ។
6. ខ្ញុំរស់នៅដោយពឹងពាក់លើម្ដាយឪពុកប៉ុណ្ណោះ ។
7. ខ្ញុំត្រូវធ្វើអ្វីៗជាទីសង្ឃឹមដល់ម្ដាយឪពុក លោកគ្រូអ្នកគ្រូ និងមិត្តភក្ដិ ។
8. ខ្ញុំមិនដឹងរស់នៅដើម្បីអ្វីទេ ។
9. ខ្ញុំត្រូវរស់នៅឱ្យមានប្រយោជន៍សម្រាប់មនុស្សគ្រប់ៗគ្នា ។

## 4. ការសម្រេចគោលដៅក្នុងការរស់នៅ

ដើម្បីឱ្យគោលដៅបានសម្រេចយើងត្រូវរស់នៅដោយមានក្ដីសង្ឃឹម គឺជឿជាក់លើកម្លាំងកាយ កម្លាំងចិត្ត និងកម្លាំងបញ្ញារបស់យើង ។ យើងត្រូវមានសង្ឃឹមដើម្បីបម្រើប្រយោជន៍ខ្លួនឯង គ្រួសារ និងសង្គម ដូចខ្លឹមសារកំណាព្យខាងក្រោម ។

### រស់ដើម្បីក្ដីសង្ឃឹម

| | | |
|---|---|---|
| រស់គឺប្រាថ្នា | សង្ឃឹមដៅថា | គ្រប់រូបអង្គកាយ |
| ទោះមានឬក្រ | ខ្វះប្រាក់ចំណាយ | ព្រួយឬសប្បាយ |
| | សង្ឃឹមរស់ទៀត ។ | |
| នោះហើយបានជា | រាល់រូបគ្រប់គ្នា | លៃលករកឆ្កៀត |
| សង្វាតរៀនសូត្រ | ខំស្រូតរូតទៀត | សង្ឃឹមថាជាតិ |
| | គ្រួសារសុខសាន្ត ។ | |
| ទើបយើងមិ៑ម្នា | ស៊ូទ្រាំរស់ជា | រួមចិត្តកាយប្រាណ |
| រួមទាំងបញ្ញា | សាស្ត្រាចំណាន | សង្ឃឹមថាបាន |
| | កែទុក្ខសុខខ្លួន ។ | |
| រស់ត្រូវរិះរក | សំភីលៃលក | ឱ្យខ្ជាប់មាំមួន |
| ធ្វើការសម្រេច | នាំជោគជ័យសួ្ន | មិនកប់បំពួន |
| | ក្ដីសង្ឃឹមប៉ង ។ | |
| នេះជាវិធី | នាំចិត្តមូលមីរ | បំពេញបំណង |
| រស់ដោយសង្ឃឹម | ទើបយើងផុតឆ្លង | គោលដៅចម្បង |
| | ជីវិតសុខសាន្ត ។ | |

ដូចនេះ ដើម្បីជួយខ្លួនឯង និងជួយសង្គមឱ្យរីកចម្រើននោះ យើងត្រូវមានគោលដៅច្បាស់លាស់និងព្យាយាមតស៊ូជម្នះឧបសគ្គក្នុងការអនុវត្តផែនការ ។

## ៥. ការជម្នះឧបសគ្គ





មនុស្សគ្រប់រូបតែងកំណត់គោលដៅប្លែកៗគ្នា អាស្រ័យតាមតម្រូវការនិងសមត្ថភាពរបស់បុគ្គលម្នាក់ៗ ។ អ្នកខ្លះកំណត់ថា ត្រូវខិតខំរៀនដើម្បីក្លាយជាអ្នកវិទ្យាសាស្ត្រ ខ្លះចង់ធ្វើការក្នុងវិស័យមនុស្សធម៌ ខ្លះចង់ក្លាយជាវេជ្ជបណ្ឌិត និងខ្លះទៀតចង់ក្លាយជាយុទ្ធជនការពារទឹកដីជាដើម ។ អ្នកដែលបានកំណត់គោលដៅរួចត្រូវតែខិតខំប្រឹងធ្វើកិច្ចការតាមផែនការ ឬវិធីដែលបានដៅទុកក្នុងគោលដៅនោះឱ្យបានសម្រេចជោគជ័យ ។ ដូចនេះ អ្នកសិក្សាត្រូវរៀនឱ្យបានពូកែនូវមុខវិជ្ជាជំនាញដែលបានកំណត់ថា ជាគោលដៅសិក្សានាពេលអនាគត ។ កសិករត្រូវស្រូតរូតខិតខំភ្ជួរដាស់ដី សាបព្រោះបណ្ដុះដាំមិនទំនេរដៃ ។ ពួកគាត់មិនចេះត្អូញត្អែរទេ ទោះបីស្ថិតនៅក្រោមកម្ដៅថ្ងៃ ភ្លៀងខ្យល់ យ៉ាងណាក៏ដោយក៏ពួកគាត់ខិតខំធ្វើចំការស្រែឱ្យទាន់រដូវ ដើម្បីទទួលបានផលខ្ពស់ ។ ពាណិជ្ជករត្រូវរកស៊ីដោយសុចរិតទៀងត្រង់ ចេះពោលពាក្យរាក់ទាក់ប្រកបដោយទឹកមុខញញឹមស្រស់ស្រាយ ដើម្បីទាក់ទាញអតិថិជនឱ្យបានច្រើន ។

ដូចនេះវិធីជម្នះឧបសគ្គក្នុងគោលដៅគឺត្រូវមានសេចក្ដីតស៊ូ អំណត់ព្យាយាមហ៊ានពុះពារជម្នះការលំបាក និងឧបសគ្គ ។

## ៦. ការជម្នះឧបសគ្គក្នុងគោលដៅថែរក្សាបរិស្ថាន

ឧបសគ្គមួយក្នុងគោលដៅថែរក្សាបរិស្ថានសហគមន៍អាចរារាំងដល់ការអនុវត្ត គោលដៅអភិវឌ្ឍន៍សហគមន៍របស់យើង ។ តើឧបសគ្គទាំងនោះបណ្ដាលមកពីកត្តាអ្វីខ្លះ ? តើវាបង្កការលំបាកដល់ការអនុវត្តគោលដៅដូចម្ដេចខ្លះ ?

- ចូរចម្លងល្បះក្នុងតារាងខាងក្រោម រួចគូសសញ្ញា ( ✓ ) ក្រោយល្បះដែលអ្នកយល់ថា ជាឧបសគ្គ ឬជាសកម្មភាពដែលនាំគោលដៅថែរក្សាបរិស្ថានសម្រេចបានជោគជ័យនៅក្នុងសហគមន៍ ។

| សកម្មភាព | ឧបសគ្គ | គោលដៅសម្រេច |
|---|---|---|
| ប្រជាជននៅភូមិយើងនាំគ្នាធ្វើរបងព័ទ្ធជុំវិញផ្ទះ ។ | | |
| អ្នកភូមិប្រើប្រាស់បង្គន់អនាម័យគ្រប់ផ្ទះ ។ | | |
| យើងមិនចាប់សត្វព្រៃធ្វើជាអាហារ ឬលក់ដូរតទៅទៀតឡើយ ។ | | |
| កសិករខ្លះបានប្រើថ្នាំគីមីសម្លាប់សត្វល្អិតលើដំណាំទាំងគ្មានបច្ចេកទេស ។ | | |
| គេជីកសត្វពាហនៈចុះត្រាំ ឬមុជក្នុងទឹកស្រះសម្រាប់ប្រើប្រាស់ ។ | | |
| យើងរួមគ្នាដាំដើមឈើឡើងវិញ ។ | | |
| រោងចក្រនៅទីនេះ បានបង្ហូរកាកសំណល់ចោលក្នុងស្ទឹងជានិច្ច ។ | | |

ឧបសគ្គក្នុងគោលដៅថែរក្សាបរិស្ថានសហគមន៍ខាងលើកើតឡើងដោយសារកត្តាមនុស្សនិងធម្មជាតិ ។

ដូចនេះ យើងត្រូវយកចិត្តទុកដាក់ព្យាយាមធ្វើកិច្ចការថែរក្សាបរិស្ថានទាំងអស់គ្នាដើម្បីឱ្យសហគមន៍មានអនាម័យល្អនិងបរិស្ថានស្អាត ។

## ៧. ការអនុវត្តដើម្បីសម្រេចគោលដៅ " ភាពស្អាតនិងសណ្ដាប់ធ្នាប់ផ្ទះបាយ "

ដើម្បីសម្រេចគោលដៅអ្វីមួយ គេត្រូវធ្វើកិច្ចការច្រើនណាស់ ។ យើងសាកគិតមើលលើផ្នែកមួយនៃផ្ទះរបស់យើងគឺផ្ទះបាយ ដែលខ្លះសង់ដាច់ដោយឡែក ខ្លះនៅជាមួយផ្ទះធំ ។ ក្នុងផ្ទះបាយទោះធំក្ដី តូចក្ដីត្រូវមានចង្ក្រាន ទូម្ហូបអាហារ រាវចាន កន្លែងដាក់ឆ្នាំង កញ្ជ្រែង កាំបិត បំពង់ស្លាបព្រា កំណាត់ជូតចាន ទ្រនាប់ដៃ កន្លែងដាក់ជ្រញ់ ដាក់អុស ធ្យូង តុដាក់កំសៀវទឹក ធុងទឹក កែវ ផ្តិល ជាដើម ។ ដើម្បីធ្វើឱ្យផ្ទះបាយស្អាតមានសណ្ដាប់ធ្នាប់ល្អ នាំមកនូវសុខុមាលភាពសម្រាប់គ្រួសារ យើងត្រូវសំអាតនិងរៀបចំគ្រប់សម្ភារៈទាំងអស់ដែលមាននៅក្នុងផ្ទះបាយ ។

- ចូរអានល្បះក្នុងតារាងខាងក្រោម រួចគូសសញ្ញា (✓) នៅក្នុងប្រអប់ណាដែលជាសកម្មភាពរក្សាភាពស្អាតនិងសណ្ដាប់ធ្នាប់ក្នុងផ្ទះបាយរបស់អ្នក ។

| សកម្មភាព | អនុវត្តជាប្រចាំ | អនុវត្តម្ដងម្កាល |
|---|---|---|
| ខ្ញុំជូតសំអាត ជុសលាង ចាន ឆ្នាំង ស្លាបព្រា | | |
| ខ្ញុំទុកដាក់ចានក្នុងទូចាន ឬរាវចាន | | |
| ខ្ញុំដាក់ឆ្នាំងនៅកន្លែងពាក់ឆ្នាំង | | |
| ខ្ញុំទុកដាក់កាំបិតតូចធំនៅជិតកន្លែងដាក់ជ្រញ់ | | |
| ខ្ញុំបោកសំអាតកំណាត់ជូតចាន ទ្រនាប់ដៃ | | |
| ខ្ញុំជូតសំអាតបំពង់ស្លាបព្រា | | |
| ខ្ញុំទុកដាក់អុស ធ្យូងតាមកន្លែង | | |
| ខ្ញុំគ្របនិងលាងសំអាតពាងទឹក | | |
| ខ្ញុំបោសជូតសំអាតចង្ក្រាន | | |
| ខ្ញុំជួយរៀបចំទុកដាក់សម្ភារៈផ្ទះបាយ | | |

### មេរៀនសង្ខេប

ការរស់នៅដោយកំណត់គោលដៅច្បាស់លាស់នឹងនាំឱ្យគេរកឃើញវិធីធ្វើឱ្យសម្រេចជោគជ័យក្នុងជីវិតនាពេលអនាគត ។ មនុស្សមានការកំណត់គោលដៅជាមនុស្សដែលស្គាល់តម្លៃរបស់ខ្លួនបានច្បាស់លាស់អាចនាំឱ្យជីវិតរបស់ខ្លួនស្រស់បំព្រងជានិច្ច ។ ដើម្បីសម្រេចគោលដៅណាមួយ គេត្រូវអនុវត្តកិច្ចការឱ្យបានច្រើន ហើយត្រូវជម្នះនូវរាល់ឧបសគ្គ ។



## សំណួរ

**ក. ចូរគូសសញ្ញា( ✓ )ក្នុងប្រអប់ដែលអ្នកយល់ថាចម្លើយត្រឹមត្រូវ**

1. គោលដៅនៃជីវិតរបស់មនុស្សម្នាក់ៗមិនមែនគ្រាន់តែរស់រានមានជីវិតទេ គឺត្រូវ

☐ក. រស់ដើម្បីរស់ ☐ខ. រស់តាមធម្មជាតិកំណត់ឱ្យ

☐គ. រស់ដើម្បីលេងសប្បាយ ☐ឃ. រស់ដើម្បីភាពថ្លៃថ្នូរ ។

2. មនុស្សដែលមានការកំណត់គោលដៅច្បាស់លាស់ ជាអ្នកដែល

☐ក. ស្គាល់តម្លៃរបស់ខ្លួន ☐ខ. អួតអាង

☐គ. ពូកែតែនិយាយ ☐ឃ. គ្មានប្រយោជន៍ ។

**ខ. ចូរឆ្លើយនឹងសំណួរខាងក្រោម :**

1. តើការកំណត់គោលដៅក្នុងការរស់នៅនាំឱ្យអ្នកក្លាយជាមនុស្សដូចម្តេច ?
2. តើការកំណត់គោលដៅត្រូវមានអ្វីខ្លះ ?
3. តើអ្នកបានកំណត់យកគោលដៅអ្វីក្នុងឆ្នាំនេះ ?
4. តើអ្នកត្រូវរៀបចំសកម្មភាពអ្វីខ្លះដើម្បីអនុវត្តគោលដៅខាងលើ ?
5. ចូរបង្ហាញការអនុវត្តគោលដៅខាងលើ ដើម្បីធ្វើឱ្យសម្រេចបានគោលដៅ ។

មេរៀនទី

# 2 គោលដៅនៅក្នុងការសិក្សា

ការសិក្សាជាទិសដៅសម្រាប់ធ្វើឱ្យសិស្សានុសិស្សទទួលបាននូវចំណេះដឹង និងចំណេះធ្វើ ។ ដូចនេះ សិស្សត្រូវរៀបចំគោលដៅក្នុងការសិក្សាសម្រាប់ខ្លួនឱ្យបានត្រឹមត្រូវ ។



## 1. គោលដៅសិក្សារបស់សិស្ស

ការសិក្សាជាកិច្ចការចាំបាច់របស់សិស្សានុសិស្សគ្រប់រូបដែលត្រូវខិតខំរៀនសូត្រ គឺរៀនទាំងក្នុងសាលានិងក្រៅសាលា ដោយមិនអាចខកខានបាន ។ នៅសាលារៀន អ្នកគ្រូលោកគ្រូជាឪពុកម្ដាយទីពីររបស់សិស្ស ។ សិស្សត្រូវខិតខំយកចិត្តទុកដាក់ស្ដាប់តាមការពន្យល់ណែនាំកុំបីធ្វេសប្រហែស ។ នៅក្រៅសាលារៀន សិស្សត្រូវរៀនខ្លួនឯងដោយខិតខំស្រាវជ្រាវនិងធ្វើកិច្ចការរបស់សាលាឱ្យបានទៀងទាត់ ។

ដូចនេះ ដើម្បីក្លាយជាសិស្សទទួលបានជោគជ័យក្នុងការរៀនសូត្រ អ្នកត្រូវចេះកំណត់គោលដៅក្នុងការសិក្សានិងខិតខំធ្វើកិច្ចការ ដោយជម្នះនូវរាល់ឧបសគ្គដែលកើតមានចំពោះមុខ ។

## 2. គោលដៅសិក្សាប្រចាំឆមាស

ការសិក្សាប្រចាំឆមាសនឹងទទួលបានជោគជ័យ ឬពិន្ទុល្អនៅពេលណាយើងមានការកំណត់គោលដៅក្នុងការសិក្សាបានត្រឹមត្រូវ ព្រោះថាយើងបានរិះរកវិធីល្អៗសម្រាប់អនុវត្តសកម្មភាពសិក្សា ។

គោលដៅសិក្សាប្រចាំឆមាសរបស់សិស្ស មានការកំណត់វិធីរៀនឱ្យបានពូកែគ្រប់មុខវិជ្ជាក្នុងរយៈពេលខ្លី ។ វិធីដែលធ្វើឱ្យសិស្សរៀនបានពូកែរួមមាន ការហាត់អានសរសេរ ស្ដាប់ការពន្យល់ណែនាំរបស់គ្រូឬមិត្តភក្ដិ ការហ៊ានសួរ និងហ៊ានឆ្លើយ ។ លើសពីនេះត្រូវចូលរួមធ្វើកិច្ចការក្រុម ដើម្បីធ្វើឱ្យអ្នកទទួលបានចំណេះដឹងនិងមានឥរិយាបថល្អដោយចេះយោគយល់អធ្យាស្រ័យគ្នា ។

ឧទាហរណ៍គោលដៅសិក្សារបស់សិស្សពីរនាក់ ។

គោលដៅសិក្សាប្រចាំឆមាសទី 1 របស់ខ្ញុំគឺ

ខ្ញុំត្រូវដណ្ដើមពិន្ទុឱ្យបានល្អគ្រប់មុខវិជ្ជាដូចនេះខ្ញុំត្រូវ ៖
- ខិតខំហាត់អាន សរសេរ ធ្វើលំហាត់លេខរាល់ថ្ងៃ ។
- រំលឹកមេរៀនរាល់ពេល មុននឹងទៅសាលារៀន ។
- ធ្វើលំហាត់គ្រប់កិច្ចការដែលគ្រូដាក់ឱ្យធ្វើនៅផ្ទះ ។



ចំណែកខ្ញុំត្រូវរៀនមុខវិជ្ជាភាសាខ្មែរលើសំណេរបន្ថែមទៀត ដូចជាសរសេរពាក្យ ល្បះក្នុងអត្ថបទឱ្យបានត្រឹមត្រូវនិងរហ័ស ខ្ញុំក៏ត្រូវធ្វើលំហាត់នៃមុខវិជ្ជាទាំង 3 ទៀតឱ្យបានពិន្ទុល្អផងដែរ ។

ដូចនេះ យើងត្រូវរៀបចំផែនការសិក្សាប្រចាំឆមាសនេះ ឱ្យបានច្បាស់លាស់ ។

## ៣. ការរៀបចំផែនការសិក្សា




ការរៀបចំផែនការសិក្សា ជាការរៀបចំសកម្មភាពសិក្សាដែលមានគោលដៅច្បាស់លាស់ ជាវិធីជំរុញឱ្យគ្រប់ដំណើរការសិក្សារបស់យើងទទួលបានជោគជ័យពិតប្រាកដ ។ ការរៀបចំផែនការសិក្សាល្អដោយអនុវត្តបានត្រឹមត្រូវ អ្នកនឹងក្លាយជាអ្នកដឹកនាំដ៏ឈ្លាសវៃនៅពេលអនាគត ។

ដើម្បីធ្វើផែនការសិក្សាប្រកបដោយប្រសិទ្ធភាពត្រូវ ៖

- បែងចែកពេលវេលាសិក្សាប្រចាំថ្ងៃនិងកំណត់ពីអ្វីដែលត្រូវសិក្សាឱ្យបានចេះចាំនៅក្នុងថ្នាក់ និងក្រៅថ្នាក់ ។
- កំណត់បញ្ជីមេរៀនទាំង4មុខវិជ្ជា សម្រាប់សិក្សាប្រចាំថ្ងៃ ប្រចាំខែ និងប្រចាំឆមាស ។
- កំណត់ខ្លឹមសារមេរៀន ដើម្បីរកអ្នកជួយគាំទ្រ ឬជួយពន្យល់ណែនាំបន្ថែម
- កំណត់វិធីជម្នះឧបសគ្គនានា ។

តើអ្នកមានផែនការសិក្សានៅឆមាសនេះ ហើយឬនៅ ? តើអ្នកត្រូវធ្វើដូចម្ដេចខ្លះ ?

## 4. ផែនការសិក្សា

អ្នកសិក្សាដែលមានភាពវៃឆ្លាតត្រូវចេះធ្វើផែនការសិក្សាសម្រាប់អនុវត្តមួយម៉ោង មួយថ្ងៃ មួយខែ មួយឆមាស មួយឆ្នាំ និងបន្តបន្ទាប់ទៅមុខទៀត ។ ផែនការសិក្សាមាន ជាជំហានៗពីតូចទៅធំ ពីរយៈពេលខ្លីទៅរយៈពេលវែង ។

ផែនការសិក្សាជាកម្មវិធីមួយដែលកំណត់ផ្លូវឱ្យអ្នកសិក្សារៀបចំសកម្មភាពរៀនទៅតាមលំដាប់លំដោយខ្លឹមសារមេរៀន ។ យើងត្រូវអនុវត្តផែនការសិក្សាពីបច្ចុប្បន្ននេះទៅគឺខិតខំបំពេញនិងហ្វឹកហាត់ ដោយយកចិត្តទុកដាក់លើការសិក្សារបស់ខ្លួន ។

ផែនការសិក្សាដើម្បីអនុវត្តគោលដៅសិក្សាប្រចាំឆមាស ប្រកបដោយជោគជ័យ រួមមាន:

1. ត្រូវខិតខំរៀនមុខវិជ្ជាទាំង4នៅសាលារៀននិងនៅផ្ទះឱ្យបានរាល់ថ្ងៃ ។
2. ត្រូវរៀននៅផ្ទះតាមកាលវិភាគ ។
3. ត្រូវរំលឹក ឬរៀនម្តងទៀតពីអ្វីៗដែលរៀននៅសាលា ដើម្បីពង្រឹងចំណេះដឹង ។
4. ត្រូវរៀនមេរៀនថ្មី ឬមេរៀនមិនទាន់យល់ច្បាស់ ។
5. ត្រូវមានសៀវភៅសិក្សាគោលទាំង4មុខវិជ្ជានិងសៀវភៅស្រាវជ្រាវផ្សេងៗទៀត ។
6. ត្រូវចូលរួមធ្វើកិច្ចការនៅក្នុងថ្នាក់ ឬក្នុងក្រុមជាមួយមិត្តភក្តិ ។
7. ត្រូវជម្នះចិត្តដោយកុំឱ្យនរណាម្នាក់បង្ខំ ឬបបួលយើងចេញទៅលេងជាមួយបានឡើយ ។
8. ត្រូវហ៊ានសួរទៅអ្នកដែលចេះនិងយល់ជាងខ្លួនលើខ្លឹមសារ ឬលំហាត់ដែលមិនទាន់យល់ច្បាស់ ។

## 5. ការអនុវត្តផែនការសិក្សា









ការសិក្សាត្រូវមានផែនការធ្វើឱ្យសម្រេចគោលដៅសិក្សា ។ ការអនុវត្តផែនការក្នុងគោលដៅសិក្សាប្រចាំឆមាសទី 1 មានដូចជា ៖

- នៅពេលសិក្សានៅក្នុងថ្នាក់ត្រូវស្តាប់ការណែនាំពន្យល់របស់គ្រូនិងកត់ត្រាគ្រប់ចំណុចនៃខ្លឹមសារមេរៀនឬលំហាត់ ។
- ពេលធ្វើកិច្ចការក្រុមត្រូវចូលរួមបញ្ចេញគំនិតយោបល់និងបង្ហាញហេតុផលពីអ្វីដែលយល់ថាត្រឹមត្រូវ ។
- ពេលរៀននៅផ្ទះត្រូវរំលឹកមេរៀនដែលបានរៀនពីសាលាទាំងអស់ ទើបអាចបន្តរៀនមេរៀនថ្មីសម្រាប់រៀនថ្ងៃស្អែកទៅតាមកាលវិភាគដែលត្រូវរៀននៅក្នុងថ្នាក់ ។
- ខ្លឹមសារណាមិនយល់ច្បាស់ត្រូវសាកសួរអ្នកដែលចេះជាងឱ្យជួយពន្យល់ណែនាំបន្ថែម ។
- ការស្តាប់វិទ្យុ ឬការទស្សនាទូរទស្សន៍ក្នុងកម្មវិធីកម្សាន្តសប្បាយត្រូវកាត់បន្ថយដោយជ្រើសរើសកម្មវិធីណាទាក់ទងនឹងចំណេះដឹងផ្សេងៗដែលបម្រើការសិក្សាដូចជានាទីអប់រំនិងរឿងនិទានល្អៗសម្រាប់កុមារ ។
- ការសិក្សាតាមផែនការដែលបានរៀបចំ ដោយសេចក្តីព្យាយាមខ្ពស់នឹងនាំឱ្យអ្នកសិក្សាទទួលបានលទ្ធផលតាមប្រាថ្នា ។

**មេរៀនសង្ខេប**

ការកំណត់គោលដៅនៅក្នុងការសិក្សា ជាកត្តាមួយធ្វើឱ្យការសិក្សាទទួលបានជោគជ័យ ។ ក្នុងគោលដៅតែងមានផែនការដែលយើងបានគិតទុកជាមុននូវសកម្មភាពដែលត្រូវសិក្សា បញ្ហាដែលត្រូវប្រឈម និងវិធីនានាដែលត្រូវដោះស្រាយ ។ ការសិក្សាមានផែនការធ្វើឱ្យយើងជឿជាក់លើសមត្ថភាពរបស់ខ្លួននិងឈានទៅសម្រេចគ្រប់បំណងប្រាថ្នា ។

## សំណួរ

**ក. ចូរឆ្លើយនឹងសំណួរខាងក្រោម :**

1. តើអ្នកមានគោលដៅក្នុងការសិក្សាប្រចាំឆមាសដូចម្តេច ?
2. តើអ្នកកំណត់ចំណុចអ្វីខ្លះ នៅពេលដាក់ផែនការសិក្សា ?
3. ហេតុអ្វី បានជាអ្នកធ្វើផែនការសិក្សា ?

**ខ. ចូរគូសរង្វង់ជុំវិញលេខណាដែលជាចម្លើយត្រឹមត្រូវ ។**

ការសិក្សាខាងក្រោមនេះ តើសកម្មភាពសិក្សាណាខ្លះ ដែលអ្នកជ្រើសរើសសម្រាប់អនុវត្ត ?

1. ខ្ញុំខិតខំរៀនឱ្យបានពូកែទាំងបួនមុខវិជ្ជា ។
2. ខ្ញុំត្រូវធ្វើលំហាត់គណិតវិទ្យាឱ្យបានញឹកញាប់ ។
3. រាល់ល្ងាចក្រោយពេលបាយ ខ្ញុំតែងមើលកាលវិភាគសម្រាប់រៀនថ្ងៃស្អែក ។
4. ខ្ញុំខំធ្វើកិច្ចការ ឬរៀនមេរៀនណាដែលរៀនពីសាលាឱ្យបានចេះចាំ ។
5. កិច្ចការណាដែលមិនទាន់បានយល់ច្បាស់ខ្ញុំសុំឱ្យឪពុកម្តាយឬបងខ្ញុំជួយពន្យល់ ។
6. ខ្ញុំមិនចូលរួមការកម្សាន្តនៅពេលកំពុងសិក្សានៅផ្ទះ ។

មេរៀនទី

# 3 ឥរិយាបថនិងតម្លៃ

អ្នកមានឥរិយាបថល្អ នាំឱ្យការរស់នៅមានរបៀបរៀបរយ និងត្រូវបានគេគោរពស្រឡាញ់រាប់អាន ។ តើអ្នកត្រូវធ្វើដូចម្ដេច ដើម្បីក្លាយជាសិស្សមានឥរិយាបថល្អនិងមានតម្លៃ ?

## 1. ការគោរពឱនលំទោន

តើអ្នកប្រតិបត្តិកាយវិការខាងក្រោមនេះនៅពេលណាខ្លះ ?



ការគោរពឱនលំទោនជាកាយវិការបញ្ជាក់ពីឥរិយាបថមានតម្លៃសីលធម៌សុភាវធម៌របស់មនុស្សដែលមានការអប់រំល្អ ។ កាយវិការទាំងនោះមានដូចជា ការសំពះជម្រាបសួរ ជម្រាបលា ការសំពះព្រះសង្ឃ ការចាប់ដៃ ការអរគុណ ការបម្រើអ្នកមានគុណ ការមិនរំខានគ្នានិងការជួយគ្នាជាដើម ។ ទង្វើទាំងនេះជាដំបូន្មានដែលនាំឱ្យយើងចៀសវាងពីអំពើមិនគប្បី ហើយនាំយើងឱ្យប្រព្រឹត្តអំពើល្អ ។

ដូចនេះកាយវិការគោរពឱនលំទោនត្រូវអនុវត្តជាប្រចាំក្នុងជីវភាពរស់នៅ ព្រោះជាទម្លាប់មានតម្លៃល្អក្នុងការរស់នៅនិងជាកត្តាមួយដែលបណ្ដុះទឹកចិត្តឱ្យស្រឡាញ់រាប់អានគ្នាដោយសុទ្ធចិត្ត និងរស់នៅជាមួយគ្នាដោយសុខសាន្ត ។

## ក. ការគោរព បម្រើជីដូនជីតា និងមាតាបិតារបស់យើង



កាយវិការគោរពជីដូនជីតា ម្ដាយឪពុក ជាតម្លៃដ៏សំខាន់សម្រាប់កូនចៅផៅសន្ដាន បញ្ជាក់ភាពស្មោះត្រង់ហើយសំដែងឡើងឱ្យឃើញនូវទឹកចិត្តតបស្នងទៅនឹងអ្នកដែលបានផ្ដល់ជីវិត និងជាអ្នកបីបាច់ថែរក្សាស្រឡាញ់ប្រោសប្រណីដល់ខ្លួន ។ ក្នុងការគោរពបម្រើលោកអ្នកមានគុណ កូនចៅត្រូវគោរពនិងស្ដាប់ដំបូន្មានល្អៗ ឬជួយសម្រាលការងារខ្លះៗរបស់លោក ។ មុនពេលចេញទៅណា កូនចៅត្រូវជម្រាប ឬសុំអនុញ្ញាតពីលោកជាមុន ដោយបង្ហាញហេតុផលនិងផលប្រយោជន៍នៃកិច្ចការនោះ ។

ការគោរពនិងការបម្រើជីដូនជីតា ម្ដាយឪពុករបស់យើងធ្វើឱ្យគ្រួសារសប្បាយរីករាយនិងមានសុភមង្គល ។ ដូចនេះ ការគោរពជាទង្វើមួយដែលយើងត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួន ទើបក្លាយជាកូនល្អនិងពលរដ្ឋថ្លៃថ្នូរ ។

## ២. ការគោរពគ្រូ



សិស្សត្រូវស្រឡាញ់គោរពគ្រូ ដោយនិយាយសំដីទន់ភ្លន់និងប្រើពាក្យគួរសមជានិច្ច ។ ពេលចូលរៀនសិស្សត្រូវក្រោកឈរដោយរក្សាដងខ្លួនឱ្យត្រង់សមរម្យ និងលើកដៃទាំងពីរសំពះគ្រូ ។ ពេលមករៀនយឺតត្រូវសុំអនុញ្ញាតចូលរៀនពីគ្រូជាមុន ។ បើគ្រូនិយាយត្រូវប្រុងស្តាប់ដោយយកចិត្តទុកដាក់ និងកត់ត្រាចំណុចសំខាន់ៗ ។ ការសំដែងកាយវិការគោរព សំពះ ចេះប្រើវាចាពីរោះ និងមានទឹកមុខសមរម្យ គឺជាតម្លៃរបស់សិស្សគ្រប់រូបដែលត្រូវមានជាប្រចាំ ទើបជាគំរូល្អ ។

តើអ្នកបានគោរពគ្រូរបស់អ្នកដូចម្តេចខ្លះ ? ចូរបង្ហាញពីកាយវិការនិងពាក្យសដីដែលអ្នកធ្លាប់អនុវត្ត ។

## គ. ការគោរពចំពោះព្រឹទ្ធាចារ្យ



ចាស់ព្រឹទ្ធាចារ្យជាចាស់ទុំ ដែលមានបទពិសោធន៍ល្អៗនៅក្នុងជីវិតនិងចេះដឹងរឿងរ៉ាវច្រើននៅក្នុងសង្គម ។ លោកអាចប្រៀនប្រដៅកូនចៅឱ្យប្រព្រឹត្តអំពើល្អនិងមានចិត្តមេត្តាអត់ឱនឱ្យគ្នាទៅវិញទៅមក ។

យើងត្រូវគោរពស្រឡាញ់ ឱនលំទោនជួយធុរៈគាត់គ្រប់បែបយ៉ាង ដូចជាជួយដឹកដៃ កាន់របស់ជូន ផ្ទេរកន្លែងជូនគាត់នៅតាមរថយន្តឈ្នួល ឬកន្លែងចង្អៀតជាដើម ។

ចូរបង្ហាញពីកាយវិការគោរពចាស់ព្រឹទ្ធាចារ្យដែលអ្នកធ្លាប់អនុវត្តសម្រាប់ធ្វើជាគំរូដល់មិត្តរួមថ្នាក់ ។

## ឃ. ការគោរពមិត្តភក្តិ



មិត្តភក្តិជាមនុស្សដែលយើងទាក់ទងគ្នារាល់ថ្ងៃ ។ យើងត្រូវមានទំនាក់ទំនងគ្នាដោយរីករាយនិងប្រពៃជាមួយមិត្តដោយចេះយកអាសាគ្នា គោរពគ្នា ធ្វើកិច្ចការណាល្អៗសម្រាប់មិត្តដោយសុទ្ធចិត្តនិងភាពរីករាយ ។

មិត្តភក្តិអាចប្តូរបទពិសោធន៍ និងរក្សាការប្រាស្រ័យទាក់ទងជាមួយគ្នាដោយមិនប្រកាន់ទីកន្លែង ពេលវេលា។ បច្ចុប្បន្ន យើងមានភាពងាយស្រួលច្រើនក្នុងការទាក់ទងគ្នា ។ មិត្តភក្តិ អាចជជែក ឬផ្ញើសារជាជំបូន្មាន ឬគំនិតល្អៗឱ្យគ្នាទៅវិញទៅមកតាមប្រព័ន្ធបច្ចេកវិទ្យាទំនើបៗ ទោះបីយើងរស់នៅជិត ឬនៅឆ្ងាយពីគ្នាក៏ដោយ ។

អំពើទាំងនេះ ជាហេតុនាំឱ្យកុមារអាចរស់នៅជាមួយគ្នាដោយស្រុះស្រួល ។

## ង. ការគោរពស្ត្រីភេទនិងជនពិការ





គេចាត់ទុកស្ត្រីជាមាតានៃពិភពលោក ។ អ្នកមិនត្រូវរើសអើងស្ត្រីភេទទេ ។អ្នកត្រូវគោរពស្ត្រីភេទ ដោយប្រកាន់អាកប្បកិរិយាទន់ភ្លន់ទឹកមុខរីករាយនិងចិត្តសប្បុរសជានិច្ច ។ ដូចនេះ នៅកន្លែងអង្គុយទីសាធារណៈ ត្រូវទុកឱ្យស្ត្រីភេទ ស្ត្រីមានផ្ទៃពោះនិងស្ត្រីចាស់ជរាអង្គុយមុន ឬបើទីកន្លែងចង្អៀតត្រូវឱ្យស្ត្រីភេទទៅមុននិងចៀសវាងនិយាយពាក្យមិនសមរម្យនៅចំពោះមុខគាត់ ។ អ្នកត្រូវចាត់ទុកស្ត្រី ជាជីដូន បងប្អូនស្រីអ្នកគ្រូម្តាយធំ ម្តាយមីង ឬមិត្តភក្តិស្រីរួមថ្នាក់របស់យើងដែរ ។

ជនពិការរស់នៅយ៉ាងលំបាកលំបិន ។ ទោះបីអ្នកនោះពិការដោយហេតុអ្វីក៏ដោយក៏គាត់ជាមនុស្សដែលយើងត្រូវអាណិតអាសូរនិងជួយសង្គ្រោះ ។ យើងមិនគួរមាក់ងាយធ្វើត្រាប់តាម ឬចំអកឡកឡឺយឱ្យគាត់ឡើយ ពិសេសយើងត្រូវជួយរុញរទេះ ឬហុចនេះហុចនោះ ឬផ្តល់កន្លែងឱ្យគាត់បានអង្គុយរៀនជាមួយយើងដោយងាយស្រួលផង ។

## 2. សុជីវធម៌

### ក. សុជីវធម៌ចំពោះជនបរទេស



អ្នកប្រទេសដទៃចូលមកបំពេញកិច្ចការផ្សេងៗ មកលេងកម្សាន្តជាទេសចរណ៍ ឬចូលមករស់នៅក្នុងប្រទេសយើងតាមច្បាប់អន្តោប្រវេសន៍ហៅថាជនបរទេស ។ បែបបទសុជីវធម៌ យើងត្រូវមានអាកប្បកិរិយាសមរម្យ សំដីទន់ភ្លន់សុភាពរាបសា រាក់ទាក់ចំពោះជនបរទេសឱ្យដូចជនជាតិយើងដែរ ។ បើជនបរទេសចង់ដឹងពីផ្លូវ អាសយដ្ឋានទីកន្លែងផ្សេងៗ យើងត្រូវជួយផ្ដល់ដំណឹងដោយរីករាយតាមលទ្ធភាព ។

យើងត្រូវចេះជួយយកអាសាជនបរទេស នៅពេលពួកគាត់មានគ្រោះថ្នាក់ផ្សេងៗ ។ នេះជាការលើកតម្កើងកិត្តិយសនិងសេចក្ដីថ្លៃថ្នូររបស់ជាតិយើង ។

បើអ្នកជួបជនបរទេសនៅកន្លែងណាមួយ តើពេលនោះអ្នកត្រូវធ្វើដូចម្ដេចខ្លះដើម្បីបង្ហាញថា អ្នកមានសុជីវធម៌ជាមួយពួកគេ ?

## ១. សុជីវធម៌នៅទីសាធារណៈ



នៅតាមរថយន្តឈ្នួល តាមរោងមហោស្រព ក្នុងវត្តអារាមជាទីកន្លែងសាធារណៈ ។ នៅកន្លែងទាំងនោះ យើងគ្រប់គ្នាត្រូវរៀបចំឥរិយាបថឱ្យបានសមរម្យគឺគោរពនិងផ្ដល់សិទ្ធិឱ្យគ្នាទៅវិញទៅមក និងអនុវត្តតាមបម្រាមជានិច្ច ។

ពេលធ្វើដំណើរតាមរថយន្តឈ្នួលយើងត្រូវចេះគោរពសិទ្ធិអ្នកដទៃនិងប្រកាន់អាកប្បកិរិយាថ្លៃថ្នូរ ។ នៅតាមទីសាធារណៈ អ្នកមិនត្រូវជជែកគ្នាខ្លាំងៗ ឬខាកស្ដោះញើសសំបោរ ចោលសំបកនំ ចំណីអាហារតាមផ្លូវឬបោះចេញតាមបង្អួចឡានឡើយព្រោះវាប៉ះពាល់បរិស្ថាននិងអាចបង្កគ្រោះថ្នាក់ដល់អ្នកដំណើរផ្សេងៗទៀត ។ បើមានចាស់ជរាជនពិការ ស្ត្រីមានផ្ទៃពោះ យើងគប្បីផ្ទេរ ឬជួយសម្រួលកន្លែងអង្គុយជូនគាត់ដោយទឹកមុខញញឹម ។

ក្នុងរោងមហោស្រពត្រូវអង្គុយឱ្យបានសមរម្យ រក្សាភាពស្ងៀមស្ងាត់ និងចូលរួមទះដៃអបអរសាទរចំពោះអ្នកសំដែងតាមបែបបទនៃខ្លឹមសារ ។ យើងគ្រប់គ្នាមិនត្រូវទម្លាប់ហៅសិល្បករថា “ អា មីង មីហាង” ឡើយ ។

វត្តអារាមជាកន្លែងគោរពបូជាសម្រាប់ សង្រួមកាយ វាចា ចិត្តនៃពុទ្ធសាសនិកជនទូទៅ ។ ដូចនេះយើងមិនត្រូវជិះកង់ ម៉ូតូ ពាក់មួក បេះបោចផ្កា ផ្លែឈើ បាញ់សត្វ ផឹកស្រា ឬលួចទ្រព្យសម្បត្តិផ្សេងៗឡើយ ។

## គ. ឥរិយាបថគួរចៀសវាង



ការរស់នៅជាមួយគ្នា បើយើងមិនប្រុងស្មារតីមិនបានគិតនោះ ខ្លួនយើងនឹងក្លាយទៅជាជនរំខានអ្នកដទៃ ។ កាយវិការដែលនាំឱ្យរំខានដល់ផ្លូវកាយអ្នកដទៃ រួមមានដូចជាការឈរបាំងគេ ធ្វើឫកក្រអឺតក្រទមដាក់គេ ចូលចិត្តអង្គុយប្រជ្រៀតនឹងគេ និយាយជំទាស់នឹងគេដោយគ្មានហេតុផល ឈ្លោះ ច្រណែននិន្ទា មានបំណងចង់ឱ្យគេអន់ជាងខ្លួន មិនព្រមស្ដាប់ ឬរំលែកយោបល់ពីមិត្តភក្តិដែលនាំឱ្យគេពិបាក ឬមិនអាចទទួលយកបាន ។ កាយវិការដែលនាំឱ្យរំខានដល់ផ្លូវចិត្តគេមានដូចជា ការស្រែកឡូឡា និយាយពាក្យចំអាសចំអូង ប្រើសំដីទ្រគោះបោះបោកដែលនាំឱ្យគេខឹង ឬអាក់អន់ចិត្ត ។

ទង្វើខាងលើនេះ មនុស្សទូទៅមិនចូលចិត្តនិងមិនគាំទ្រឡើយ ហើយគេក៏មិនឱ្យតម្លៃថាជាពលរដ្ឋល្អក្នុងសង្គមឡើយ ។ ដូចនេះកុមារគ្រប់ៗរូបត្រូវខិតខំចៀសវាងឱ្យបាន ព្រោះវាជាឥរិយាបថមិនល្អ ។

**មេរៀនសង្ខេប**

ការប្រកាន់នូវឥរិយាបថល្អត្រឹមត្រូវនឹងនាំឱ្យយើងមានតម្លៃសម្រាប់ខ្លួន គ្រួសារនិងសង្គម ។ សង្គមកាន់តែរីកចម្រើន អារ្យធម៌កាន់តែខ្ពស់ ហើយសុភាវធម៌ក៏កាន់តែចម្រើនដែរ ។ ការប្រកាន់យកនូវឥរិយាបថល្អប្រពៃនឹងនាំឱ្យយើងមានមិត្តភក្តិច្រើន មានកេរ្តិ៍ឈ្មោះ និងមានកិត្តិយសថ្លៃថ្នូរ ។

ដូចនេះ យើងត្រូវប្រកាន់យកអាកប្បកិរិយាគោរពឱនលំទោនទាំងកាយ វាចា ចិត្ត ចំពោះមនុស្សដែលនៅជុំវិញខ្លួនជានិច្ច ។



## សំណួរ

### ក. ចូរឆ្លើយនឹងសំណួរខាងក្រោម :

1. តើការគោរពឱនលំទោនមានកាយវិការដូចម្តេចខ្លះ ?
2. ហេតុអ្វីបានជាអ្នកត្រូវគោរពបម្រើជីដូនជីតា ម្តាយឪពុក ?
3. តើការគោរពគ្នានាំឱ្យមានប្រយោជន៍អ្វីខ្លះ ?
4. ចូរបង្ហាញពីឥរិយាបថ គោរពឱនលំទោន មិនគោរពឱនលំទោនចំពោះមិត្តភក្តិ រួចផ្តល់មូលហេតុនៃការពេញចិត្ត ឬមិនពេញចិត្តចំពោះទង្វើនោះ ។

### ខ. ចូរគូសរង្វង់ជុំវិញលេខណាដែលបង្ហាញពីឥរិយាបថល្អដែលអ្នកធ្លាប់អនុវត្ត

1. ម៉ែពុកកូនសូមជម្រាបលាទៅសាលារៀន ។
2. ម៉ែពុក ខ្ញុំសុំទៅដើរលេងជាមួយមិត្តភក្តិហើយ ។
3. សូមមិត្តជួយយកសៀវភៅកិច្ចការនេះទៅជូនអ្នកគ្រូឱ្យខ្ញុំផង ។
4. ខ្ញុំចូលចិត្តអង្គុយបាំងមុខគេដើម្បីធ្វើឱ្យគេពិបាកមើលអក្សរ ។
5. ខ្ញុំមិនចេះនិយាយសុំទោសគេទេ ព្រោះខ្ញុំខ្មាសគេ ។

មេរៀនទី

# 4 សិទ្ធិនិងការទទួលខុសត្រូវ

## 1. សិទ្ធិ



មនុស្សគ្រប់រូបមានសិទ្ធិដូចគ្នា ។ សិទ្ធិ គឺជាអ្វីៗដែលមនុស្សត្រូវតែមានជាចាំបាច់ដើម្បីរស់នៅឱ្យបានសមរម្យនិងមានតម្លៃជាមនុស្ស ។ សិទ្ធិ ជាអំពើដែលអាចធ្វើនិងមិនអាចធ្វើបាននៅក្នុងក្របខ័ណ្ឌមួយច្បាស់លាស់ និងជាការធ្វើសកម្មភាពអ្វីមួយដែលអនុវត្តឡើងដោយត្រឹមត្រូវ យុត្តិធម៌ និងសមស្របទៅតាមក្រឹត្យក្រមនៃច្បាប់ ។ ឯកុមារមានសិទ្ធិពេញលេញក្នុងការរស់នៅដើម្បីអភិវឌ្ឍកាយសម្បទាឱ្យចម្រើនលូតលាស់និងមានចំណេះដឹង ចំណេះធ្វើទៅតាមកម្រិតវ័យរបស់ពួកគេ ។ កុមារក៏ត្រូវមានសិទ្ធិទទួលបាននូវការការពារថែរក្សាទាំងផ្លូវកាយ និងផ្លូវចិត្តពីក្រុមគ្រួសារ សហគមន៍ ឱ្យបានខ្ជាប់ខ្ជួនដើម្បីធានាសុខសុវត្ថិភាព ។ ទន្ទឹមនឹងការទទួលបាននូវចំណេះដឹងនិងសុខសុវត្ថិភាពហើយនោះ កុមារត្រូវមានសិទ្ធិសេរីភាពក្នុងការចូលរួមសកម្មភាពផ្សេងៗក្នុងសហគមន៍ និងមានសេរីភាពក្នុងការបញ្ចេញគំនិតយោបល់សម្រាប់រួមចំណែកក្នុងការអភិវឌ្ឍសង្គម ។

## ២. សិទ្ធិរស់រានមានជីវិតរបស់កុមារ



មាតាបិតា អាណាព្យាបាលកុមារគ្រប់រូបតែងតែខិតខំបីបាច់ថែរក្សាកូនចៅឱ្យមានជីវិតរស់នៅបានល្អប្រសើរជានិច្ច ។ កាតព្វកិច្ចរបស់លោក គឺផ្តល់ចំណីអាហារ ផ្តល់ជម្រកសមរម្យ មើលថែរក្សាសុខភាព និងការពារសុវត្ថិភាពដល់កូនៗគ្រប់ពេលវេលា ។ កុមារទទួលបានការចាក់ថ្នាំបង្ការជំងឺនានា ការព្យាបាលជំងឺនៅពេលឈឺថ្កាត់ជាប្រចាំពីក្រុមគ្រួសារ និងគ្រូពេទ្យ ។ ពួកគេក៏ទទួលបានការរស់នៅសមរម្យដោយមានសម្លៀកបំពាក់និងជម្រកដែលអាចការពារខ្លួនជៀសផុតពីព្យុះភ្លៀង ក្តៅរងានៃអាកាសធាតុធម្មជាតិទៀតផង ។ ជាពិសេសកុមារត្រូវបានមាតាបិតាចុះបញ្ជីកំណើតតាំងពីប្រសូត្រមកដែលជាការបញ្ជាក់ពីសញ្ជាតិ ថ្ងៃ ខែ ឆ្នាំកំណើតនិងឈ្មោះពិតប្រាកដរបស់ខ្លួនច្បាស់លាស់ ។

ដូចនេះសិទ្ធិរស់រានមានជីវិតរបស់កុមារមាន :

- សិទ្ធិទទួលបានចំណីអាហារគ្រប់គ្រាន់
- សិទ្ធិមានជម្រកសមរម្យ
- សិទ្ធិទទួលបានការព្យាបាលនិងថែទាំសុខភាព
- សិទ្ធិមានឈ្មោះនិងសញ្ជាតិសមស្រប ។

## ៣. សិទ្ធិអភិវឌ្ឍន៍របស់កុមារ



សិទ្ធិអភិវឌ្ឍន៍របស់កុមារគ្រប់រូបរួមមាន សិទ្ធិទទួលព័ត៌មានសមស្របផ្សេងៗ សិទ្ធិទទួលបានការស្រឡាញ់សន្តោសប្រោសប្រណីពីមាតាបិតា ឬអាណាព្យាបាល និង សិទ្ធិទទួលបានការអប់រំ ។

កុមារគ្រប់រូបមានសិទ្ធិទទួលបានការអប់រំទាំងចំណេះដឹងនិងចំណេះធ្វើពេញលេញទៅតាមកម្រិតវ័យ ដើម្បីអភិវឌ្ឍឱ្យពួកគេក្លាយជាពលរដ្ឋល្អនិងមានលទ្ធភាពប្រកបរបរចិញ្ចឹមជីវិតក្នុងពេលអនាគត ។

ពួកគេក៏ត្រូវការលេងកំសាន្តដែរ ដើម្បីជួយពួកគេឱ្យមានការលូតលាស់ទាំងរាងកាយ ទាំងបញ្ញាក្នុងការប្រាស្រ័យទាក់ទងជាមួយមិត្តភក្តិនិងពិភពខាងក្រៅ ។

ក្រៅពីសិទ្ធិទទួលបានការអប់រំនិងលេងកម្សាន្ត ពួកគេត្រូវទទួលបាននូវសេចក្តីស្រឡាញ់ថ្នាក់ថ្នមពីក្រុមគ្រួសារនិងពីមនុស្សចាស់ដទៃទៀត ដើម្បីឱ្យពួកគេចេះចែករំលែកសេចក្តីស្រលាញ់នោះទៅដល់មិត្តភក្តិ ឬអ្នកដទៃផងដែរ ។

ដូចនេះកុមារមានសិទ្ធិទទួលថ្នាក់ថ្នមពីក្រុមគ្រួសារ ការអប់រំប្រកបដោយគុណភាព និងសិទ្ធិលេងកម្សាន្តសប្បាយ ។

## 4. សិទ្ធិចូលរួមរបស់កុមារ

កុមារត្រូវមានសេរីភាពក្នុងការគិតនិងបញ្ចេញមតិយោបល់ ដើម្បីជួយឱ្យគេចេះគិត និងសម្រេចចិត្ត ចំពោះបញ្ហាទាក់ទងនឹងការរស់នៅរបស់ពួកគេ ។ ពួកគេក៏ត្រូវចូលរួមបង្កើតក្រុម ឬសមាគមដែលត្រឹមត្រូវនៅសាលារៀន ឬនៅទីកន្លែងមានសុវត្ថិភាពផ្សេងទៀតដើម្បីជំរុញឱ្យពួកគេមានសេចក្ដីក្លាហានក្នុងការបញ្ចេញសមត្ថភាពទេពកោសល្យរបស់ពួកគេ ។ កុមារក៏មានសិទ្ធិទទួលព័ត៌មានសមស្របដែលលើកកម្ពស់ផ្នែកសុខភាព បញ្ញាស្មារតី សីលធម៌ និងសង្គមដើម្បីឱ្យពួកគេចូលរួមផ្សព្វផ្សាយបន្តបានទូលំទូលាយ ។

## 5. សិទ្ធិទទួលបាននូវការការពារ



មនុស្សដែលរស់នៅជុំវិញកុមារត្រូវនិយាយប្រាប់កុមារពីល្បិចកលដែលជនខិលខូចតែងបោកប្រាស់ លួងលោមបញ្ឆោតកុមារយកទៅរំលោភផ្លូវភេទតាមរយៈការឱ្យលុយកាក់ ឬវត្ថុផ្សេងៗជាដើម ព្រមទាំងអប់រំកុមារឱ្យចេះប្រុងប្រយ័ត្ននិងចេះការពារខ្លួនដោយខ្លួនឯង ។ ក្រុមគ្រួសារ គ្រូ និងសហគមន៍ត្រូវការពារកុមារឱ្យគេចផុតពីគ្រឿងញៀនដោយពន្យល់បង្ហាញពីផលប៉ះពាល់ដល់សុខភាព និងសន្តិសុខសង្គមនាពេលអនាគត ។ អាជ្ញាធរត្រូវការពារនិងបញ្ចៀសកុមារឱ្យរួចផុតពីពលកម្មដែលបង្កឱ្យមានបញ្ហាដល់ការលូតលាស់រាងកាយ ប្រាជ្ញា ស្មារតី អំពើហិង្សា ការប្រកាន់ពូជសាសន៍ឋានៈពណ៌សម្បុរនិងសាសនា ។

ដូចនេះកុមារគ្រប់រូបមានសិទ្ធិទទួលការការពារឱ្យរួចផុតពីការរំលោភបំពានការកេងប្រវ័ញ្ចគ្រប់រូបភាព និងការបំបែកចេញពីគ្រួសារដោយខុសច្បាប់ ។

## ៦. អ្នកទទួលខុសត្រូវក្នុងការអនុវត្តសិទ្ធិកុមារ



អ្នកទទួលខុសត្រូវលើការអនុវត្តសិទ្ធិកុមារឱ្យបានពេញលេញនិងល្អប្រពៃនោះ ចាំបាច់ត្រូវមានការចូលរួមគាំទ្រ និងអនុវត្តពីមនុស្សទាំងអស់គ្នា និងស្ថាប័នគ្រប់លំដាប់ថ្នាក់រួមមាន មាតាបិតា អាណាព្យាបាល សមាជិកក្នុងក្រុមគ្រួសារ សហគមន៍ អាជ្ញាធរមូលដ្ឋាន អាជ្ញាធរជាតិ អង្គការក្រៅរដ្ឋាភិបាល សហគមន៍អន្តរជាតិ និងកុមារខ្លួនឯង ។ មាតាបិតាឬគ្រួសារត្រូវថែទាំកុមារដោយស្រលាញ់ហើយការពារ និងផ្តល់អាហារ សម្ភារៈសមរម្យ ការអប់រំ និងការចូលរួម ។ គ្រូត្រូវផ្តល់គំរូល្អ ឱវាទល្អៗ ចំណេះដឹង ព្រមទាំងមានការលើកទឹកចិត្ត និងផ្តល់ការចូលរួមថែមទៀតដល់កុមារ ។ សហគមន៍ និងស្ថាប័ននានាត្រូវការពារ ថែទាំលើកទឹកចិត្ត និងផ្តល់ព័ត៌មានជាគំរូល្អដល់កុមារជានិច្ច ។

ការទទួលខុសត្រូវទាំងអស់នេះជាការរួមចំណែកយ៉ាងសកម្មដែលនាំឱ្យច្បាប់ស្តីពីសិទ្ធិកុមារក្លាយជាការអនុវត្តជាក់ស្តែងប្រកបដោយប្រសិទ្ធភាព ព្រោះជាការផ្តល់ផលប្រយោជន៍ដល់កុមារ ។

## 7. ការទទួលខុសត្រូវរបស់កុមារក្នុងការអនុវត្តសិទ្ធិ



ប្រទេសកម្ពុជាបានទទួលយកអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារមកអនុវត្ត ហើយតួនាទី និងការទទួលខុសត្រូវរបស់កុមារបានកើតមានឡើងជាមួយនឹងសិទ្ធិទាំងនោះ ។ ពួកគេអនុវត្តសិទ្ធិរបស់ខ្លួនហើយត្រូវទទួលខុសត្រូវលើទង្វើនៃការអនុវត្តសិទ្ធិស្របច្បាប់ទាំងនោះជានិច្ច ។ ដើម្បីរៀបចំខ្លួនឱ្យក្លាយជាពលរដ្ឋល្អមួយរូបរស់នៅប្រកបដោយការទទួលខុសត្រូវលើខ្លួនឯង ចំពោះក្រុមគ្រួសារ សាលារៀន សហគមន៍ និងសង្គមជាតិទាំងមូលកុមារត្រូវរៀនកំណត់ និងអនុវត្តតួនាទីរបស់ខ្លួនឱ្យបានសមស្របដោយជានិច្ចកាលផ្សារភ្ជាប់ការទទួលខុសត្រូវទៅនឹងសិទ្ធិដែលខ្លួនមាន ។

ដូចនេះរាល់ការអនុវត្តសិទ្ធិរបស់ខ្លួន កុមារត្រូវមានការទទួលខុសត្រូវលើការប្រើប្រាស់សិទ្ធិរបស់ខ្លួនឱ្យបានត្រឹមត្រូវ ។

### ក. ការទទួលខុសត្រូវរបស់កុមារនៅក្នុងគ្រួសារ

ការទទួលខុសត្រូវរបស់កុមារនៅក្នុងគ្រួសារ គឺត្រូវត្រងត្រាប់ស្តាប់ដំបូន្មាននិងជួយសម្រាលការងារឪពុកម្តាយ អាណាព្យាបាលតាមលទ្ធភាព និងវ័យរបស់ខ្លួន ។ កុមារត្រូវរួមចំណែកយ៉ាងសកម្មដើម្បីបង្កើនសេដ្ឋកិច្ចគ្រួសារ ដូចជាជួយសន្សំសំចៃ ចេះចែករំលែកចំណីអាហារគ្នា មិនខ្ជះខ្ជាយ ចេះសំអាតខ្លួនប្រាណឱ្យមានអនាម័យ ចេះលេងកីឡាដើម្បីសុខភាព និងចេះថែទាំសំអាតគេហដ្ឋាន ដើម្បីកាត់បន្ថយការចំណាយផ្សេងៗ ។ កុមារត្រូវជួយធ្វើកិច្ចការបងប្អូនដោយមិនមើលបំណាំគ្នា មិនបង្កជម្លោះឬបង្កការលំបាកដល់គ្រួសារ គឺធ្វើគំរូល្អនិងមានសីលធម៌រស់នៅល្អដែលជាកត្តាមួយជួយដល់ការស្តារ និងអភិវឌ្ឍន៍សង្គមជាតិ ។

## ខ. ការទទួលខុសត្រូវរបស់កុមារនៅក្នុងសាលារៀន



នៅសាលារៀនគ្រូបានផ្តល់ការប្រៀនប្រដៅល្អ ធ្វើជាគំរូល្អ និងអប់រំបណ្តុះបណ្តាលសិស្សរាល់ថ្ងៃ ។ លោកតែងលើកទឹកចិត្តនិងផ្តល់ឱកាសឱ្យកុមារចូលរួមគ្រប់សកម្មភាព ។

ដូចនេះកុមារត្រូវព្យាយាមសិក្សារៀនសូត្រ ដោយស្តាប់តាមការណែនាំពន្យល់របស់គ្រូ ត្រូវគោរពវិន័យសាលា ថែរក្សាសម្បត្តិទ្រព្យក្នុងសាលារៀន ថែរក្សាអនាម័យ និងបង្កើនសាមគ្គីភាពឱ្យទូលំទូលាយដោយចេះយោគយល់គ្នា ជួយធុរៈគ្នាទៅវិញទៅមក ។

## គ. ការទទួលខុសត្រូវរបស់កុមារនៅក្នុងសង្គម

កុមារមានសិទ្ធិចូលរួមក្នុងសកម្មភាពសង្គមជាច្រើន ហើយទន្ទឹមនឹងនេះកុមារក៏មានតួនាទី ជួយថែរក្សាសម្បត្តិសាធារណៈ ថែរក្សាប្រពៃណីទំនៀមទម្លាប់ វប្បធម៌ជាតិ បរិស្ថាន គោរពច្បាប់ ។ល។ ជាពិសេសកុមារត្រូវកសាងខ្លួនឱ្យក្លាយជាសិស្សល្អ មិត្តល្អ និងពលរដ្ឋល្អ ដើម្បីអាចរួមចំណែកការពារ និងកសាងមាតុភូមិឱ្យបានរីកចម្រើនជឿនលឿនដូចបណ្តាប្រទេសនានានៅលើពិភពលោក ។

## មេរៀនសង្ខេប

កុមារគ្រប់រូបមានសិទ្ធិ និងអនុវត្តសិទ្ធិទាំងឡាយរបស់ខ្លួនក្នុងកម្រងសិទ្ធិធំៗទាំង4 ប្រកបដោយការទទួលខុសត្រូវជានិច្ច ។

ការទទួលខុសត្រូវលើការអនុវត្តសិទ្ធិរបស់កុមារជាតម្លៃមួយដែលជាមូលដ្ឋានគ្រឹះនៃការកសាងឱ្យក្លាយជាកូនល្អ មិត្តល្អ សិស្សល្អ និងពលរដ្ឋថ្លៃថ្នូរក្នុងសង្គម ។

ការអនុវត្តសិទ្ធិដោយផ្សារភ្ជាប់នឹងការទទួលខុសត្រូវធ្វើឱ្យមានការគោរពពីអ្នកដទៃ ។ កុមារខ្លួនឯង និងអ្នកនៅជុំវិញទាំងអស់ត្រូវរួមគ្នាទទួលខុសត្រូវលើការអនុវត្តសិទ្ធិកុមារ ដើម្បីរួមចំណែកកសាងធនធានមនុស្សក្នុងសង្គមប្រកបដោយគុណភាព និងមានការទទួលខុសត្រូវដើម្បីអភិវឌ្ឍប្រទេសឱ្យសម្បូររុងរឿង ។

## សំណួរ

**ក. ចូរឆ្លើយនឹងសំណួរខាងក្រោម :**

1. តើសិទ្ធិជាអ្វី?
2. តើកុមារមានសិទ្ធិអ្វីខ្លះ ?
3. តើការទទួលខុសត្រូវរបស់កុមារក្នុងការអនុវត្តសិទ្ធិ មានអ្វីខ្លះ?
4. តើនរណាខ្លះត្រូវទទួលខុសត្រូវក្នុងការអនុវត្តសិទ្ធិរបស់កុមារ ?
5. ហេតុអ្វីបានជាកុមារត្រូវទទួលខុសត្រូវលើការអនុវត្តសិទ្ធិរបស់ខ្លួន ?

**ខ. ចូរបង្ហាញពីការទទួលខុសត្រូវរាល់ទង្វើរបស់អ្នកដែលបានធ្វើរាល់ថ្ងៃ ។**

មេរៀនទី

# 5 ការបង្កើតថ្មីនិងគំនិតច្នៃប្រឌិត

ពីជំនាន់មួយទៅជំនាន់មួយ មនុស្សតែងបង្កើតស្នាដៃថ្មីៗនិងបានច្នៃប្រឌិតស្នាដៃទាំងនោះប្រកបដោយសិល្បៈរស់រវើក ដែលជាទីទាក់ទាញចំណាប់អារម្មណ៍ ។

កុមារក៏អាចបង្កើតស្នាដៃច្នៃប្រឌិតបានដែរ ដូចជា

**ការបត់ក្រដាសបង្កើតរូប :** ដើម្បីបត់ក្រដាសបង្កើតរូប យើងត្រូវមាន ក្រដាសបន្ទាត់ ខ្មៅដៃ ខ្មៅដៃពណ៌ ជ័រលុប កន្ត្រៃ និងយល់ដឹងពីរបៀបបត់ ។

## 1. របៀបបត់ក្រដាសធ្វើពែងទឹក



ជំហានទី 1

- បត់ក្រដាសរាងការេបញ្ឆិត ឱ្យត្រួតលើគ្នាចំចំណុច "ក" និង "ខ" ដៃឆ្វេងទប់ក្រដាស ។



ជំហានទី 2

- ដៃស្តាំកាន់ជ្រុងក្រដាសខាងក្រោមបត់ទៅលើឱ្យបានជារាងត្រីកោណពីរស្មើគ្នា ។



ជំហានទី 3

- បត់ចំណុច "ឃ" ទៅប៉ះនឹងគែមជ្រុង "ខគ" ឱ្យជ្រុង "ខឃ" ដែលបត់ចោះស្របនឹងបាតត្រីកាណ ។



ជំហានទី 4

- ត្រឡប់មកម្ខាងទៀត ហើយបត់ដូចជំហានទី 3



ជំហានទី 5

- បត់ចំណុច "ក" ស៊កបញ្ចូលក្នុងថតខាងមុខ រួចបត់ចំណុច "ខ" ស៊កបញ្ចូលទៅថតខាងក្រោយ ។


ជំហានទី 6

- ច្របាច់មាត់ "កខ" ឱ្យប៉ោង ហើយសម្រួលឱ្យបានស្អាត រួចផាត់ពណ៌ ឬបិទរូបលំអ ។

## 2. របៀបបត់ក្រដាសធ្វើសត្វទីទុយ

ជំហានទី 1



បត់ក្រដាសតាមបន្ទាត់ដាច់ៗ
ឱ្យត្រួតស៊ីគ្នា រួចលាវាមកវិញ ។

ជំហានទី 2



បត់ជ្រុងខាងស្ដាំ និងជ្រុងខាងឆ្វេង
តាមគំនូសបន្ទាត់ដាច់ៗ ។

ជំហានទី 3



ដំបូងបត់ជ្រុងខាងស្ដាំ
ក្រោយមកបត់ជ្រុងខាងឆ្វេង ។

ជំហានទី 4



បត់ជ្រុងហើយទាំងសងខាង ។

ជំហានទី 5



បត់ជ្រុងខាងលើចុះមក
ក្រោមត្រឹមបន្ទាត់ដាច់ៗ ។

ជំហានទី 6



បត់ជ្រុងខាងលើចុះមក
ក្រោមបានរួចរាល់ ។

ជំហានទី 7



គូរភ្នែកលើជ្រុងដែលបត់ពីលើ
មកក្រោម ។ យើងបានសត្វទីទុយមួយ ។

# 3. របៀបបត់ក្រដាសធ្វើក្បាលសត្វចចក





ជំហានទី 1 : បត់ក្រដាស
រាងការេតាមបន្ទាត់ដាច់ៗឱ្យត្រួត
ស៊ីគ្នាបានត្រីកោណពីរស្មើគ្នា ។

ជំហានទី 2 : គូរបន្ទាត់ដាច់ៗលើជ្រុង
សងខាងនៃត្រីកោណ ។



ជំហានទី 3 : បត់ជ្រុងខាងស្តាំ
តាមគំនូសបន្ទាត់ដាច់ៗ ។



ជំហានទី 4 : បត់ជ្រុងខាងឆ្វេង
តាមបន្ទាត់ដាច់ៗ ។



ជំហានទី 5 : ត្រឡប់ជ្រុងបត់
រួចទៅក្រោយ ។



ជំហាន់ទី 6 : គូរភ្នែក ច្រមុះ មាត់ លើត្រីកោណ
បង្កើតបានមុខសត្វចចកតាមការចូលចិត្ត ។

# 4. របៀបបត់ក្រដាសធ្វើមួក




ជំហានទី 1 : បត់ក្រដាសរាងការេពីក្រោមទៅលើបាន ជាត្រីកោណពីរស្មើគ្នា ។




ជំហានទី2 : បត់ចំណុច “ ក ” មកស្តាំ។ បត់ចំណុច “ ខ ” មកឆ្វេង ។ លៃយ៉ាងណាចែកមុំ O ជាបីភាគស្មើគ្នា ។




ជំហានទី3 : បត់ចំណុច “ ខ” និងចំណុច “ក” ស្មើនឹងគែមខាងក្រោយ ។




រូបមួកបត់រួច




ជំហានទី4 : យកដៃច្របាច់មាត់ឱ្យប៉ោងបានជាមួក ។គូរឬកាត់រូបតុបតែងបិទលំអលើតួមួកតាមការចូលចិត្ត ។

# 5. របៀបបត់ក្រដាសធ្វើរូបព្រាប



បត់តាមសញ្ញាព្រួញ ។



បត់ហើយផ្កាប់ ។



បត់តាមសញ្ញាព្រួញ ។



បត់ហើយផ្កាប់បានរូប លេខ 5 ។



បត់តាមសញ្ញាព្រួញ បានរូបលេខ 6 ។



លាវិញតាមរូបព្រួញ បានរូបលេខ 7 ។



បត់តាមរូបព្រួញបាន រូបលេខ 8 ។



បង្ហើបហើយទាញ ជ្រុងទៅលើតាមរូប ព្រួញបានរូបលេខ 9



បត់ចុះក្រោមតាមរូប ព្រួញបានរូបលេខ 10 ។



បត់ជ្រុងស្រួចតាមរូប ព្រួញបានរូបលេខ 11 ។



បត់កន្ទុយឡើងហើយបត់ ចុះបានរូបលេខ 12 ។



បត់ជាពីរតាមបណ្ដោយ បានរូបលេខ 13 ។



បត់ក្បាលបញ្ចូលរួចទាញកន្ទុយ ឡើងបន្តិចបានរូបលេខ 14 ។



ទីបញ្ចប់គូររង្វង់ភ្នែក បន្ថែម ។

## ជំពូកទី

# 2 ឥរិយាបថប្រកបដោយសុវត្ថិភាព








ការប្រកាន់ឥរិយាបថល្អក្នុងការរស់នៅធ្វើឱ្យយើងទទួលបានសេចក្ដីសុខសុវត្ថិភាពក្នុងជីវិត ។ ផ្ទុយទៅវិញបើយើងប្រព្រឹត្តទង្វើទាំងឡាយណាដែលបង្កការលំបាកដល់ម្ដាយឪពុក បងប្អូនឬអ្នកដទៃនោះវានាំឱ្យយើងខាតបង់ថវិកា ខាតពេលវេលា ខូចកេរ្ដិ៍ឈ្មោះខ្លួនឯង និងគ្រួសារទៀតផង ។

មេរៀនទី

# 1 ការចៀសវាងទង្វើដែលនាំឱ្យមានគ្រោះថ្នាក់

ការរស់នៅមានភាពរីករាយ មានសេចក្ដីសុខក្នុងគ្រួសារជាបំណងប្រាថ្នារបស់យើងគ្រប់គ្នា ។ យើងគប្បីធ្វើសកម្មភាពណាដែលនាំខ្លួនយើងនិងគ្រួសារសុខចម្រើនជានិច្ច ។



## 1. គ្រឿងញៀន

គ្រឿងញៀនមានច្រើនប្រភេទនិងមានឈ្មោះខុសៗគ្នា ។ ប្រភេទគ្រាប់មានយ៉ាម៉ាយ៉ាបា ។ ប្រភេទរុក្ខជាតិញៀនមានកញ្ឆា អាភៀន និងគ្រឿងញៀនដទៃទៀតមានស្រាបារីជាដើម ។ វាគឺជាអាវុធអាចបំផ្លាញ ឬសម្លាប់យើងបាន ។ ទោះបី កុមារប្រើគ្រឿងញៀនប្រភេទណាក៏ដោយក៏វាជាការបង្កឱ្យខ្លួនឯងមានគ្រោះថ្នាក់ដោយបាត់បង់សតិ ឬបោះបង់ការសិក្សា ។ ដូចនេះដើម្បីអនាគតខ្លួនឯងនិងការគោរពច្បាប់សង្គម យើងមិនត្រូវប្រើប្រាស់ ឬសាកល្បងសេពគ្រឿងញៀនឡើយ ។ យើងត្រូវនៅឱ្យឆ្ងាយពីគ្រឿងញៀន និងត្រូវចេះឆ្លើយតបដោយសមហេតុផល បដិសេធការបបួលរបស់អ្នកដទៃឱ្យធ្វើទង្វើណាមួយពាក់ព័ន្ធជាមួយគ្រឿងញៀន ។

## 2. ផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន



គ្រឿងញៀនជាអាវុធបំផ្លាញមនុស្សគ្រប់រូប ។ វាបង្កឱ្យមានផលប៉ះពាល់ដល់អ្នកប្រើប្រាស់យ៉ាងខ្លាំង ។ ផលប៉ះពាល់ទាំងនោះ ធ្វើឱ្យយើងរងគ្រោះដូចជា ៖

- ខាតពេលវេលារៀនសូត្រអាចនឹងគេចសាលា ឬលែងចង់ចូលរៀនធ្វើឱ្យខូចអនាគត ។
- ខាតថវិកាជាច្រើន ព្រោះត្រូវចំណាយប្រាក់សម្រាប់ទិញថ្នាំញៀន ព្យាបាល និងផ្តាច់ការញៀនថ្នាំ ។
- ខូចសុខភាព ទឹកមុខស្លេកស្លាំង ភ្នែករូង គ្មានកម្លាំង បញ្ញាស្មារតីអន់ថយ ។
- ប្រើអំពើហិង្សាសម្លុតបងប្អូននិងបង្កជម្លោះ វាយដំក្នុងគ្រួសារដើម្បីទាររកប្រាក់ទៅទិញថ្នាំគ្រឿងញៀន ។
- អាចក្លាយខ្លួនជាចោរដោយហ៊ានលួច ឆក់ទ្រព្យអ្នកដទៃ ។
- ប្រឈមភាពភ័យខ្លាចគ្រប់ពេល ព្រោះរាល់សកម្មភាពរបស់ពួកគេជាអំពើខុសច្បាប់ ។ ពួកគេត្រូវជាប់ពន្ធនាគារនៅពេលដែលសមត្ថកិច្ចចាប់បាន ។

ជារួមរាល់សកម្មភាព ឬទង្វើរបស់អ្នកប្រើប្រាស់គ្រឿងញៀនជាបញ្ហាប្រកបដោយគ្រោះថ្នាក់ គួរឱ្យខ្លាច និងស្អប់ខ្ពើម ព្រោះវាបានបំផ្លាញខ្លួនឯង បំផ្លាញគ្រួសារ និងបំផ្លាញសង្គមឱ្យជួបអសន្តិសុខគ្មានការអភិវឌ្ឍ ។ ដូចនេះ យើងមិនត្រូវប្រើប្រាស់ និងលក់ដូរគ្រឿងញៀនទេ ។ ជាពិសេសយើងត្រូវដើរចេញឱ្យឆ្ងាយពីគ្រឿងញៀន ។

## ៣. គ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះ




សង្គ្រាមក្នុងប្រទេសកម្ពុជារយៈពេល3ទសវត្សរ៍បានបន្សល់ទុកនូវគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះជាច្រើនដែលធ្វើឱ្យប្រទេសក្លាយជាតំបន់មានមីនច្រើនជាងគេក្នុងចំណោមប្រទេសដែលមានបញ្ហាមីននៅលើពិភពលោក ។ គ្រឿងផ្ទុះទាំងនោះមានរូបរាងខុសៗគ្នា វាស្ថិតនៅពាសពេញដីដែលជាកន្លែងសមរភូមិប្រយុទ្ធ និងបន្ទាយទាហានចាស់ៗជាដើម ។ គ្រាប់ខ្លះកប់នៅក្នុងដីស្រែ ដីចំការ ខ្លះទៀតមាននៅលើដីដែលគេដាក់បង្កៃក្បែរគល់ឈើ និងក្នុងព្រៃ ឬនៅតាមផ្លូវ ។ គ្រាប់ទាំងអស់នោះនឹងផ្ទុះ ប្រសិនបើមានអ្វីមួយទៅប៉ះវា ។ វាអាចបំផ្លាញរាងកាយមនុស្សឱ្យពិការ ឬសម្លាប់យើងបានភ្លាមៗ ។ រៀងរាល់ថ្ងៃ មានមនុស្សចាស់ ក្មេងជាច្រើននាក់បានស្លាប់ និងពិការអស់មួយជីវិតដោយសារការផ្ទុះគ្រាប់មីន និងគ្រាប់ផ្សេងៗ ។

ចូរកុំប៉ះពាល់គ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ ឬវត្ថុផ្សេងៗទៀតដែលយើងមិនស្គាល់ថាជាអ្វី ទោះបីវាមានរូបរាង និងពណ៌គួរឱ្យស្រឡាញ់ក៏ដោយ ។

យើងត្រូវជម្រាបគ្រូ ឬមនុស្សចាស់អំពីទីកន្លែងនៃវត្ថុទាំងនោះ ។ យើងត្រូវចងចាំថា គ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះអាចបង្កមហន្តរាយគ្រប់ពេល ។

## 4. ផលវិបាកនៃគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះ



បច្ចុប្បន្នមានការផ្សព្វផ្សាយឱ្យប្រជាជនយកចិត្តទុកដាក់និងប្រុងប្រយ័ត្នរាល់ពេលឃើញឬជួបគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះ ។ តាមរបាយការណ៍របស់កាកបាទក្រហមកម្ពុជាស្ថិតិជនរងគ្រោះដោយសារមីននិង គ្រាប់មិនទាន់ផ្ទុះមានប្រមាណជា6ម៉ឺននាក់ ក្នុងនោះ 75% ត្រូវពិការបាត់បង់កម្លាំងពលកម្មនិង 25% ទៀតត្រូវបាត់បង់អាយុជីវិត ។ គ្រោះថ្នាក់ទាំងអស់នេះបណ្តាលមកពីការដំ វាយ ដុត អារ ច្នៃគ្រឿងផ្ទុះទៅធ្វើជារបស់របរផ្សេងៗ ការគប់ចោលគ្រឿងផ្ទុះធ្វើជាល្បែងលេងកម្សាន្ត ការយកគ្រឿងផ្ទុះទៅទុកក្នុងលំនៅស្ថាន ការប្រើម៉ាស៊ីនរាវរកគ្រឿងផ្ទុះដែលកប់នៅក្នុងដី និងជីកកកាយយកគ្រឿងផ្ទុះ ការដឹកជញ្ជូនគ្រឿងផ្ទុះតាមរទេះ ម៉ូតូ រថយន្តគ្មានសុវត្ថិភាព ការយកគ្រាប់មិនទាន់ផ្ទុះទៅធ្វើជាឧបករណ៍ចាប់ត្រីខុសច្បាប់ ការដើរឆ្លងកាត់ស្លាកសញ្ញាតំបន់មានមីន និងមានគ្រាប់មិនទាន់ផ្ទុះជាដើម ។

យើងទាំងអស់គ្នាត្រូវយល់ថា គ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះជាឃាតករអាចសម្លាប់មនុស្ស សត្វ និងបំផ្លាញទ្រព្យសម្បត្តិ ។

## ៥. ល្បែងភ្នាល់





សង្គមបានចាត់ទុកថា " ល្បែងភ្នាល់ស៊ីសងជាអំពើអបាយមុខឬអំពើពាលា និងថោកទាប" ។

មានពាក្យចាស់តំណាលថា " លោកថាឆ្កួតបី ឆ្កួតមួយនឹងស្រី ឆ្កួតមួយនឹងស្រា ឆ្កួតមួយនឹងល្បែង អំពើពាលា ឆ្កួតនោះហៅមហា ឆ្កួតក្រៃកន្លង" ។

អំពើអបាយមុខមានច្រើនប្រភេទដូចជា បៀ កន្ទុយលេខ អាប៉ោង យោគីឡូតូ ជល់មាន់... ។

អ្នកខ្លះបានយកកីឡាមួយចំនួនដូចជា បាល់ទះ បាល់ទាត់ ប្រដាល់ និង ល្បែងផ្សេងៗទៀតដូចជាល្បែងចត្រង្គ (អុក) ព្រមទាំងល្បែងនានាតាមកុំព្យូទ័រមកភ្នាល់ស៊ីសងដែរ ។ ការធ្វើបែបនេះ ជាអំពើមិនត្រឹមត្រូវ ខុសច្បាប់ដែលសង្គមបានហាមឃាត់ ។

អ្នកលេងល្បែងភ្នាល់ជាជនមិនគោរពខ្លួនឯង និងមិនគោរពច្បាប់ ។ ចូរចៀសឱ្យឆ្ងាយពីល្បែងភ្នាល់គ្រប់ប្រភេទ ។ ចូរកុំចូលរួមលេងល្បែងភ្នាល់ទាំងនោះ ។

## ៦. ផលវិបាកនៃការលេងល្បែងភ្នាល់



ល្បែងភ្នាល់មានច្រើនប្រភេទ ។ អ្នកដែលប្រព្រឹត្តល្បែងភ្នាល់ស៊ីសងមានគុណវិបត្តិច្រើនណាស់សម្រាប់ខ្លួនឯងនិងសង្គម ។ អ្នកលេងល្បែងភ្នាល់ខាតបង់ពេលវេលាក្នុងការប្រកបការងារចិញ្ចឹមជីវិត ធ្វើឱ្យសេដ្ឋកិច្ចគ្រួសារបាត់លំនឹង និងឈានទៅរកភាពក្រីក្រ បាត់បង់ពេលវេលារៀនសូត្រ បំផ្លាញទ្រព្យសម្បត្តិគ្រួសារ ម្ដាយឪពុក ហើយអាចក្បត់ចិត្តក្រុមគ្រួសារដោយហ៊ានកុហកបោកប្រាស់ដើម្បីបានប្រាក់យកទៅលេងល្បែង ។

អ្នកលេងល្បែងគ្មានមិត្តល្អ គ្មានកិត្តិយស និងជាអ្នកចូលចិត្តបង្កទំនាស់ជាច្រើនដោយសារតែបញ្ហាប្រាក់សម្រាប់លេងល្បែង ។ ពួកគេអាចប្រព្រឹត្តអំពើចោរកម្មឃាតកម្មដែលជាហេតុធ្វើឱ្យមានអំពើហិង្សា និងអសន្តិសុខសង្គម ។

ម្យ៉ាងទៀតល្បែងភ្នាល់ជាអំពើល្មើសច្បាប់ អ្នកលេងត្រូវមានទោស ។ យើងមិនត្រូវលេងល្បែងភ្នាល់ទេ ព្រោះល្បែងភ្នាល់នាំឱ្យវិនាស ។ ដូចនេះមានតែការសិក្សាប៉ុណ្ណោះដែលធ្វើឱ្យខ្លួនយើងមានការរីកចម្រើន និងមានអនាគតល្អ ។

ដើម្បីចៀសផុតពីល្បែងភ្នាល់ យើងត្រូវខិតខំរៀនសូត្រគោរពវិន័យនិងបទបញ្ជាសាលារៀន ជួយកិច្ចការក្នុងគ្រួសារ ធ្វើលំហាត់ប្រាណ និងសម្រាកលំហែកម្សាន្តដើម្បីសុខភាព ។

## ៧. ការឆ្លើយបដិសេធនិងវិធីការពារខ្លួនទៅនឹងការបបួល

### ក. ការបបួលប្រកបដោយគ្រោះថ្នាក់

ការឆ្លើយបដិសេធនឹងការបបួលរបស់អ្នកដទៃក្នុងទង្វើដែលនាំឱ្យមានគ្រោះថ្នាក់ជាមធ្យោបាយល្អមួយដែលអាចនាំយើងរួចផុតពីគ្រោះថ្នាក់ និងល្បិចកលនៃជនខិលខូចមួយចំនួន ។ នៅពេលឆ្លើយបដិសេធ យើងគប្បីលើកហេតុផល ឬពន្យល់ពីមូលហេតុផ្សេងៗដើម្បីឱ្យអ្នកបបួលមានអារម្មណ៍ស្ងប់មិនប្រកាន់ខឹងនឹងយើង ។

ប្រសិនបើមានជនណាមកបបួលយើងនៅកន្លែងស្ងាត់ វិធីឆ្លើយបដិសេធ គឺនិយាយថា " ទេ " រួចប្រញាប់គេចវេះចេញឱ្យឆ្ងាយពីអ្នកបបួល ឬរត់ទៅរកអ្នកដែលអាចជួយយើងបាន ។ វិធីបែបនេះជាការបដិសេធដែលនាំឱ្យយើងរួចផុតពីការបបួល និងនាំមកនូវសុវត្ថិភាពសម្រាប់ខ្លួនយើង ។

### ខ. ការបដិសេធប្រកបដោយសុវត្ថិភាពសម្រាប់កុមារ

ការបដិសេធប្រកបដោយសុវត្ថិភាពមានច្រើនដូចជា ៖

- សូមទោសលោកពូ ! ថ្ងៃនេះខ្ញុំត្រូវវេនបោសសំអាតថ្នាក់ ។ ដូចនេះ ខ្ញុំត្រូវប្រញាប់ទៅសាលារៀនឱ្យទាន់ពេល ។ ក្មួយសុំជម្រាបលាលោកពូសិនហើយ ។

- ខ្ញុំសុំទោស! ខ្ញុំមិនបានទៅជាមួយទេ ព្រោះថ្ងៃនេះមានកិច្ចការនៅឯផ្ទះ ។ ប៉ុន្តែពួកយើងមិនត្រូវទៅលេងទីនោះទេ ព្រោះខ្ញុំឃើញមានសញ្ញាហាមឃាត់មិនឱ្យមនុស្សដើរចូល ឬឆ្លងកាត់ ។ ពួកយើងគួរតែត្រឡប់ទៅផ្ទះដើម្បីមើលមេរៀន ឬជួយធ្វើការងារម្ដាយឪពុកយើងវិញ ។

- អត់ទេអ្នកមីង! ខ្ញុំមិនចូលលេងល្បែងនោះទេ ។ ម៉ែពុក និងលោកគ្រូ អ្នកគ្រូខ្ញុំបានប្រាប់ និងផ្ដាំថារាល់ពេលចេញពីសាលារៀនមិនត្រូវទៅណាផ្ដេសផ្ដាសទេ ។ ខ្ញុំសុំលាអ្នកមីងសិនហើយ ព្រោះម្ដាយខ្ញុំនៅចាំឯផ្ទះ ។

**មេរៀនសង្ខេប**

សុវត្ថិភាពជាវិធីសន្តិភាពសម្រាប់ជីវិតរស់នៅរបស់មនុស្សគ្រប់រូប ។ យើងមិនត្រូវចូលរួមធ្វើទង្វើណាដែលបង្កឱ្យមានគ្រោះថ្នាក់ទេ ។ កាលណាយើងមានរបួស ឬមានគ្រោះថ្នាក់នោះវាធ្វើឱ្យយើងខាតពេលវេលារៀនសូត្រ និងខាតបង់ថវិកាគ្រួសារ ។ ម្យ៉ាងទៀតយើងមិនត្រូវតាមការបបួលរបស់អ្នកដទៃឱ្យធ្វើអំពើខុសនឹងច្បាប់ឡើយ ដោយធ្វើតាមការទូន្មានប្រៀនប្រដៅរបស់ម្ដាយឪពុក អ្នកគ្រូលោកគ្រូ ដើម្បីក្លាយខ្លួនជាកូនល្អ សិស្សល្អ និងមិត្តល្អ ។ យើងត្រូវចៀសវាងរាល់សកម្មភាព ឬទង្វើទាំងឡាយណាដែលខុសច្បាប់ ។

## សំណួរ

**ក. ចូរគូសសញ្ញា ✓ក្នុងប្រអប់ខាងមុខចម្លើយណាដែលត្រឹមត្រូវ ។**

1. គ្រឿងញៀនមានប្រភេទ

☐ ក. កាវ ☐ ខ. រុក្ខជាតិ ☐ គ. គ្រាប់និងរុក្ខជាតិ ។

2. នៅពេលជួបគ្រាប់មិនទាន់ផ្ទុះយើងត្រូវ

☐ ក. ចាប់កាន់ ☐ ខ. ឈរមើល ☐ គ. ប្រាប់អាជ្ញាធរ ។

3. អ្នកលេងល្បែងភ្នាល់ភាគច្រើនជាមនុស្ស

☐ ក. មានមិត្តច្រើន ☐ ខ. មិនគោរពច្បាប់ ☐ គ. ខូចចិត្ត ។

**ខ. ចូរឆ្លើយនឹងសំណួរខាងក្រោម :**

1. តើការប្រើប្រាស់គ្រឿងញៀនបង្កការលំបាកដូចម្ដេចខ្លះ ?
2. ហេតុអ្វីបានជាអ្នកមិនត្រូវដើរកាត់តំបន់មានមីននិងគ្រាប់មិនទាន់ផ្ទុះ ?
3. តើល្បែងភ្នាល់បង្កផលវិបាកដល់ខ្លួនឯង គ្រួសារ និងសង្គម ដូចម្ដេចខ្លះ ?
4. ហេតុអ្វីយើងត្រូវឆ្លើយ " ទេ " នៅពេលគេបបួលឱ្យលេងល្បែងភ្នាល់ ?

មេរៀនទី

# 2 ការរក្សាសុវត្ថិភាពនៅពេលដើរនិងពេលជិះកង់

ការរក្សាសុវត្ថិភាពនៅពេលធ្វើដំណើរបាននាំមកនូវភាពសុខសាន្តដល់ខ្លួនឯង និងអ្នកដំណើរផ្សេងៗ ។ ដើម្បីធានាសុវត្ថិភាពនៅពេលធ្វើដំណើរ តើយើងត្រូវធ្វើដូចម្តេចខ្លះ ?

## 1. ឥរិយាបថល្អនៅពេលធ្វើដំណើរទៅសាលារៀន



ការរក្សាសុវត្ថិភាពនៅពេលធ្វើដំណើរជាសកម្មភាពសំខាន់ដែលកុមារគ្រប់គ្នាត្រូវប្រកាន់ខ្ជាប់ជានិច្ច ។ ដើម្បីធានាសុវត្ថិភាព រាល់ពេលធ្វើដំណើរទៅសាលារៀន កុមារត្រូវប្រកាន់ឥរិយាបថដូចជា ៖

- ដើរលើចិញ្ចើមផ្លូវនិងប្រកាន់ស្តាំជានិច្ច ។
- ដើរឆ្លងផ្លូវតាមគំនូសកាត់ទទឹងទ្រូងផ្លូវ ដោយគោរពតាមភ្លើងសញ្ញាចរាចរណ៍
- ដើរកាន់ដៃមនុស្សធំនៅពេលឆ្លងផ្លូវធំៗ ឬផ្លូវជាតិ ។
- មុនពេលដើរឆ្លងផ្លូវត្រូវងាកមើលខាងឆ្វេងដៃ លុះដើរបានពាក់កណ្តាលទ្រូងផ្លូវ ត្រូវមើលខាងស្តាំ និងគោរពតាមភ្លើងសញ្ញាចរាចរណ៍
- មិនដើរលើទ្រូងផ្លូវនិងមិនរត់ប្រវ៉ៀងគ្នាតាមដងផ្លូវ ។

## 2. ផ្លូវទៅសាលារៀនដែលមានសុវត្ថិភាព




ដើម្បីធានាសុវត្ថិភាពក្នុងការធ្វើដំណើរទៅសាលារៀន កុមារគួរជ្រើសរើសផ្លូវដើរតាមស្ថានភាពរស់នៅជាក់ស្ដែងឱ្យបានត្រឹមត្រូវ ។ នៅទីក្រុងផ្លូវដែលអាចរក្សាសុវត្ថិភាពបានល្អ គឺផ្លូវដែលមានចរាចរណ៍មិនសូវកកស្ទះជាផ្លូវមានគំនូសកាត់ទទឹងផ្លូវសម្រាប់ថ្មើរជើងឆ្លងកាត់ ជាផ្លូវដែលមានភ្លើងចរាចរណ៍និងជាផ្លូវមានចិញ្ចើមដែលអាចដើរបានផង ។

នៅជនបទកុមារគួរដើរតាមផ្លូវលំក្នុងភូមិដែលជាផ្លូវកាត់ពីផ្ទះទៅសាលារៀន ព្រោះវាជាផ្លូវគ្មានរថយន្តឆ្លងកាត់ទៅមកហើយអាចធ្វើឱ្យយើងដើរឆាប់ដល់សាលារៀននិងមានសុវត្ថិភាពចរាចរណ៍ផង ។ ពិសេសកុមារអាចដើរតាមផ្លូវសម្រាប់ថ្មើរជើង ព្រោះគ្មានយានយន្ត ម៉ូតូបើកបរ និងដើរតាមផ្លូវដែលមានស្ពានឆ្លងកាត់ស្ទឹង អូរត្រឹមត្រូវ ។

ក្រៅពីនេះ កុមារត្រូវមានស្មារតីប្រុងប្រយ័ត្នរាល់ពេលធ្វើដំណើរដូចជា ដើរមិនប្រលែងគ្នា ត្រូវដើរលើចិញ្ចើមផ្លូវ គោរពភ្លើង និងផ្លាកសញ្ញាចរាចរណ៍ ។ នៅពេលធ្វើដំណើរយប់ងងឹតត្រូវប្រើភ្លើង ឬសម្ភារៈដែលមានពណ៌ចាំង ដើម្បីឱ្យអ្នកធ្វើដំណើរដទៃមើលឃើញយើង ។

## ៣. សុវត្ថិភាពក្នុងការជិះកង់

### ក. ការជ្រើសរើសផ្លូវក្នុងការជិះកង់

ដើម្បីរក្សាសុវត្ថិភាពនៅពេលជិះកង់ យើងត្រូវជិះកង់នៅចិញ្ចើមផ្លូវ អែបខាងស្ដាំជិតកន្លែងថ្មើរជើង ជាពិសេសត្រូវជិះនៅលើផ្លូវសម្រាប់ទោចក្រយាន ។ យើងមិនត្រូវជិះកង់លើទ្រូងផ្លូវឬជិះពេញផ្លូវដែលនាំឱ្យរំខានដល់ចរាចរណ៍ផ្លូវនោះទេ ។ កុមារគួរចៀសវាងក្នុងការជិះកង់លេងតាមផ្លូវសាធារណៈ ព្រោះវាអាចបណ្ដាលឱ្យមានគ្រោះថ្នាក់ដោយសារយានជំនិះបើកបរលើផ្លូវមកប៉ះទង្គិច ។

### ខ. កិច្ចការពារខ្លួនក្នុងពេលជិះកង់

កុមារជាច្រើនចូលចិត្តជិះកង់លេងកម្សាន្តនិងជិះទៅសាលារៀន ។ ពួកគេត្រូវរៀបចំខ្លួនឱ្យបានត្រឹមត្រូវនៅមុនពេលជិះកង់ និងពេលជិះកង់ដើម្បីធានាសុវត្ថិភាពបានល្អដូចជា មុនពេលជិះកង់ត្រូវត្រួតពិនិត្យមើលកង់ ចង្កៀងកង់ ភ្លើង ហ្វ្រាំង កណ្ដឹង និងច្រវាក់ជាដើម ។ បន្ទាប់មកត្រូវពាក់មួកសុវត្ថិភាពការពារក្បាល ។ យើងត្រូវរើសយកកង់ដែលសមល្មមនឹងកម្ពស់របស់ខ្លួន ពោលគឺអាចដាក់ជើងដល់ដី ។ ពេលជិះត្រូវគោរពច្បាប់ ផ្លាក និងភ្លើងសញ្ញាចរាចរណ៍ និងប្រុងប្រយ័ត្នចំពោះយានយន្តគ្រប់ប្រភេទព្រមទាំងធ្វើតាមការទូន្មានរបស់ចាស់ៗ ។

### គ. របៀបជិះកង់បត់ឆ្វេង បត់ស្ដាំប្រកបដោយសុវត្ថិភាព

ក្នុងពេលកំពុងជិះកង់ប្រសិនបើយើងចង់បត់ឆ្វេងយើងត្រូវលើកដៃឆ្វេងជាសញ្ញាសុំផ្លូវដល់អ្នកខាងក្រោយ ។ ប្រសិនបើយើងចង់បត់ស្ដាំត្រូវលើកដៃស្ដាំជាសញ្ញា រួចមើលទៅទិសដែលត្រូវបត់បន្ទាប់មកមើលទិសត្រូវជិះ ។ បើគ្មានចរាចរណ៍ទើបយើងជិះឆ្លងបាន ឬបត់បាន ។ អ្នកជិះកង់ត្រូវចៀសវាងសកម្មភាពមួយចំនួនដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ដូចជាជិះនៅកណ្ដាលទ្រូងផ្លូវ ជិះប្រឡែងគ្នា ជិះទន្ទឹមគ្នា ជិះកាច់ចង្កូតវេរពេញផ្លូវជាដើម ។ ដើម្បីរក្សាសុវត្ថិភាពយើងត្រូវជិះកង់យឺតៗហើយជិះអែបខាងស្ដាំដៃតាមចិញ្ចើមផ្លូវ ។

## 4. គ្រោះថ្នាក់ផ្សេងៗដែលតែងកើតចំពោះថ្មើរជើងនិងអ្នកជិះកង់

ចូរចម្លងតារាងខាងក្រោមនេះ ចូលក្នុងសៀវភៅរបស់អ្នករួចគូសសញ្ញា (✓) នៅពីក្រោយល្បះនីមួយៗដើម្បីបង្ហាញពីគ្រោះថ្នាក់ដែលបានកើតមានលើអ្នកថ្មើរជើង និងអ្នកជិះកង់ ។

| ខ្លឹមសារ ឬសកម្មភាព | សម្រេចតាម | មិនសម្រេចតាម |
|---|---|---|
| ខ្ញុំយល់ថា ការធ្វើដំណើរមិនប្រកាន់ស្តាំនាំឱ្យងាយប៉ះទង្គិចគ្នានិងអាចកើតជាទំនាស់ ឬគ្រោះថ្នាក់ផ្សេងៗ ។ | | |
| ខ្ញុំឃើញអ្នកជិះកង់មានគ្រោះថ្នាក់ មកពីមិនគោរពភ្លើងសញ្ញានិងច្បាប់ចរាចរណ៍នៅពេលជិះកង់ ។ | | |
| ខ្ញុំគិតថា អ្នកថ្មើរជើងត្រូវដើរលើចិញ្ចើមផ្លូវ កាលណាយើងមិនគោរពច្បាប់នេះនឹងនាំឱ្យមានគ្រោះថ្នាក់ដល់ខ្លួន ។ | | |
| ខ្ញុំយល់ថា អ្នកជិះកង់មានគ្រោះថ្នាក់របួសក្បាលច្រើនមកពីពួកគេមិនពាក់មួកការពារក្បាលនៅពេលជិះកង់ ។ | | |
| ខ្ញុំឃើញថា អ្នកថ្មើរជើងភាគច្រើនបើមិនបានមើលឆ្វេងស្តាំមុនពេលឆ្លងផ្លូវទេនោះគ្រោះថ្នាក់នឹងអាចកើតមានដល់ខ្លួនមិនខាន ។ | | |
| យានយន្តជាច្រើនមានម៉ូតូ រថយន្តតូចធំ រថយន្តដឹកទំនិញដែលបើកបរដោយល្បឿនលឿនអាចមកប៉ះទង្គិចអ្នកជិះកង់បណ្តាលឱ្យមានគ្រោះថ្នាក់ បាក់ដៃបាក់ជើងហើយជួនកាលរហូតដល់បាត់បង់ជីវិតក៏មាន ។ | | |
| ការជិះកង់ទន្ទឹមគ្នា ឬជិះប្រណាំងគ្នា ជិះមិនអែបខាងស្តាំជាហេតុនាំឱ្យមានគ្រោះថ្នាក់បំផុត ។ | | |

## មេរៀនសង្ខេប

ការមិនប្រុងប្រយ័ត្នក្នុងពេលធ្វើដំណើរ គ្រោះថ្នាក់ចរាចរណ៍នឹងអាចកើតមានឡើងគ្រប់ពេល ចំពោះអ្នកថ្មើរជើង និងអ្នកជិះកង់ ។ ដើម្បីចៀសវាងគ្រោះថ្នាក់ផ្សេងៗអ្នកថ្មើរជើង ឬអ្នកជិះកង់ត្រូវគោរពច្បាប់ចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍ ផ្លាកសញ្ញាចរាចរណ៍ឱ្យបានខ្ជាប់ខ្ជួន ។ ការគោរពច្បាប់ចរាចរណ៍បានត្រឹមត្រូវ នឹងនាំមកនូវសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ។

## សំណួរ

**ក. ចូរគូសសញ្ញា(✓) ក្នុងប្រអប់ពីមុខខ្លឹមសារណាដែលអ្នកយល់ថាមិនបង្កឱ្យមានគ្រោះថ្នាក់ ។**

1. កុមារអាចរត់លេងបាននៅតាម

☐ ក. ផ្លូវសាធារណៈ ☐ ខ. ទីធ្លាក្នុងរបង ☐ គ. កន្លែងជិតផ្លូវ ។

2. ពេលធ្វើដំណើរអ្នកជិះកង់ត្រូវ

☐ ក. ជិះកណ្តាលផ្លូវ ☐ ខ. ជិះជិតចិញ្ចើមផ្លូវប្រកាន់ស្តាំ

☐ គ. ជិះតាមចិត្ត ។

**ខ. ចូរឆ្លើយនឹងសំណួរខាងក្រោម :**

1. ដើម្បីឱ្យមានសុវត្ថិភាពនៅពេលធ្វើដំណើរទៅសាលារៀន តើយើងត្រូវជ្រើសរើសផ្លូវដើរដូចម្តេច ?
2. នៅពេលធ្វើដំណើរឆ្លងផ្លូវ តើយើងត្រូវធ្វើដូចម្តេចខ្លះ?
3. តើការជិះកង់របៀបណាដែលមិនបង្កឱ្យមានគ្រោះថ្នាក់ដល់ខ្លួន និងអ្នកដទៃ ?
4. តើមួកសុវត្ថិភាពត្រូវពាក់នៅពេលណា ? ដើម្បីអ្វី ?
5. តើមូលហេតុអ្វីខ្លះដែលនាំឱ្យមានគ្រោះថ្នាក់ដល់អ្នកធ្វើដំណើរ ?

ជំពូកទី

# 3 ជីវភាពសង្គមបច្ចុប្បន្ន







ព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្នមានប្រជាពលរដ្ឋរស់នៅ ប្រកបដោយភាពសុខសាន្ត និងសន្តិភាព ។ ពួកគេប្រកបរបរចិញ្ចឹមជីវិតផ្សេងៗគ្នាទៅតាមស្ថានភាពបរិស្ថានធម្មជាតិ និងជំនាញរៀងៗខ្លួន ហើយប្រតិបត្តិទំនៀមទម្លាប់ប្រពៃណី និងវប្បធម៌ជាតិខ្លួនបានដ៏ល្អប្រពៃណាស់ ។

មេរៀនទី

# 1 ការថែរក្សាចម្រៀងនិងរបាំខ្មែរ

ចម្រៀងនិងរបាំខ្មែរជាសម្បត្តិវប្បធម៌របស់ប្រទេស ។ ព្រះរាជាណាចក្រកម្ពុជាមានសម្បត្តិវប្បធម៌ច្រើនអនេក ។ ដើម្បីឱ្យសម្បត្តិវប្បធម៌ខ្មែរនៅគង់វង្ស តើយើងត្រូវធ្វើដូចម្ដេចខ្លះ ?

## 1. យើងរៀនច្រៀង

### បទសុរិយាល្ងាចថ្ងៃ (បទមហោរី)



| | | |
|---|---|---|
| សុរិយាល្ងាចថ្ងៃ | សុរិយាល្ងាចថ្ងៃ | (2ដង) |
| ទន្សោងគោព្រៃ | រកស៊ីជើងភ្នំ | (2ដង) ។ |
| ស៊ីតូចដោយតូច | ស៊ីធំដោយធំ | (2ដង) |
| រកស៊ីជើងភ្នំ | ផឹកទឹកដងអូរ | (2ដង) ។ |
| លុះផឹករួចហើយ | បញ្ចូល់គ្នាវរ | (2ដង) |
| សុទ្ធតែឡើងក | អួតអាងកម្លាំង | (2ដង) ។ |

## 2. យើងរៀនរាំចង្វាក់សារ៉ាវ៉ាន់

### ក. របៀបរាំ

សារ៉ាវ៉ាន់ គឺជាចង្វាក់ដែលប្រជាពលរដ្ឋខ្មែរចូលចិត្តរាំលេងកម្សាន្តគ្រប់ៗគ្នា ។ ចង្វាក់សារ៉ាវ៉ាន់មានពីរវគ្គ (ឆ្វេងស្តាំ ទៅមុខ ថយក្រោយ) ក្នុងមួយវគ្គៗមានក្បាច់ ដៃ ជើង ដងខ្លួន និងក្បាលរួមផ្សំគ្នា ។

វគ្គទី 1 : មាន 4 ដំណាក់

**ដំណាក់ទី 1**
ឈានជើងស្តាំទៅមុខជើងឆ្វេង ដៃទាំងពីររលាស់នៅចំហៀងខ្លួន ។

**ដំណាក់ទី 2**
ឈានជើងឆ្វេងទៅមុខ ជើងស្តាំបន្ត ដៃទាំងពីររលាស់មកមុខបន្តិច ។



**ដំណាក់ទី 4**
គោះកែងជើងឆ្វេងបញ្ចិតពីមុខ ជើងស្តាំ ដៃទាំងពីររលាស់ខ្វែងគងលើគ្នា ។

**ដំណាក់ទី 3**
ឈានជើងស្តាំទៅមុខ ជើងឆ្វេងបន្តទៀត ដៃទាំងពីររលាស់ត្រង់ ។

វគ្គទី2 : មាន4ដំណាក់



**ដំណាក់ទី1** : ឈានជើងឆ្វេងមកក្រោយ ជើងស្ដាំ ដៃទាំងពីររលាស់ទៅមុខត្រង់ ។



**ដំណាក់ទី2** : ឈានជើងស្ដាំមកក្រោយ ជើងឆ្វេងបន្ត ដៃទាំងពីររលាស់លាមក ចំហៀងបន្តិច ។



**ដំណាក់ទី3** : ឈានជើងឆ្វេងមកក្រោយ ជើងស្ដាំបន្ត ដៃទាំងពីររលាស់មកចំហៀង បន្តិច ។



**ដំណាក់ទី4** : គោះកែងជើងស្ដាំបញ្ឆិត មកមុខជើងឆ្វេង ដៃទាំងពីររលាស់ មកចំហៀងខ្លួន ។

## ១. អនុវត្តរាំចង្វាក់សារ៉ាវ៉ាន់





ចង្វាក់សារ៉ាវ៉ាន់ជាលំនាំបទនៃរបាំខ្មែរ ។ ប្រជាជនខ្មែរគ្រប់រូបទាំងក្មេងចាស់ប្រុសស្រីចូលចិត្តរាំចង្វាក់សារ៉ាវ៉ាន់តាមបែបជ្រំជើង ព្រោះងាយរាំ និងជាចង្វាក់ញាក់មួយបែបដែលធ្វើឱ្យអារម្មណ៍រីករាយ កាយវិការរហ័សរហួន និងរស់រវើក ។ ភាគច្រើនគេរាំចង្វាក់សារ៉ាវ៉ាន់តាមបែបឈានជើងទៅមុខ ថយក្រោយ និងគោះកែងមួយនៅលើឆាកព្រោះងាយស្រួលឱ្យទស្សនិកជនមើលអ្នករាំ ។

## ៣. យើងរៀនច្រៀងបទ“ បទចៅដួង ”

(បទភ្លេងមហោរី)



ឱចៅដួងភ្ញួងផ្កាបុប្ផាមាស អើយសែនវិសាលសុគន្ធរកផ្ទឹមគ្មាន ។
បុប្ផជាតិឃ្លាតធ្លាក់សួគ៌វិមាន ចិន្តាស្មានមេត្រីដោយក្តីស្ម័គ្រ ។
ក្រងថ្កុលជារំយោលជរសំយុង រំដួលប្រុងក្រងជាសង្វារពាក់ ។
រ័ត្ននារីមានឆោមវិល័យលក្ខណ៍ អាចទាញទាក់ចិត្តប្រុសដក់ជាប់អើយ ។

## 4. អត្ថន័យនៃក្បាច់របាំខ្មែរ

តើកាយវិការនៃក្បាច់របាំខ្មែរមានន័យដូចម្ដេចខ្លះ ?



មេរៀនទី

# 2 ពិធីបុណ្យប្រពៃណីជាតិ

បុណ្យប្រពៃណីជាតិខ្មែរយើងមានតាំងពីយូរលង់រៀងមក ហើយត្រូវបានប្រជាពលរដ្ឋអនុវត្តខ្ជាប់ខ្ជួនពីជំនាន់មួយទៅជំនាន់មួយទៀត ។ ការប្រារព្ធពិធីបុណ្យប្រពៃណីជាតិបានផ្តើមចេញពីគ្រួសារ សហគមន៍ ដើម្បីថែរក្សាអ្វីដែលចាស់ៗជំនាន់មុនបានធ្វើ ។

## 1. បុណ្យភ្ជុំបិណ្ឌ

- តើគេធ្វើបុណ្យភ្ជុំបិណ្ឌនៅថ្ងៃណា ខែណា ?




បុណ្យភ្ជុំបិណ្ឌជាពិធីបុណ្យប្រពៃណីជាតិតាមបែបពុទ្ធសាសនា ។ កាលពីសម័យដើមបុណ្យនេះគេប្រារព្ធធ្វើចាប់ពីថ្ងៃទី1 រោច ខែអាសាធពេលចូលវស្សា រហូតដល់ថ្ងៃទី 15 កើតខែអស្សុជពេលចេញវស្សា មានរយៈពេលបីខែ ។ បច្ចុប្បន្នបុណ្យភ្ជុំចាប់ផ្តើមធ្វើនៅថ្ងៃទី1 រោចដល់ថ្ងៃទី 15 រោចខែភទ្របទ គឺមានរយៈពេល 15 ថ្ងៃប៉ុណ្ណោះ ។ បុណ្យភ្ជុំបិណ្ឌគេចែកជាពិធីដាក់បិណ្ឌ ឬហៅថាកាន់បិណ្ឌមានរយៈពេល 14 ថ្ងៃដោយគិតចាប់ពីថ្ងៃទី 1 រោច រហូតដល់ថ្ងៃទី 14 រោច ។ លុះដល់ថ្ងៃទី 15 រោចខែភទ្របទដដែលគេហៅថាបុណ្យភ្ជុំបិណ្ឌ ។ ថ្ងៃនោះពុទ្ធបរិស័ទនៅគ្រប់ទិសទីទៅជួបជុំគ្នាតាមភូមិឋានរៀងខ្លួនៗនិងនាំយកចង្ហាន់ និងទេយ្យទានទៅប្រគេនព្រះសង្ឃនៅវត្តដើម្បីឆ្លងបុណ្យ ។

- គោលបំណងបុណ្យភ្ជុំបិណ្ឌ

ពិធីបុណ្យភ្ជុំបិណ្ឌមានអត្ថន័យ និងមានទំនាក់ទំនងរវាងមនុស្សដែលនៅរស់នឹងបុព្វការីជនរបស់ខ្លួនដែលបានចែកឋានទៅហើយ ។ គោលបំណងនៃពិធីបុណ្យនេះ ឧទ្ទិសកុសលនិងចំណីអាហារដល់សាច់សារលោហិតដែលបានចែកឋានទៅ ។ ពាក្យ បិណ្ឌមានន័យថា "**ដុំបាយ ឬពំនូតបាយ**" ដែលគេឧទ្ទិសដល់អ្នកដែលស្លាប់ ។ បាយបិណ្ឌ គឺជាពំនូតបាយដំណើបលាយជាមួយខ្ទិះដូង និងគ្រឿងផ្សំសណ្តែកបាយលីង ។ គេតែងរៀបចំបាយបិណ្ឌដាក់ក្នុងថាស ឯបាយបិត្តបូរដាក់ចំកណ្តាលថាស ។ បាយបិត្តបូរ ដូចជាបាយបិណ្ឌដែរគ្រាន់តែគេពូនបាយនោះឱ្យមានរាងជាសាជី ហើយគ្របស្លឹកចេកពីលើ ។ គេដោតទៀន ធូបនៅលើកំពូលនៃបាយបិត្តបូរ ។ គេរៀបចំផ្កាបិណ្ឌជាតង្វាយចំពោះព្រះចូឡាមណីចេតិយរបស់ព្រះសម្មាសម្ពុទ្ធ ។ ផ្កាបិណ្ឌគេរៀបចំនៅក្នុងរោង ផ្កានោះគេរៀបមានរាងមូលដូចសាជីដែរ ។ លើកំពូលផ្កាបិណ្ឌគេធ្វើរូបហង្សទ្រទៀនដែលគេពូនរាល់យប់នៅពេលកាន់បិណ្ឌ ។

- ជំនឿក្នុងពុទ្ធសាសនា

តាមជំនឿក្នុងពុទ្ធសាសនា មនុស្សស្លាប់ទៅក៏នៅតែទទួលអំណាចនៃកម្មផលទៅតាមអំពើដែលខ្លួនបានប្រព្រឹត្តកាលមាននៅជីវិត ។ មនុស្សចិត្តអាក្រក់ប្រព្រឹត្តបាបកម្ម លុះស្លាប់ទៅតែងទៅកើតជាប្រេត នរក នៅស្ថានយមរាជ (តាមគម្ពីររបស់ពុទ្ធសាសនា) គេថា ប្រេតមានបួនប្រភេទ គឺប្រេតចិញ្ចឹមជីវិតដោយខ្ទុះឈាម ប្រេតដែលស្រេកឃ្លានអាហារជានិច្ច ប្រេតដែលស្ថិតក្នុងភ្លើងជានិច្ច និងប្រេតដែលចិញ្ចឹមជីវិតដោយផលដែលបុគ្គលដទៃឧទ្ទិសឱ្យ ។ ប្រេតទាំងបួនប្រភេទនេះត្រូវទទួលយកនូវភោគផលដែលកូនចៅឧទ្ទិសឱ្យក្នុងពិធីបុណ្យភ្ជុំបិណ្ឌ ។

គេតែងមានជំនឿថា រយៈពេល 14 ថ្ងៃនៃថ្ងៃកាន់បិណ្ឌ បើប្រេតដើរគ្រប់ 7 វត្ត ហើយនៅតែរកមិនឃើញកូនចៅ ឬសាច់ញាតិរបស់ខ្លួនទេ ពួកប្រេតទាំងនោះនឹងអត់បាយអត់ទឹក រងទុក្ខវេទនា ។ ពួកគេជេរប្រទេច ដាក់បណ្តាសាដល់កូនចៅកុំឱ្យមានសេចក្តីសុខអ្វីទាំងអស់ ។

• តើបុណ្យដាក់បិណ្ឌនិងបុណ្យភ្ជុំបិណ្ឌគេរៀបចំដូចម្ដេច ?



ពុទ្ធបរិស័ទនៅកម្ពុជា ប្រារព្ធពិធីបុណ្យដាក់បិណ្ឌចាប់ពីថ្ងៃទី1 រោចរហូតដល់ថ្ងៃទី 14 រោច ខែភទ្របទ ។ ពេលនោះគេបានហៅថា បិណ្ឌ 1 បិណ្ឌ 2 ហូរហែរហូតដល់បិណ្ឌ 14 ។ ក្នុងបិណ្ឌនីមួយៗ អ្នកស្រុកចែកគ្នាជាក្រុម ដាក់វេនគ្នាធ្វើចង្ហាន់ប្រគេនព្រះសង្ឃគង់នៅឯវត្ត ។

លុះដល់ថ្ងៃទី 15 រោចជាថ្ងៃបញ្ចប់ គេហៅថាថ្ងៃបុណ្យភ្ជុំបិណ្ឌ ។ អ្នកស្រុកនាំគ្នាធ្វើចង្ហាន់យកទៅប្រគេនព្រះសង្ឃ ។ ពួកគេជួបជុំគ្នានៅក្នុងវត្តនិងមានយកនំអន្សម ផ្លែឈើ តែ ស្ករ ទឹកក្រូច ទឹកដោះគោនិងវត្ថុផ្សេងៗជាច្រើនទៀតទៅប្រគេនព្រះសង្ឃ ។ បន្ទាប់មកគេធ្វើពិធីរាប់បាត្រប្រគេនចង្ហាន់ព្រះសង្ឃ និងបង្សុកូលផង ដើម្បីឧទ្ទិសផលនោះទៅដល់ញាតិ ដែលចែកឋានទៅហើយ ។

ពេលរសៀលពុទ្ធបរិស័ទទាំងអស់នាំគ្នាស្ដាប់ធម្មទេសនា ។ ថ្ងៃនោះអ្នកស្រុក ស្រី ប្រុស ក្មេងចាស់ ក្រោកពីព្រលឹមដោយក្ដីរីករាយ ។ ពួកគេស្លៀកពាក់ខោអាវស្អាតបាត រួចនាំគ្នាទៅវត្តដើម្បីធ្វើបុណ្យ ។

ក្រៅពីពិធីនៅវត្ត គេធ្វើពិធីសែនព្រេននៅតាមផ្ទះវេលាយប់បង្អើយ ដើម្បីអញ្ជើញវិញ្ញាណក្ខន្ធដូនតា ញាតិការ 7 សន្ដានមកទទួលភោគផលពីកូនចៅ ។

## 2. បុណ្យអុំទូក អកអំបុក សំពះព្រះខែ

- តើបុណ្យអុំទូកជាបុណ្យអ្វី ?



ពិធីបុណ្យអុំទូក ជាបុណ្យប្រពៃណីដែលធ្វើឡើងដើម្បីរំលឹកថ្ងៃជ័យជម្នះនៃកងទ័ពជើងទឹកដ៏ខ្លាំងពូកែនាសម័យអង្គរ ។ កាលពីសម័យអង្គរបុណ្យនេះតែងធ្វើឡើងនៅតាមគូទឹកប្រាសាទអង្គរវត្ត ។ បច្ចុប្បន្នការប្រារព្ធពីធីបុណ្យអុំទូកស្ថិតនៅទន្លេចតុមុខខាងមុខព្រះបរមរាជវាំងនៃព្រះរាជាណាចក្រកម្ពុជា ។ នៅថ្ងៃទី14 និង 15 កើតខែកត្តិកពិធីអុំទូកចាប់ផ្តើមប្រណាំងគ្នាតាមគូ តាមខ្នាតទូកដែលកំណត់ដោយគណៈកម្មាធិការរៀបចំបុណ្យជាតិនិងអន្តរជាតិ ។ ការប្រណាំងទូកក្នុងមួយគូៗ គេអាចអុំពីរលើកក្នុងមួយថ្ងៃ ។ ដោយលើកទី 1 អុំខ្សែទឹកខាងក្នុង និងលើកទី 2 ត្រូវប្តូរទៅអុំនៅខ្សែទឹកខាងក្រៅវិញ ។

លុះដល់ថ្ងៃទី 1 រោច ខែកត្តិកត្រូវជាថ្ងៃទី 3 ក្រោយពីការអុំប្រណាំងទូកចប់ មានពិធីមួយទៀតហៅថា ពិធីកាត់ព្រ័ត្រ ឬចាប់កូនខ្លែង ។ ពិធីនេះទូកង ទូកម្លង ទាំងអស់ត្រូវចេញអុំឃីតៗអមជាមួយទូកមេទ័ព រៀបក្បួនចេញដំណើរទៅរកទីព្រ័ត្រ និងកាត់ខ្សែព្រ័ត្រដើម្បីអបអរសាទរដល់កងទ័ពជើងទឹកដែលទទួលជ័យជម្នះលើសត្រូវ ។ ការអុំប្រណាំងទូកមានកំណត់ពិន្ទុដោយគណៈកម្មាធិការរៀបចំបុណ្យជាតិនិងអន្តរជាតិលើល្បឿន និងសោភណភាពរបស់ទូក ។

• តើពិធីអកអំបុក សំពះព្រះខែធ្វើនៅពេលណា ? ដើម្បីអ្វី ?



នៅវេលាយប់ចន្ទពេញបូណ៌មីត្រូវនឹងថ្ងៃទី15កើត ខែអស្សុជ អ្នកស្រុកក្មេងចាស់ប្រុសស្រី ស្លៀកពាក់ស្អាតបាតមានទឹកមុខរីករាយ បាននាំយកផល្លានុផលមានចេក ទុំ ដូងខ្ចី ត្រាវ ដំឡូងស្វារ អំពៅ ស្លា អំបុក ក្រឡាន ធូបទៀន បាយសី ផ្កាភ្ញីរៀបចំប្រារព្ធពិធីសំពះព្រះខែនៅទីធ្លាវត្ត ឬមុខផ្ទះ ។ ពេលខែរះពេញពន្លឺគេរៀបចំអុជ ទៀនធូបសំពះបួងសួងថ្វាយគ្រឿងរណ្ដាប់ ដែលរៀបចំស្រេចថ្វាយចំពោះព្រះចន្ទ ។បន្ទាប់មកគេធ្វើពិធីអកអំបុក ដោយយកចេកលាយជាមួយអំបុកបង្អកគ្នាទៅវិញទៅមក រួចពួកគេសួរថាឆ្អែត ឬទេ ? ហៀរហូរឬទេ ? ហើយអ្នកឆ្លើយត្រូវឆ្លើយថា៖ “ឆ្អែតហៀរហូរហើយ” ។ ពិធីនេះធ្វើឡើងដើម្បីបង្ហាញនូវភោគផលកសិកម្មដែលទទួលបានក្នុងឆ្នាំថ្មីដោយភាពសម្បូរហូរហៀរ ។ ជាពិសេសក៏បង្ហាញពីប្រពៃណីជំនឿដែលពុទ្ធសាសនិកខ្មែររំលឹកដល់បារមីព្រះពោធិសត្វ ក្នុងកាលព្រះអង្គយោនយកព្រះជាតិជាសត្វទន្សាយនោះដែរ ។

## ៣. បុណ្យផ្កា

- ហេតុអ្វីបានជាគេធ្វើបុណ្យផ្កា ?



បុណ្យផ្កា ជាបុណ្យប្រពៃណីតាមបែបពុទ្ធសាសនាដ៏មានសារៈសំខាន់របស់ប្រជាពលរដ្ឋខ្មែរដែលអាចប្រារព្ធនៅតាមវត្តអារាម តាមផ្ទះ ក្រសួងមន្ទីរនិងសាលារៀន ។ គេធ្វើបុណ្យផ្កា ដើម្បីប្រមូលបច្ច័យយកទៅស្ថាបនាទីសាធារណៈនានា មានដូចជា សាលាឆទាន កុដិ សាលារៀន អណ្តូងទឹក ស្រះទឹក ផ្លូវចូលវត្ត បង្គន់អនាម័យ ជាដើម ។ សម្បត្តិទាំងនោះសម្រាប់ប្រើប្រាស់ក្នុងវត្តជាប្រយោជន៍រួមរបស់សហគមន៍ដែលគេរស់នៅ ។ បុណ្យនេះ គេច្រើនប្រារព្ធនៅអំឡុងបញ្ចប់ការប្រមូលផលកសិកម្ម ។ ពេលខ្លះ បុណ្យផ្ការៀបចំឡើងដោយគណៈកម្មការវត្ត ។ ពេលខ្លះ រៀបចំដោយបុគ្គលពុទ្ធបរិស័ទ និងពេលខ្លះទៀតរៀបចំដោយសមាគមពុទ្ធបរិស័ទ ។

បុណ្យផ្កាជាបុណ្យប្រពៃណីជាតិខ្មែរយើងមានតាំងពីបុរាណកាលមក ហើយត្រូវបានប្រជាពលរដ្ឋ អនុវត្តបន្តរហូតបច្ចុប្បន្ន ។ យើងទាំងអស់គ្នាត្រូវចូលរួមឧបត្ថម្ភបុណ្យផ្កាតាមសទ្ធាជ្រះថ្លារៀងៗខ្លួនដើម្បីប្រយោជន៍រួម ។

- តើគេរៀបចំធ្វើបុណ្យផ្កាដូចម្ដេចខ្លះ ?



ជាទូទៅ ប្រជាពលរដ្ឋខ្មែរតែងមានអារម្មណ៍រីករាយនៅថ្ងៃបុណ្យផ្កា និងមានសទ្ធាជ្រះថ្លាជួយទ្រទ្រង់សាសនា ព្រោះថ្ងៃបុណ្យនេះបានផ្ដល់ឱកាសឱ្យក្រុមញាតិដែលនៅស្រុកជិតក្ដី ឆ្ងាយក្ដីបានជួបជុំធ្វើបុណ្យទានជាមួយគ្នាផងដែរ ។ បុណ្យផ្កាតែងប្រារព្ធធ្វើឡើងចំនួនពីរថ្ងៃ ។ មុនពេលប្រារព្ធពិធីបុណ្យមួយថ្ងៃអ្នកខ្លះធ្វើរោងបុណ្យ ខ្លះទៀតបេះផ្កាម្លិះ ផ្កាឈូកយកមកក្រងជាកម្រង និងយកកូនចេក ឬមែកឈើមកតាក់តែងលំអធ្វើដើមផ្កា ។ បន្ទាប់មកគេយកក្រដាសប្រាក់សម្រាប់ឧបត្ថម្ភបុណ្យមកដោតចងធ្វើស្លឹកផ្កា ។ ពេលរសៀលគេធ្វើពិធីចម្រើនព្រះបរិត្តនិងសំដែងធម្មទេសនាឆ្លងផ្កា ។

ពេលរាត្រីតែងមានកម្មវិធីកម្សាន្តខ្លះៗ ទៅតាមការនិយមចូលចិត្តរបស់ខ្មែរយើងដូចជា ការសម្ដែងសិល្បៈរបាំប្រពៃណីខ្មែរ ល្ខោនបាសាក់ អាយ៉ៃ យីកេ រាំវង់ បញ្ចាំងភាពយន្តជាដើម ។ ក្រៅពីការកម្សាន្តសប្បាយក៏ជាការផ្ដល់ឱកាសដល់អ្នកចូលរួមទាំងអស់ដែលមានសទ្ធាជ្រះថ្លា ចូលចាប់មគ្គផល ដើម្បីសន្សំកុសលបុណ្យរៀងៗខ្លួនផងដែរ ។

លុះព្រឹកឡើងគេរៀបចំដង្ហែផ្កាទៅថ្វាយព្រះពុទ្ធរូប និងវេរប្រគេនផ្កាបច្ច័យដល់ព្រះសង្ឃជាកិច្ចបង្ហើយបុណ្យ ។

**មេរៀនសង្ខេប**

- បុណ្យភ្ជុំបិណ្ឌគេធ្វើចាប់ពីថ្ងៃ 1 រោចដល់ថ្ងៃទី 15 រោច ខែភទ្របទមានរយៈពេល 15 ថ្ងៃ ។ បុណ្យនេះ ធ្វើឡើងដើម្បីប្រគេនចង្ហាន់ព្រះសង្ឃ និងឧទ្ទិសផលឱ្យញាតិដែលបានចែកឋានទៅ ។
- បុណ្យអុំទូក ធ្វើឡើងដើម្បីរំលឹកថ្ងៃជ័យជម្នះនៃកងទ័ពជើងទឹកនាសម័យអង្គរ ។ ឯការអកអំបុក សំពះព្រះខែជាការបង្ហាញភោគផលកសិកម្មដែលទទួលបានក្នុងឆ្នាំថ្មី និងការរំលឹកដល់បារមីព្រះពោធិសត្វកាលយកកំណើតជាសត្វទន្សាយ ។
- បុណ្យផ្កាជាបុណ្យឧបត្ថម្ភបច្ច័យសម្រាប់សាងសង់ទីសាធារណៈនានា ។ ភាគច្រើនគេធ្វើបុណ្យនេះ នៅរដូវទំនេរពីរបរកសិកម្ម ។

## សំណួរ

**ក. ចូរឆ្លើយនឹងសំណួរខាងក្រោម :**

1. តើអ្នកធ្លាប់ចូលរួមបុណ្យភ្ជុំបិណ្ឌនៅឯណា ? ដើម្បីអ្វី ?
2. តើការធ្វើបុណ្យភ្ជុំបិណ្ឌប្រជាជនយើងមានជំនឿដូចម្តេច ?
3. តើបុណ្យអុំទូកគេធ្វើនៅពេលណា ? មានប៉ុន្មានថ្ងៃ ?
4. តើពិធីកាត់ព្រ័ត្រនៅពេលបុណ្យអុំទូកមានន័យដូចម្តេច ?
5. ជាទូទៅ តើគេធ្វើបុណ្យផ្កាដើម្បីអ្វី ?

**ខ. ចូរបង្ហាញពីរបៀបរៀបចំពិធីបុណ្យអកអំបុក សំពះព្រះខែដែលអ្នកធ្លាប់បានឃើញ និងចូលរួមតាមរយៈសំណួរខាងក្រោម :**

1. តើអ្នកធ្លាប់បានចូលរួមរៀបចំធ្វើពិធីបុណ្យអកអំបុក សំពះព្រះខែនៅឯណា ?
2. តើការរៀបចំនោះត្រូវមានអ្វីខ្លះ ?
3. តើអ្នកមានអារម្មណ៍ដូចម្តេចនៅពេលបានចូលរួមពិធីអកអំបុកសំពះព្រះខែ ?

មេរៀនទី

# 3 ការងារប្រចាំថ្ងៃ

## 1. តម្លៃការងារ



ការងារជាប្រភពនាំមកនូវផលប្រយោជន៍ ។ ការងារសុចរិតជាតម្លៃដែលមនុស្សគ្រប់រូបប្រាថ្នា និងប្រកាន់យកជាមុខរបរ ។ មនុស្សធ្វើការងារដើម្បីចិញ្ចឹមជីវិតរាល់ថ្ងៃ ។ ឯកុមារក៏មានការងារត្រូវធ្វើប្រចាំថ្ងៃ ដូចមនុស្សចាស់ដែរ ។ ពួកគេត្រូវសិក្សារៀនសូត្រ ត្រូវជួយធ្វើកិច្ចការផ្ទះ និងត្រូវចូលរួមធ្វើកិច្ចការសង្គមផងដែរ ។

### ក. ការសិក្សារៀនសូត្រ

ការសិក្សាជាការងារចម្បងរបស់កុមារ ។ ពួកគេត្រូវបំពេញកិច្ចការនេះមិនអាចធ្វេសប្រហែសបានទេ ។ ភារកិច្ចសិក្សារបស់កុមារ គឺត្រូវខិតខំអាន សរសេរ និយាយស្តាប់ទាំងក្នុងថ្នាក់ និងក្រៅថ្នាក់ ហ្វឹកហាត់គណនាលេខនព្វន្ត និងរៀបចំឥរិយាបថឱ្យបានខ្ជាប់ខ្ជួនរាល់ថ្ងៃ ។ កិច្ចការបន្ថែមទៀតដែលកុមារត្រូវធ្វើ គឺការគោរពវិន័យនិងបទបញ្ជាផ្ទៃក្នុង ការសំអាតថ្នាក់ និងសំអាតសាលារៀនជាដើម ។

ដូចនេះ ការសិក្សាជាការងារប្រចាំថ្ងៃរបស់កុមារដើម្បីហ្វឹកហាត់ឱ្យទទួលបាននូវចំណេះដឹង បំណិន និងឥរិយាបថត្រឹមត្រូវ ។

## ១. ការជួយធ្វើកិច្ចការផ្ទះ



អ្នករស់នៅក្នុងគ្រួសារជាមួយគ្នា សុទ្ធតែរួមសុខរួមទុក្ខជាមួយគ្នា ។

ការជួយធ្វើកិច្ចការផ្ទះ ជាការងារដែលកុមារគ្រប់រូបត្រូវបំពេញរាល់ថ្ងៃ ។ កិច្ចការទាំងនោះ កុមារត្រូវជួយបោសសំអាតផ្ទះ លាងបង្គន់ បន្ទប់ទឹក ក្រោលគោក្របី ទ្រុងជ្រូក មាន់ទា ប្រមូលសំរាម និងលាមកសត្វទៅដាក់ក្នុងរោង ឬរណ្ដៅទុកធ្វើជី ។ ពេលចម្អិនអាហារកុមារត្រូវជួយបេះបន្លែ លាងសំអាត ត្រី សាច់ឱ្យបានត្រឹមត្រូវ និងរៀបចំសំអាតទុកដាក់ចាន ស្លាបព្រា កែវទឹក រាល់ពេលបរិភោគរួច ។ កុមារក៏ត្រូវជួយស្រោចទឹក បោចស្មៅ ចាប់ដង្កូវចេញពីដំណាំក្នុងសួនបន្លែផងដែរ ។ ដើម្បីឱ្យគ្រួសារកាន់តែមានភាពរីករាយថែមទៀតនោះកុមារត្រូវជួយនាំប្អូនលេងកម្សាន្ត និងសិក្សាឱ្យបានរាល់ថ្ងៃ ។

ការជួយធ្វើកិច្ចការផ្ទះនាំឱ្យគ្រួសារមានបរិយាកាសរីករាយគ្រប់ពេលវេលា និងបង្កើនភាពស្និទ្ធស្នាល ដែលនាំមកនូវភាពរីកចម្រើន ។

## គ. ការចូលរួមធ្វើកិច្ចការសង្គម



កុមារមានកិច្ចការជាច្រើន ដែលពួកគេបានបំពេញប្រចាំថ្ងៃ ។ ក្រៅពីការសិក្សា និងការធ្វើកិច្ចការផ្ទះ កុមារក៏អាចចូលរួមជួយធ្វើកិច្ចការក្នុងសហគមន៍ ដែលគេកំពុងរស់នៅឱ្យបានល្អប្រសើរថែមទៀត ។ ការងារដែលកុមារអាចធ្វើបានមានដូចជា ការចូលរួមដាំដើមឈើ ការធ្វើពលកម្មសំអាតបរិស្ថានភូមិ សំអាតប្រភពទឹក ការការពារសម្បត្តិវប្បធម៌ជាតិ ការចូលរួមលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ... ។

ដូចនេះ ការចូលរួមជួយធ្វើកិច្ចការសង្គមរបស់កុមារជាផ្នែកមួយអាចនាំឱ្យសង្គមមានការអភិវឌ្ឍ ព្រោះកុមារអាចធ្វើឱ្យសង្គមមានបរិស្ថានស្អាតល្អ មានសណ្តាប់ធ្នាប់ និងសន្តិសុខ ។

## 2. ផលប្រយោជន៍នៃការងារ



### ក. ផលប្រយោជន៍នៃការសិក្សា

សិស្សានុសិស្សទាំងឡាយណាដែលបានបំពេញករណីយកិច្ចសិក្សា គឺជាជនដែលបានរកផលប្រយោជន៍ជាច្រើនសម្រាប់ខ្លួនឯង គ្រួសារ និងសង្គម ។ មនុស្សមានចំណេះដឹងជ្រៅជ្រះបានកម្ចាត់បង់នូវសេចក្ដីល្ងង់ខ្លៅ ។ ជនដែលចេះអក្សរ លេខ នព្វន្តទុកដូចជា មនុស្សភ្លឺថ្លាដូចពេជ្រ ដែលអាចយកទៅច្នៃជារតនវត្ថុ ឬសម្ភារៈប្រើប្រាស់តាមសេចក្ដីត្រូវការ ។ បើអ្នកសិក្សាមានចំណេះវិជ្ជាពិតប្រាកដហើយ អ្នកនឹងចូលប្រឡងចាប់យកមុខរបរ ឬការងារណាក៏បានគាប់ប្រសើរដែរ ។

ចំណេះ អាចញ៉ាំងឱ្យយើងថ្កុំថ្កើងរុងរឿងបាន ដោយសារការប្រព្រឹត្តកិរិយាមារយាទល្អ ។ វិជ្ជាមានតម្លៃសម្រាប់អភិវឌ្ឍគំនិតប្រាជ្ញាជានិច្ច ។

## ខ. ផលប្រយោជន៍នៃការជួយធ្វើកិច្ចការគ្រួសារ

គ្រួសារតែងមានជីដូនជីតា ម្ដាយឪពុក កូនចៅ បងប្អូនរស់នៅជាមួយគ្នា ជ្រកកោនក្រោមគេហដ្ឋានតែមួយ ។ ពេលបានសប្បាយគេរួមគ្នាអបអរសាទរ ។ ពេលមានបញ្ហាគេចូលរួមជួយដោះស្រាយជាមួយគ្នា ។ ការជួយកិច្ចការក្នុងគ្រួសារជាការសម្រាលការងារគ្នាបានយ៉ាងគាប់ប្រសើរ ។ ទង្វើនេះអាចនាំឱ្យគ្រួសារមានសុភមង្គល ព្រោះបានបង្កើតភាពស្និទ្ធស្នាល សហការ និងមានសាមគ្គីភាព ព្រមទាំងមានការយោគយល់ អធ្យាស្រ័យគ្នា រវាងម្ដាយឪពុក និងកូនៗ ជីដូន ជីតា និងចៅៗ បង និងប្អូន ។ ជាពិសេសធ្វើឱ្យគ្រួសារមានបរិយាកាសរីករាយ សេដ្ឋកិច្ចរីកចម្រើន ។

ដូចនេះ គ្រួសារជាកោសិកាសង្គម ។ គ្រួសាររីកចម្រើននាំឱ្យសង្គមរីកចម្រើនដែរ ។ ការចេះយោគយល់អធ្យាស្រ័យក្នុងគ្រួសារនាំឱ្យគេចេះយោគយល់ និងជួយគ្នាក្នុងសង្គមថែមទៀត ។

## គ. ផលប្រយោជន៍នៃការធ្វើកិច្ចការក្នុងសង្គម

សង្គមជាបណ្ដុំនៃមនុស្ស ។ ការរស់នៅរបស់មនុស្សតែងមានទំនាក់ទំនងគ្នានិងជួយកិច្ចការគ្នាទៅវិញទៅមក ។ កុមារក៏ជាមនុស្សដែលត្រូវមានកាតព្វកិច្ចជួយធ្វើកិច្ចការផ្សេងៗនៅក្នុងសហគមន៍ទៅតាមសមត្ថភាពនិងកម្រិតវ័យរបស់ពួកគេ ។ ផលប្រយោជន៍ដែលទទួលបានពីការងារទាំងនោះជាចំណែកមួយជួយឱ្យសង្គម ដែលពួកគេរស់នៅមានបរិស្ថានស្អាតល្អ ចេះគោរពសិទ្ធិគ្នា ចេះយោគយល់អធ្យាស្រ័យនិងចេះគោរពច្បាប់បានត្រឹមត្រូវ ជាពិសេសធ្វើឱ្យសង្គមមានសណ្ដាប់ធ្នាប់ ។

ដូចនេះ ការចូលរួមជួយកិច្ចការសង្គមរបស់កុមារជាសកម្មភាពដែលជំរុញឱ្យសង្គមមានការអភិវឌ្ឍឆាប់រហ័ស ។

# ៣. ការសម្ភាសន៍ជាមួយអ្នកមានបំណិនក្នុងការធ្វើការងារ



• ការរៀបចំធ្វើសម្ភាស

សម្ភាសន៍ គឺជាការសុំជួបនរណាម្នាក់ ដើម្បីសាកសួរឱ្យបានព័ត៌មានមួយច្បាស់ត្រឹមត្រូវ ។ ដូចនេះមុនទៅសម្ភាសន៍នរណាម្នាក់យើងត្រូវរៀបចំជាមុនមានដូចជា ៖

• កំណត់គោលដៅ ឬមនុស្សដែលត្រូវជួបសម្ភាស ។
• ផ្ដល់ដំណឹង ឬសុំការអនុញ្ញាតជាមុនពីអ្នកត្រូវសម្ភាស ។
• រៀបចំកម្រងសំណួរ ឬកំណត់ប្រធានបទសម្រាប់សួរឱ្យបានច្បាស់លាស់ ។

កិច្ចការទាំងអស់នេះនឹងធ្វើឱ្យយើងទទួលបានព័ត៌មានពិតនិងច្បាស់លាស់ ។

• ការសម្ភាសជាមួយអ្នកធ្វើកន្ទេលក្រហម



តើការធ្វើកន្ទេលក្រហមត្រូវមានវត្ថុធាតុដើមអ្វីខ្លះ ? មានលំនាំដូចម្ដេច ?

មីងសីជាអ្នកត្បាញកន្ទេលក្រហម ។ គាត់រស់នៅភូមិខ្លាគ្រហឹម ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ រាល់ថ្ងៃគាត់ត្បាញកន្ទេលបានល្អប្រណីតលក់បានកម្រៃខ្ពស់ថែមទៀត ។ មីងបានប្រាប់ថា ការធ្វើកន្ទេលក្រហម ដំបូងគេត្រូវយកកក់មូល មកកូតហើយហាលថ្ងៃ ។ បន្ទាប់មកគេជ្រលក់កក់នោះនឹងល័ក្តផ្សេងៗ រួចយកទៅហាលថ្ងៃឱ្យស្ងួតម្ដងទៀត ។ មុននឹងត្បាញកន្ទេល គេយកក្រចៅមកវេញធ្វើជាខ្សែកន្ទេលរួចទើបអន្ទង ។ ពេលរៀបត្បាញគេយកកក់ទៅជ្រលក់ទឹកឱ្យសើម ទើបយកមកត្បាញ ។ ការត្បាញកន្ទេលត្រូវការមនុស្សពីរនាក់ គឺម្នាក់អ្នកដាក់កក់ ឯម្នាក់ទៀតអ្នកគោះនិងវេចមុខ ។

ដូចនេះការធ្វើកន្ទេលក្រហម ជាការងារមួយមានលំនាំច្បាស់លាស់និងទាមទារបំណិនប្រសប់ ។

### មេរៀនសង្ខេប

កិច្ចការប្រចាំថ្ងៃរបស់មនុស្សម្នាក់ៗ គឺការព្យាយាមបំពេញការងារសុចរិត ដោយយកចិត្តទុកដាក់ ដើម្បីធ្វើឱ្យមានជីវិតរុងរឿង សម្បូរសប្បាយ ។ គ្រប់មុខរបរសុចរិត សុទ្ធតែមានប្រយោជន៍ និងមានតម្លៃទាំងអស់ ។ ដើម្បីប្រកបការងារបានជោគជ័យ មនុស្សម្នាក់ៗ ត្រូវខិតខំសិក្សានិងជ្រើសរើសមុខរបរតាមជំនាញ បំណិន ឬតាមស្ថានភាពនិងលក្ខណៈភូមិសាស្ត្រដែលខ្លួនកំពុងរស់នៅ ។

## សំណួរ

**ក. ចូរឆ្លើយនឹងសំណួរខាងក្រោម :**

1. តើកុមារមានការងារប្រចាំថ្ងៃអ្វីខ្លះ ?
2. តើកុមារត្រូវបំពេញការងាររៀនសូត្រដូចម្តេច ?
3. តើកិច្ចការផ្ទះអ្វីខ្លះ ដែលកុមារអាចជួយធ្វើបាន?
4. តើកុមារអាចចូលរួមធ្វើកិច្ចអ្វីខ្លះ ក្នុងសង្គម?
5. តើការងារប្រចាំថ្ងៃរបស់អ្នកមានអ្វីខ្លះ ?

**ខ. ផ្អែកលើអត្ថបទនិងបំណិនក្នុងការធ្វើកន្ទេលក្រហម ចូរអ្នកធ្វើសម្ភាសជាមួយអ្នកមានបំណិនធ្វើការងារណាមួយតាមលំនាំសំណួរខាងក្រោម :**

1. ដើម្បីធ្វើការងារ ឬផលិតសម្ភារៈនោះ តើគេត្រូវការវត្ថុធាតុដើមអ្វីខ្លះ ?
2. ដំបូង តើគេចាប់ផ្តើមធ្វើអ្វី ?
3. បន្ទាប់មក តើគេធ្វើដូចម្តេចទៀត ? ហើយបន្តបន្ទាប់រហូតដល់ចប់ តើគេធ្វើដូចម្តេចខ្លះ ?
4. តើការងារនោះត្រូវការបំណិនអ្វីខ្លះ ?

មេរៀនទី

# 4 អំណាចនីតិប្បញ្ញត្តិ

ព្រះរាជាណាចក្រកម្ពុជាមានព្រឹទ្ធសភានិងរដ្ឋសភាដែលជាស្ថាប័នកំពូលកាន់អំណាចនីតិប្បញ្ញត្តិ ។ ស្ថាប័នទាំងពីរជាអ្នកអនុម័តច្បាប់សម្រាប់ប្រើប្រាស់ក្នុងប្រទេស ។

## 1. ព្រឹទ្ធសភា



*ព្រឹទ្ធសភា*

ព្រឹទ្ធសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ។ ព្រឹទ្ធសភាមានប្រធាន អនុប្រធាននិងសមាជិកស្មើនឹងពាក់កណ្តាលនៃសមាជិករដ្ឋសភាទាំងមូល ។ សមាជិកព្រឹទ្ធសភាខ្លះត្រូវបានចាត់តាំងនិងសមាជិកខ្លះទៀតត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកល ។

ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភានិងរាជរដ្ឋាភិបាល ។ ជាពិសេសត្រូវពិនិត្យរាល់ច្បាប់ទាំងឡាយណាដែលរដ្ឋសភាបានអនុម័តរួចឬបញ្ជូនច្បាប់ដែលអនុម័តរួចនោះត្រឡប់ទៅរដ្ឋសភាពិនិត្យជាថ្មី ក្នុងករណីមានជម្លោះ ។

## 2. ភារកិច្ចនិងការទទួលខុសត្រូវរបស់ប្រធាននិងអនុប្រធានព្រឹទ្ធសភា



ប្រធានព្រឹទ្ធសភាមានកិច្ចការជាច្រើនដែលត្រូវបំពេញ ។ ភារកិច្ចទាំងនោះមានដូចខាងក្រោម ។

- ធានាការប្រព្រឹត្តទៅនៃព្រឹទ្ធសភាឱ្យបានត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ។
- ដឹកនាំអង្គប្រជុំនៃព្រឹទ្ធសភានិងគណៈកម្មាធិការអចិន្ត្រៃយ៍ ។
- បើក ឬលើកពេលប្រជុំព្រឹទ្ធសភានិងគណៈកម្មាធិការអចិន្ត្រៃយ៍ ។
- ចាត់តាំងការពិភាក្សាហើយចុះហត្ថលេខាលើកំណត់ហេតុនៃការប្រជុំព្រឹទ្ធសភា។
- ធ្វើឱ្យមានការប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ។
- រក្សាការពារសណ្តាប់ធ្នាប់ផ្ទៃក្នុងនៃព្រឹទ្ធសភា ។
- ទាក់ទងជាមួយព្រះមហាក្សត្រ រដ្ឋសភា ឬអាជ្ញាធរសាធារណៈ ។
- ទាក់ទងជាមួយប្រធានរដ្ឋសភា ដើម្បីរៀបចំសមាជអង្គសភាទាំងមូល ។ ឯអនុប្រធានទាំងពីរជាអ្នកជួយធ្វើកិច្ចការប្រធាន ឬធ្វើការជំនួសប្រធាន ។

## ៣. រដ្ឋសភា




*រដ្ឋសភា*

### ក. តំណាងរាស្ត្រ

រដ្ឋសភាជាអង្គការកំពូលកាន់អំណាចនីតិប្បញ្ញត្តិ ។ អំណាចនេះរដ្ឋសភាមិនអាចប្រគល់ទៅឱ្យអង្គការ ឬបុគ្គលណាមួយបានឡើយ ។ បច្ចុប្បន្ន រដ្ឋសភាមានសមាជិកជាតំណាងរាស្ត្រ 123 រូប ។ តំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកលដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។ អ្នកដែលអាចឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុចាប់ពី 25 ឆ្នាំឡើងទៅ ។

## ១. តួនាទី



រដ្ឋសភាមានតួនាទីយ៉ាងសំខាន់ក្នុងការអនុម័តច្បាប់ ។ នៅពេលអនុម័តច្បាប់នីមួយៗ រដ្ឋសភាប្រើពេលប្រជុំពិភាក្សាយ៉ាងល្អិតល្អន់ ។ រដ្ឋសភាប្រជុំសាមញ្ញពីរដងក្នុងមួយឆ្នាំ ។ សម័យប្រជុំនីមួយៗមានថេរវេលាយ៉ាងតិចបីខែ ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬសមាជិករដ្ឋសភាចំនួនមួយភាគបីយ៉ាងតិចគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាកោះប្រជុំសភាជាវិសាមញ្ញ ។

សេចក្តីព្រាងច្បាប់ស្នើដោយរាជរដ្ឋាភិបាល ឬសេចក្តីស្នើច្បាប់ស្នើដោយតំណាងរាស្ត្រដប់នាក់យ៉ាងតិចអាចត្រូវកែលំអបំពេញបន្ថែម ឬកែសម្រួលឡើងវិញមុននឹងទទួលការអនុម័តពីរដ្ឋសភា ។

## គ. ភារកិច្ចប្រចាំថ្ងៃ









រដ្ឋសភាជាស្ថាប័នដែលបង្កើតដោយការបោះឆ្នោត ។ ក្នុងកិច្ចការបម្រើប្រទេសជាតិ រដ្ឋសភាមានភារកិច្ចដូចតទៅ ៖

- អនុម័តច្បាប់ប្រទេស ។
- បង្កើតរដ្ឋធម្មនុញ្ញ ។
- តាមដានរាល់សកម្មភាពរបស់រាជរដ្ឋាភិបាល ។
- អនុម័តថវិកាជាតិ ។
- បង្កើតច្បាប់ការពារពលរដ្ឋ ។
- ស្នើនិងធ្វើវិសោធនកម្មច្បាប់ ។

## មេរៀនសង្ខេប

ព្រឹទ្ធសភានិងរដ្ឋសភាជាស្ថាប័នមួយស្ថិតក្នុងអំណាចនីតិបញ្ញត្តិ ។ រដ្ឋសភាមានសមាជិកជាតំណាងរាស្ត្រ ។ តំណាងរាស្ត្រទាំងអស់ជាបេក្ខជនដែលកើតឡើងពីការបោះឆ្នោតរបស់ប្រជាពលរដ្ឋ ដើម្បីធ្វើការតំណាងឱ្យប្រជាពលរដ្ឋជាម្ចាស់ឆ្នោតវិញ ។ ព្រឹទ្ធសភាជាស្ថាប័នសម្របសម្រួលការងាររដ្ឋសភានិងរាជរដ្ឋាភិបាល ។

## សំណួរ

**ក. ចូរឆ្លើយនឹងសំណួរខាងក្រោម :**

1. តើរដ្ឋសភានិងព្រឹទ្ធសភាកាន់អំណាចអ្វី ?
2. តើរដ្ឋសភាមានតួនាទីធ្វើអ្វី ?
3. តើតំណាងរាស្ត្រកើតឡើងបានដោយសារអ្វី ?
4. តើរដ្ឋសភាមានភារកិច្ចធ្វើអ្វី ?
5. បច្ចុប្បន្ន តើរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាមានសមាជិកតំណាងរាស្ត្រប៉ុន្មានរូប ?

**ខ. ចូរសួរឪពុកម្តាយអ្នករួចសរសេរឈ្មោះតំណាងរាស្ត្រក្នុងខេត្តរបស់អ្នក ។**

| ល.រ | ឈ្មោះខេត្ត ឬរាជធានី | ឈ្មោះតំណាងរាស្ត្រ |
|---|---|---|
| | | |

មេរៀនទី

# 5 ការប្រើប្រាស់ដីនៅតាមទីតាំងនានា

ប្រទេសកម្ពុជាមានសណ្ឋានដីប្លែកៗពីគ្នា ដែលគេអាចចែកចេញជាបីផ្នែកធំៗ គឺ តំបន់ទំនាបកណ្តាល តំបន់ខ្ពង់រាប និងតំបន់ភ្នំ ។ ហេតុនេះ កសិករបានប្រើប្រាស់ដីទំនាបកណ្តាលសម្រាប់ដំណាំស្រូវ និងដីតំបន់ខ្ពង់រាបភាគច្រើនសម្រាប់ដាំដំណាំឧស្សាហកម្ម ។

## 1. ទីតាំងនិងព្រំប្រទល់ប្រទេសកម្ពុជា




ប្រទេសកម្ពុជា ស្ថិតនៅភូមិភាគអាស៊ីអាគ្នេយ៍ ត្រង់ចន្លោះខ្សែស្របទី10 និងទី 15 នៃរយៈទទឹងខាងជើង និងចន្លោះខ្សែបណ្តោយទី102 និង 108 នៃរយៈបណ្តោយខាងកើត ។ ប្រទេសនេះមានព្រំដែនខាងជើងជាប់ប្រទេសថៃនិងប្រទេសឡាវ ។ ខាងកើតនិងខាងត្បូងជាប់នឹងប្រទេសវៀតណាម ។ ខាងលិចជាប់នឹងប្រទេសថៃ មួយផ្នែកទៀតជាប់នឹងឈូងសមុទ្រថៃ ។ ផ្ទៃដីប្រទេសមានផ្ទៃក្រឡា 181 035$km^2$ និងមានព្រំដែនសរុបប្រវែង 2 600 km (5/6 ជាដីគោក និង1/6 ជាឆ្នេរសមុទ្រ) ។

## ១. ផ្លូវទឹកនិងទីតាំងរាជធានី-ខេត្ត




ផ្លូវទឹកនៅប្រទេសកម្ពុជារួមមានទន្លេមេគង្គដែលមានប្រភពនៅខ្ពង់រាបទីបេ ប្រទេសចិន ។ ទន្លេនេះហូរកាត់ប្រទេសកម្ពុជាមានប្រវែង 500km តាមខេត្តស្ទឹងត្រែង ក្រចេះ កំពង់ចាមព្រៃវែង និងខេត្តកណ្ដាល ។ ទន្លេមេគង្គចែកជាទន្លេមេគង្គលើ ឬទន្លេធំ ចាប់ពីល្បាក់ខោនព្រំប្រទល់ប្រទេសឡាវមកដល់ភ្នំពេញ ។ ទន្លេមេគង្គក្រោមឬទន្លេក្រៅ ចាប់ពីភ្នំពេញដល់ព្រំដែនវៀតណាម កាត់តាមអ្នកលឿង ។ ទន្លេបាសាក់ ឬទន្លេក្នុង ចាប់ពីភ្នំពេញ កាត់តាមតាខ្មៅដល់ព្រំដែនវៀតណាម ។ ទន្លេសាប ចាប់ពីភ្នំពេញទៅឆ្នុកទ្រូក្នុងខេត្តកំពង់ឆ្នាំង ។ ចាប់ពីឆ្នុកទ្រូទៅដល់ខេត្តសៀមរាបគេហៅថា បឹងទន្លេសាបដែលជាជង្រុកត្រី ។

ប្រទេសកម្ពុជាមានរាជធានីមួយ គឺរាជធានីភ្នំពេញ និងមានខេត្តចំនួន 24 គឺខេត្តកណ្ដាល តាកែវ កំពត កែប ព្រះសីហនុ កោះកុង កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ ឧត្ដរមានជ័យ សៀមរាប ព្រះវិហារ កំពង់ធំ កំពង់ចាម ក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ព្រៃវែង ស្វាយរៀង និងខេត្តត្បូងឃ្មុំ ។

## 3. វិស័យកសិកម្ម




ព្រះរាជាណាចក្រកម្ពុជាជាប្រទេសកសិកម្ម ។ ប្រជាជនប្រមាណ 85% ជាកសិករ ។ វិស័យកសិកម្ម ជាស្នូលនៃសេដ្ឋកិច្ចជាតិ ព្រោះផ្ទៃដីប្រមាណ 80% ជាដីកសិកម្ម ។ កសិករបានប្រើប្រាស់ដីសម្រាប់ដាំដំណាំស្រូវ ពោត សណ្តែក កៅស៊ូ កប្បាស ក្រចៅ និងដំណាំហូបផ្លែ ។ ក្នុងមួយឆ្នាំៗកសិករទទួលបានផលយ៉ាងច្រើនពីមុខរបរនេះ ។

គេអាចចែកដំណាំជាពីរប្រភេទធំៗ គឺដំណាំស្បៀងនិងដំណាំឧស្សាហកម្ម ។

## ក. ដំណាំសៀង



- **ស្រូវ**

ស្រូវជាដំណាំសំខាន់សម្រាប់ប្រទេសកម្ពុជា ។ ខេត្តដែលមានដំណាំស្រូវរួមមាន បាត់ដំបង ពោធិ៍សាត់ បន្ទាយមានជ័យ កំពង់ចាម ព្រៃវែង ស្វាយរៀង និងតាកែវ ។ ខេត្តទាំងនេះសម្បូរដីលិចទឹក និងដីល្បាប់ដែលមានជីជាតិដល់ដំណាំស្រូវ ជាហេតុធ្វើឱ្យកសិករទទួលផលស្រូវបានច្រើន ។

- **ពោត**

ពោតជាដំណាំបន្ទាប់ពីស្រូវ ។ កសិករនិយមដាំពោតស សម្រាប់ប្រើប្រាស់ជាអាហារក្នុងស្រុក និងពោតក្រហមសម្រាប់នាំចេញទៅលក់នៅក្រៅប្រទេស ។

ដំណាំពោត ច្រើនដាំនៅតាមតំបន់ទំនាបទន្លេមេគង្គ ទន្លេបាសាក់ និងតំបន់ខ្ពង់រាប ។

- **ត្នោតនិងអំពៅ**

ដំណាំផ្តល់ស្ករមានអំពៅនិងត្នោត ។ ដំណាំអំពៅច្រើនដាំនៅតាមដងទន្លេមេគង្គ និងទន្លេបាសាក់ ព្រោះដីតំបន់នេះជាដីល្បាប់សម្បូរជីជាតិ ។ ត្នោតមានច្រើននៅខេត្តកណ្តាល តាកែវ កំពត កំពង់ស្ពឺ កំពង់ចាម និងកំពង់ឆ្នាំង ។ ទឹកត្នោត ផ្លែត្នោត និងអំពៅ សម្រាប់ប្រើប្រាស់ក្នុងស្រុក ។ ស្ករនិងផលិតផលធ្វើពីទឹកត្នោតសម្រាប់នាំចេញក្រៅប្រទេស ។

• ដំណាំសៀងផ្សេងៗ



ដំណាំសៀងផ្សេងៗទៀតមានសណ្តែកបាយ សណ្តែកដី សណ្តែកសៀង ល្ង ម្រេច និងដំណាំហូបផ្លែ ។ ដំណាំទាំងនេះ គេអាចដាំបាននៅគ្រប់ខេត្តនៃព្រះរាជាណាចក្រកម្ពុជា ដូចជានៅតំបន់ដីក្រហម ដីល្បាយខ្សាច់ ដីមមោកជាដើម ។ដំណាំទាំងនេះអាចផ្គត់ផ្គង់ជីវភាពគ្រួសារ និងនាំចេញ ធ្វើប្រេងល្ង ប្រេងសណ្តែក គ្រឿង*ទេសបានយ៉ាងគាប់ប្រសើរ ។*

## ១. ដំណាំឧស្សាហកម្ម



ដំណាំឧស្សាកម្មដែលមាននៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្នមាន កៅស៊ូ ដូងប្រេង កប្បាស ក្រចៅជាដើម ។ ចំការកៅស៊ូធំៗមាននៅតំបន់ដីក្រហមក្នុងខេត្តកំពង់ចាម ក្រចេះ រតនគិរី និងខេត្តព្រះសីហនុ ។ បច្ចុប្បន្នដំណាំដូងប្រេងច្រើនជាងគេមាននៅខេត្តព្រះសីហនុ ។ ឯដំណាំកប្បាសគេច្រើនដាំនៅតាមបណ្តោយទន្លេមេគង្គក្នុងខេត្តកំពង់ចាម និងតំបន់ទំនាបខេត្តបាត់ដំបង ។ ក្រចៅភាគច្រើនគេដាំនៅខេត្តបាត់ដំបង ។ ផលិតផលជ័រកៅស៊ូ ផ្លែដូងប្រេង កប្បាស ក្រចៅ មួយចំនួនសម្រាប់ប្រើប្រាស់នៅក្នុងស្រុក រីឯមួយចំនួនទៀតសម្រាប់នាំចេញ ។

## 4. គូរចម្លងផែនទីព្រះរាជាណាចក្រកម្ពុជា

រូបគំនូរផែនទីព្រះរាជាណាចក្រកម្ពុជាតាមរបៀបចម្លង ។

ដើម្បីគូរចម្លងផែនទីប្រទេសយើងឱ្យបានត្រឹមត្រូវដូចរូបដើមត្រូវអនុវត្តតាមរបៀបដូចខាងក្រោម :




- គូរក្រឡាការេលើរូបផែនទីដើមដោយយកក្រឡានីមួយៗស្មើៗគ្នា ។
- ដាក់លេខរៀងនៅជួរដេក ដាក់អក្សររៀងនៅជួរឈរតាមចន្លោះក្រឡានីមួយៗ
- ចង់បានរូបតូចជាង ឬធំជាងរូបដើមត្រូវបង្រួម ឬពង្រីកទំហំក្រឡា តែរក្សាចំនួនក្រឡាការេទាំងអស់នៅដដែល ។

## មេរៀនសង្ខេប

ព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ដែលមានព្រំដែនជាប់នឹងប្រទេសថៃ ឡាវ វៀតណាម និងឈូងសមុទ្រថៃ ។ ព្រះរាជាណាចក្រកម្ពុជាមានរាជធានីនៅភ្នំពេញ និងមានខេត្តចំនួន 24 ។ ទន្លេមេគង្គហូរកាត់ប្រទេសកម្ពុជាចាប់ពីព្រំដែនឡាវរហូតដល់ព្រំដែនវៀតណាមភាគខាងត្បូង ។ ទន្លេមេគង្គបែកជាបួននៅភ្នំពេញហៅថាទន្លេចតុមុខ គឺទន្លេមេគង្គលើ ទន្លេមេគង្គក្រោម ទន្លេបាសាក់ និងទន្លេសាប ។ ដំណាំដែលសំខាន់ជាងគេ គឺស្រូវ ។ ក្រៅពីស្រូវ គេឃើញមានពោត សណ្តែក ល្ង ម្រេច និងឈើហូបផ្លែ ។ ចំពោះដំណាំផ្តល់ស្ករមានអំពៅនិងត្នោត ។ រីឯដំណាំឧស្សាហកម្ម មានកៅស៊ូ ដូងប្រេង កប្បាស ក្រចៅ... ។

## សំណួរ

**ក. ចូរគូស ✓ក្នុងប្រអប់ដែលជាចម្លើយត្រឹមត្រូវ**

1. ដីនៅតំបន់ជុំវិញបឹងទន្លេសាបភាគច្រើនគេដាំ

☐ ក. ពោត ☐ ខ. ស្រូវ ☐ គ. សណ្តែក ☐ ឃ. ម្រេច ។

2. បច្ចុប្បន្នគេអាចដាំកៅស៊ូបាននៅលើដី

☐ ក. ក្រហម ☐ ខ. ដីស ☐ គ. ដីខ្មៅ ☐ ឃ. ដីក្រហមនិងដីស ។

**ខ. ចូរឆ្លើយនឹងសំណួរខាងក្រោម :**

1. តើព្រះរាជាណាចក្រកម្ពុជាមានព្រំប្រទល់ជាប់ប្រទេសណាខ្លះ ?
2. តើព្រះរាជាណាចក្រកម្ពុជាមានរាជធានីឈ្មោះអ្វី? ចែកជាប៉ុន្មានខេត្ត? ខេត្តអ្វីខ្លះ?
3. តើប្រទេសយើងមានទន្លេអ្វីខ្លះ ?
4. តើដំណាំស្រូវមានច្រើនជាងគេនៅខេត្តណាខ្លះ ? ហេតុអ្វី ?
5. ចូរចង្អុលទីតាំងដំណាំស្បៀងនិងដំណាំឧស្សាហកម្មនៅលើផែនទី ។

ជំពូកទី

# 4 ជីវភាពសង្គមពីអតីតកាល



អាណាចក្រខ្មែរនាអតីតកាល មានទឹកដីធំទូលាយ ហើយបានបន្សល់នូវមរតកវប្បធម៌ សាសនា ទំនៀមទម្លាប់ ប្រាសាទ និងក្បាច់ចម្លាក់ដ៏ល្អវិសេសវិសាលជាច្រើន ។ អាស្រ័យហេតុនេះ ទើបប្រជាពលរដ្ឋនៃប្រទេសនានាលើសកលលោកមកទស្សនាយ៉ាងច្រើនកុះករ ព្រោះគេចង់ឃើញកេរដំណែលស្នាដៃទាំងអស់នោះ ។

មេរៀនទី

# 1 គំនូរក្បាច់បុរាណខ្មែរ

គំនូរក្បាច់បុរាណខ្មែរ ជាសម្បត្តិជាតិ ដែលបង្ហាញពីវប្បធម៌ សិល្បៈត្រាប់តាមធម្មជាតិយ៉ាងរស់រវើក ។ ការគូរគំនូរក្បាច់បុរាណខ្មែរជាការរួមចំណែកថែរក្សាការពារស្នាដៃសិល្បៈគំនូររបស់បុព្វបុរសដូនតាយើង ។

## 1. មូលដ្ឋានគ្រឹះនៃក្បាច់បុរាណ

ក្បាច់បុរាណខ្មែរមានមូលដ្ឋានបីយ៉ាង គឺក្បាច់ស្លឹកពោធិ៍ ក្បាច់កន្ទុយហង្ស និងក្បាច់គូទខ្យង ។ ប្រសិនបើអ្នកគូរគំនូរ ឬឆ្លាក់ចម្លាក់ផ្សេងៗប្រាសចាកពីមូលដ្ឋានទាំងបីនេះគំនូរនិងចម្លាក់នោះពុំមានលក្ខណៈជាក្បាច់បុរាណខ្មែរទេ ។

- **ក្បាច់មូលដ្ឋានខ្មែរ**



ស្លឹកពោធិ៍ កន្ទុយហង្ស គូទខ្យង

## 2. ក្បាច់តុបតែងលំអ

ក្បាច់តុបតែងលំអរបស់ខ្មែរច្រើនឆ្លាក់នៅតាមជញ្ជាំងប្រាសាទនានា វត្តអារាម និងវត្ថុប្រើប្រាស់មួយចំនួន ។ ក្បាច់តុបតែងលំអទាំងនោះមានច្រើនប្រភេទ ។ ដូចនេះយើងនឹងសិក្សាពីរបៀបគូរបំបែកទី2 នៃក្បាច់ត្របកឈូកក្បាច់ផ្កាចន្ទន៍ និងក្បាច់ចក ។

ដើម្បីគូរយើងត្រូវមាន ក្រដាស ខ្មៅដៃ បន្ទាត់ ជ័រលុប ... ។

- **របៀបគូរផ្ទាំងក្បាច់ត្របកឈូកបំបែកទី 2**



- **របៀបគូរខ្សែក្បាច់ត្របកឈូកបំបែកទី 2**



- របៀបគូរផ្ទាំងក្បាច់ចកបំបែកទី 2



- របៀបគូរខ្សែក្បាច់ចកបំបែកទី 2



- របៀបគូរផ្ទាំងក្បាច់ផ្កាចន្ទន៍បំបែកទី 2



- របៀបគូរខ្សែក្បាច់ផ្កាចន្ទន៍បំបែកទី 2



## ៣. សារៈសំខាន់នៃក្បាច់បុរាណខ្មែរ



ក្បាច់ត្របកឈូក ក្បាច់ផ្កាចន្ទន៍ និងក្បាច់ចក គេនិយមឆ្លាក់ ឬគូរលំអជាមួយនឹងរូបព្រហ្ម រូបអប្សរា ជាដើម និងគូរលំអតាមខ្លោងទ្វារ សសរពេជ្រ ស៊ុមបង្អួចផងដែរ ។ គំនូរក្បាច់ទាំងនេះគេអាចគូរ ឬឆ្លាក់លើមកុដ កងដៃ កងជើង ផ្តិល ចានវែក ដងកណ្តៀវជាដើម ។

ក្បាច់បុរាណទាំងនេះបានបង្ហាញឱ្យឃើញថា បុព្វបុរសខ្មែរស្រលាញ់ពេញចិត្តធម្មជាតិរុក្ខជាតិយ៉ាងក្រៃលែង ។ លោកបានយករុក្ខជាតិមកផ្សារភ្ជាប់ជាមួយមនុស្សគ្រប់ពេលនិងគ្រប់ទីកន្លែង ។ ជាពិសេសក្បាច់ទាំងបីនេះ មានតួនាទីសំខាន់ក្នុងការជួយតាក់តែងលំអចម្លាក់និងគំនូរខ្មែរឱ្យកាន់តែមានភាពរស់រវើក ។

**មេរៀនសង្ខេប**

គំនូរក្បាច់បុរាណខ្មែរមានមូលដ្ឋានបីយ៉ាង គឺស្លឹកពោធិ៍ កន្ទុយហង្ស និង គូទខ្យង ។

ក្បាច់ត្របកឈូក ជាក្បាច់យកតាមស្រទាប់នៃផ្កាឈូក ដើម្បីលំអជើងមកុដ ឬ បល្ល័ង្កព្រះជាដើម ។

ក្បាច់ផ្កាចន្ទន៍ជាក្បាច់យកលំនាំតាមផ្កាចន្ទន៍រីក សម្រាប់លំអស៊ុមទ្វារ ឬវត្ថុ ប្រើប្រាស់ផ្សេងៗ ។

ក្បាច់ចក ជាក្បាច់យកលំនាំតាម រុក្ខជាតិចក សម្រាប់លំអលើវត្ថុប្រើប្រាស់ ឬ ចម្លាក់រូបជាដើម ។

## សំណួរ

**ក. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ពីមុខចម្លើយដែលត្រឹមត្រូវ**

1. គំនូរក្បាច់ត្របកឈូកយកលំនាំតាម

☐ ក. ផ្កាឈូក ☐ ខ. ត្របកឈូក ☐ គ. ស្លឹកឈូក ។

2. គំនូរក្បាច់ផ្កាចន្ទន៍យកលំនាំតាម

☐ ក. ផ្កាចន្ទន៍ ☐ ខ. ស្រទាប់ផ្កាចន្ទន៍ ☐ គ. ផ្កាចន្ទន៍រីក ។

3. ការគូរខ្សែក្បាច់ គេត្រូវគូរ

☐ ក. ផ្ទាំងក្បាច់បីផ្ទាំង ☐ ខ. ផ្ទាំងក្បាច់ច្រើនរួមគ្នា ☐ គ. ផ្ទាំងក្បាច់មួយ ។

**ខ. ចូរឆ្លើយនឹងសំណួរខាងក្រោម :**

1. តើក្បាច់បុរាណខ្មែរ មានមូលដ្ឋានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

2. ហេតុអ្វីបានជាគេហៅថា ក្បាច់ត្របកឈូក ? ក្បាច់ផ្កាចន្ទន៍ ? ក្បាច់ចក ?

3. តើអ្នកធ្លាប់ឃើញគំនូរក្បាច់អ្វីខ្លះ ? នៅឯណា ? សម្រាប់ធ្វើអ្វី ?

មេរៀនទី

# 2 ការថែរក្សាឧបករណ៍ភ្លេងប្រពៃណី

ឧបករណ៍ភ្លេងប្រពៃណី គេប្រើប្រាស់សម្រាប់ប្រគុំជាតន្ត្រីកំដរការសម្ដែងសិល្បៈឱ្យទស្សនិកជនបានស្គាល់ពីវប្បធម៌អរិយធម៌ ដ៏ខ្ពង់ខ្ពស់របស់ខ្មែរកាលពីសម័យបុរាណ ។ ដើម្បីរក្សាកេរដំណែលដូនតាឱ្យបានគង់វង្ស យើងទាំងអស់គ្នាត្រូវយល់ដឹងនិងស្គាល់ប្រភេទវង់ភ្លេង និងឧបករណ៍ភ្លេងផ្សេងៗចាប់ពីពេលនេះតទៅ ។

## 1. វង់ភ្លេងមហោរី



វង់ភ្លេងមហោរីជាក្រុមតន្ត្រី គ្រឿងខ្សែ គ្រឿងដំ គ្រឿងគោះទះ និងគ្រឿងផ្លុំ ។ វង់ភ្លេងមហោរីជាវង់តន្ត្រីដែលអ្នកប្រាជ្ញធំៗ របស់ខ្មែរបង្កើតឡើងដើម្បីប្រគុំក្នុងព្រះបរមរាជវាំង ។ អ្នកប្រគុំភ្លេងមហោរីដោយមានអ្នកបាំងក្លស់ឱ្យមានឆ្លាក់ជារូបចម្លាក់ ។

បទភ្លេងមហោរីមានក្បួនខ្នាតជាក់លាក់ច្បាស់លាស់ទាំងចង្វាក់និងលំនាំបទ ។

## 2. ឧបករណ៍ភ្លេងមហោរី

វង់តន្ត្រីមហោរីមានឧបករណ៍ពីរក្រុមនៅជាមួយគ្នា គឺឧបករណ៍មួយចំនួនយកចេញពីវង់ភ្លេងការបុរាណមាន ចាប៉ី ទ្រ ស្គរ ឃឹម តាខេ ឈិង និងឧបករណ៍មួយចំនួនទៀតយកចេញពីវង់ភ្លេងពិណពាទ្យមាន រនាតឯក រនាតធុង ។

ចូរអានឈ្មោះឧបករណ៍ភ្លេងមហោរីតាមរូបភាពខាងក្រោមឱ្យបានត្រឹមត្រូវ ។



ចាប៉ី



ឈិង



រនាតឯក



រនាតធុង



ទ្រអ៊ូ



ទ្រសោ



តាខេ



ខ្លុយ



ឃឹម



ស្គរធុន

វង់ភ្លេងមហោរីមានឧបករណ៍ច្រើនដូចជា

ទ្រ : ទ្រសោធំ ទ្រសោតូច ទ្រអ៊ូ ទ្រឆេ ជាឧបករណ៍ប្រើខ្សែពីរមាន
ដងសម្រាប់កូត ។ ឧបករណ៍នោះមានសំនៀងឮខុសៗគ្នា ។

រនាត : រនាតឯក រនាតធុង ជាឧបករណ៍ គោះដំដោយអន្លូងពីរ ។

ខ្លុយ : ខ្លុយធំ ខ្លុយតូច ជាឧបករណ៍ខ្យល់ (ផ្លុំ) ។

ស្គរ : ស្គរថូន ស្គររមនា ជាឧបករណ៍ទះ ។

ឈិង : ជាឧបករណ៍គោះទង្គិចគ្នា ។

តាខេ : ជាឧបករណ៍ខ្សែសម្រាប់កេះ ។

ឃឹម : ជាឧបករណ៍ប្រើខ្សែសម្រាប់គោះដំដោយអន្លូងតូចពីរ ។

## ៣. របៀបប្រគំភ្លេងមហោរី

វង់ភ្លេងមហោរីមានឧបករណ៍ភ្លេងជាច្រើនប្រភេទសម្រាប់ប្រគំ ។ ពេលប្រគំ គេឃើញ ទ្រសោជាអ្នកនាំមុខ ទើបឧបករណ៍ដទៃទៀតប្រគំតាម ។



# 4. ការប្រគំភ្លេងមហោរី



គេប្រគំភ្លេងមហោរីក្នុងវង់ល្ខោនគែន ពិធីបុណ្យអកអំបុកសំពះព្រះខែ និងក្នុងពិធីបួងសួងជាដើម ។ ក្រោយសម័យលង្វែក អ្នកប្រគំភ្លេងមហោរីជានារីសុទ្ធ ថែមទាំងមានអ្នកចម្រៀង មានសំនៀងពីរោះ ដូចសត្វណូរី (ចាមរី) ។ តន្ត្រីមហោរីមានសំនៀងពីរោះស្រទន់ មានចង្វាក់ច្បាស់លាស់តាមក្បួនខ្នាត ។ ឯចម្រៀងជាកាព្យមានចំណាប់ចួនពីរោះណែងណង ។

**មេរៀនសង្ខេប**

វង់ភ្លេងមហោរីបង្កើតឡើង ដោយខ្មែរជំនាន់ដើម ។ វង់ភ្លេងនេះប្រគំក្នុងពិធីកម្សាន្ត និងពិធីបួងសួង ។ បច្ចុប្បន្នឧបករណ៍វង់ភ្លេងមហោរីមាន ទ្រអ៊ូ1 ទ្រសោធំ1 ទ្រសោតូច1 ទ្រឆេ1 ខ្លុយតូច1 ខ្លុយធំ1 តាខេ1 រនាតឯក1 ស្គរថូន1 ស្គររមនា1 និងឈិង1គូ ។

# សំណួរ

ក. **ចូរឆ្លើយនឹងសំណួរខាងក្រោម :**

1. តើភ្លេងមហោរីបង្កើតឡើងដោយនរណា ?
2. តើវង់ភ្លេងមហោរីមានឧបករណ៍អ្វីខ្លះ ?
3. តើគេប្រគំភ្លេងមហោរីក្នុងពិធីអ្វីខ្លះ ?
4. នៅសម័យលង្វែក តើអ្នកប្រគំភ្លេងមហោរីជាបុរស ឬស្ត្រី ?
5. តើបទចម្រៀងមហោរីជាពាក្យកាព្យ ឬពាក្យរាយ ?

ខ. **ចូរហៅឈ្មោះ ឧបករណ៍ភ្លេងមហោរីនីមួយៗ ខាងក្រោមនេះ ។**



គ. **ប្រសិនបើអ្នកមានឧបករណ៍ភ្លេងមហោរីចូរសាកល្បង គេះ កូត គោះ ផ្លុំ ទះ ដើម្បីដឹងពីសម្លេងរបស់វា ។**

ឃ. ចូរគូសសញ្ញា( ✓) តាមខ្លឹមសារដែលអ្នកធ្លាប់ប្រគំ ឬធ្លាប់ថែរក្សាឧបករណ៍ភ្លេងមហោរីនីមួយៗ ។

| ល.រ | ខ្លឹមសារ | ធ្លាប់ | មិនធ្លាប់ |
|---|---|---|---|
| 1 | ខ្ញុំអាចទះស្គររមនានិងស្គរថូនតាមចង្វាក់បទមហោរីបានយ៉ាងពីរោះ ។ | | |
| 2 | ខ្ញុំរៀនកូតទ្រនៅបន្ទប់វប្បធម៌ក្នុងសាលារៀន ។ | | |
| 3 | ខ្ញុំគោះឈិងបន្ទរជាចង្វាក់បទរាល់ពេលរៀនភ្លេង ។ | | |
| 4 | ខ្ញុំជូតសំអាតនិងគ្របឧបករណ៍ភ្លេងនៅពេលប្រគំ ឬរៀនរួច ។ | | |
| 5 | ខ្ញុំរៀនផ្លុំខ្លុយជាមួយមិត្តភក្តិ ។ | | |
| 6 | ខ្ញុំចូលរួមកេះតាខេ រាល់ពេលរៀនភ្លេង ។ | | |
| 7 | ខ្ញុំកាន់អន្លូងដំលើខ្សែឃឹមតាមគ្រូបង្ហាញ ។ | | |
| 8 | ខ្ញុំរៀបទុកដាក់អន្លូងរនាតទាំងពីរក្នុងស្នូក ។ | | |
| 9 | ខ្ញុំចូលរួមកេះ ដំ ផ្លុំ គោះ លើឧបករណ៍ភ្លេងមហោរីនៅសាលារៀន ។ | | |
| 10 | រាល់ពេលម៉ោងសិក្សាភ្លេងប្រពៃណី ខ្ញុំសាកល្បងទះស្គររមនាបានច្រើនជាងគេ ។ | | |
| 11 | ខ្ញុំអនុវត្តគោះរនាតរាល់ពេលទំនេរនៅផ្ទះ ។ | | |
| 12 | ខ្ញុំរៀនកូតទ្រនៅផ្ទះជីតារាល់ល្ងាចថ្ងៃសៅរ៍ ។ | | |

មេរៀនទី

# 3 សំណង់អគារបុរាណ

អគារបុរាណមានដូចជា ប្រាសាទ វត្តអារាម អគារធំៗរបស់រដ្ឋ សាលារៀន ផ្ទះដែលសាងសង់ឡើងពីថ្ម ឥដ្ឋ និងឈើប្រណីតៗ ។ សំណង់ទាំងនេះជាស្នាដៃដ៏មានទេពកោសល្យរបស់បុព្វបុរសខ្មែរ ។ វាជាសម្បត្តិបច្ចេកទេសនិងទំនៀមទម្លាប់សម្រាប់ឱ្យអ្នកជំនាន់ក្រោយសិក្សាស្វែងយល់ ។ ដូចនេះ យើងទាំងអស់គ្នាត្រូវថែរក្សាមរតករបស់យើងឱ្យបានខ្ជាប់ខ្ជួនជានិរន្តរ៍ ។

## 1. ទីកន្លែងនិងសំណង់អគារបុរាណ

### ក. ព្រះបរមរាជវាំង

ព្រះបរមរាជវាំង ឋិតនៅត្រង់ចំណុចប្រសព្វនៃទន្លេបួនមុខ មានទន្លេមេគង្គលើ ទន្លេមេគង្គក្រោម ទន្លេបាសាក់ និងទន្លេសាប ។ ព្រះបរមរាជវាំងបានកសាងឡើងចំនួនពីរលើក ដែលលើកទី 1 ក្នុងឆ្នាំ 1432 ដោយព្រះបាទពញាយ៉ាតនិងលើកទី 2 ក្នុងឆ្នាំ 1866 ដោយព្រះបាទនរោត្តម ។ ព្រះបរមរាជវាំងមានប្រាសាទចំនួន 11 ដែលសង់នៅលើផ្ទៃដីទំហំ 465m × 402m ។ សំណង់ទាំងអស់នោះ សាងសង់តាមបែបស្ថាបត្យកម្មប្រពៃណីជាតិខ្មែរ ។ ប្រាសាទជាច្រើនមានដំបូលច្រើនជាន់ប្រក់ក្បឿងពណ៌មាស និងមានប្រាសាទកណ្ដាលសារពើសូត្រកំពូលស្រួចបាញ់ទៅលើ ដែលជាតំណាងនូវភាពរីកចម្រើនរុងរឿងរបស់ប្រទេស ។ ព្រះបរមរាជវាំង ជាសំណង់តំណាងឱ្យប្រទេសជាតិ ។ សំណង់ទាំងអស់គេលាបលំអដោយពណ៌លឿង តំណាងព្រះពុទ្ធសាសនានិងពណ៌សតំណាងព្រហ្មញ្ញសាសនា ។ សំណង់នេះមានកំពែងព័ទ្ធជុំវិញ និងមានទ្វារចំនួន 5 ។

## ១. ផ្ទះកឹង



ផ្ទះកឹងជាសំណង់ធ្វើពីឈើប្រណីត ។ ផ្ទះនេះគេឃើញមានតាំងពីសម័យអង្គរមក ។ កាលសម័យដើម អ្នកអាចសង់ផ្ទះកឹងបានមានតែបុគ្គលដែលមានបុណ្យសក្តិប៉ុណ្ណោះ ។ ផ្ទះបុរាណខ្មែររបៀបនេះ ជាសំណង់មានលក្ខណៈដែលសម្រាប់សម្គាល់ពីឋានៈខ្ពង់ខ្ពស់របស់ម្ចាស់ផ្ទះខ្លះនៅក្នុងសង្គមខ្មែរ ។

ផ្ទះកឹងមានដំបូលបិទចែកជាពីរថ្នាក់ ។ ថ្នាក់លើមានស្លាបដំបូល2 ។ ថ្នាក់ក្រោមមានស្លាបដំបូល6 ។ ដំបូលបិទនេះមានលំអដោយហោជាង ដែលមានលក្ខណៈខុសពីហោជាងផ្ទះដទៃ ។ រចនាបថនៃដំបូលផ្ទះនេះដូចគ្នានឹងរចនាបថនៃដំបូលប្រាសាទសម័យអង្គរ ។ ប្លង់ផ្ទះមានសសរកណ្តាល (សសរទ្រូង) ពីរជួរ និងមានស្មៀងតភ្ជាប់សងខាងដើម្បីសម្រាលទម្ងន់ ។

បច្ចុប្បន្នគេឃើញផ្ទះកឹងមាននៅសល់តិចតួចបំផុត ។ សំណង់នេះមាននៅវត្តគរក្នុងខេត្តបាត់ដំបង ។ ផ្ទះនោះមានបីខ្នង សង់លើផ្ទៃដីធំទូលាយដែលជាកម្មសិទ្ធិរបស់លោកហ្លួងស្នេហា ។ លោកហ្លួងជាមន្ត្រីជាន់ខ្ពស់ខេត្តបាត់ដំបង ។ ឯសំណង់មួយទៀតជាកម្មសិទ្ធិរបស់អតីតមេឃុំម្នាក់នៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។ ផ្ទះនោះមានទំហំតូចបន្តិច ។

## គ. ព្រះវិហារភ្នំដូនពេញ



*ព្រះវិហារភ្នំដូនពេញ*

ដូនពេញជាស្ត្រីចំណាស់ម្នាក់ ។ ថ្ងៃមួយ គាត់រើសបានព្រះពុទ្ធរូបបួនអង្គនិងបដិមាថ្ម មានលក្ខណៈជាព្រាហ្មណ៍ពីក្នុងដើមគគីរ ដែលអណ្តែតតាមទឹកទន្លេមេគង្គ មកទើរនឹងច្រាំងទន្លេ ក្បែរកន្លែងរបស់គាត់រស់នៅ ។

ដូនពេញ បាននាំអ្នកស្រុកជញ្ជូនដី ពូនជាកូនភ្នំមួយនៅខាងត្បូងសានផ្ទះរបស់គាត់ និងឱ្យគេយកឈើគគីរនោះ សង់ព្រះវិហារតូចល្មមនៅពីលើកំពូលភ្នំនោះ ។ ដូនពេញនិងអ្នកស្រុកបានហែនាំព្រះពុទ្ធរូបទាំងបួនអង្គទៅតម្កល់ក្នុងព្រះវិហារនាឆ្នាំ 1372 ។ តមកទៀតដូនពេញបានឱ្យគេសង់ខ្ទមមួយនៅទិសត្បូងសានព្រះវិហាររួចយកបដិមាថ្មទៅតម្កល់ទុកនៅទីនោះ ហើយបានសន្មតថា អ្នកតាព្រះចៅតរៀងមក (សព្វថ្ងៃគេហៅថា លោកតាព្រះចៅ) ។

លុះក្រោយមក ព្រះបាទពញាយ៉ាត បានឱ្យគេលើកដីពង្រីកភ្នំឱ្យបានធំទូលាយជាងមុន និងរៀបចំជួសជុលកែលំអព្រះវិហារធ្វើអំពីឥដ្ឋវិញ ហើយបានសម្ពោធនូវពុទ្ធសាសនៈ ជាផ្លូវការយ៉ាងអធិកអធមនៅឆ្នាំ 1434 ព្រមទាំងដាក់ឈ្មោះ ភ្នំនោះថា " ភ្នំដូនពេញ " និងមានព្រះវិហារធ្វើពីឥដ្ឋរហូតមក ហើយរាជធានីនៃព្រះរាជាណាចក្រកម្ពុជាយើងមានឈ្មោះថា ភ្នំពេញ ។

## ឃ. សារមន្ទីររោងដំរី



*សារមន្ទីររោងដំរី*

កាលដើមឡើយសារមន្ទីររោងដំរី មានឈ្មោះថា រោងដំរី ។ រោងដំរីជាសំណង់ធ្វើពីឈើនិងឥដ្ឋក្នុងឆ្នាំ1892 ស្ថិតនៅខាងត្បូងឈៀងខាងកើតព្រះវិហារព្រះកែវមរកតជាប់របងព្រះរាជវាំង ។ កាលនោះរោងដំរីជាទីសម្រាប់រក្សាគ្រឿងប្រដាប់បរិក្ខារលំអសត្វដំរី និងជាកន្លែងចិញ្ចឹមសត្វដំរី ដើម្បីត្រៀមទុកហែក្បួនក្នុងរាជពិធីបុណ្យផ្សេងៗរបស់ជាតិ ។ លុះក្រោយមកប្រទេសមានសង្គ្រាម រោងនេះត្រូវបានទំនេរចោលរហូតដល់ឆ្នាំ 1996 ទើបមានការជួសជុលកែលំអ ហើយរៀបចំទីនោះដាក់ជាសារមន្ទីរវិញ ដែលមានឈ្មោះ “សារមន្ទីររោងដំរី” ។ ក្នុងការជួសជុលកែលំអស្ថាបត្យករ នៅរក្សារចនាបថទាំងដំបូល ប្លង់អគារ ផ្ទាំពណ៌ជាលក្ខណៈប្រពៃណីខ្មែរទាំងអស់ ។ ក្នុងសារមន្ទីរនោះគេរៀបចំឱ្យមាន បន្ទប់ពិព័រណ៍រូបថត ដែលបង្ហាញពីលំនៅស្ថានខ្មែរ និងសម្លៀកបំពាក់ប្រពៃណីខ្មែរ បន្ទប់លក់វត្ថុអនុស្សាវរីយ៍ បន្ទប់តាំងគ្រឿងប្រាក់ បន្ទប់តាំងគ្រឿងហែក្បួនទ័ពដំរី បន្ទប់ព្រះឆាយាល័ក្ខណ៍ បន្ទប់តាំងគ្រឿងហែក្បួនព្រះរាជពិធីទ្វារទសមាស ផ្ទះខ្មែរ រូបសំណាកព្រះបាទជ័យវរ្ម័នទី7 និងរូបសំណាកដំរី ។

អាស្រ័យហេតុនេះសារមន្ទីររោងដំរីមានអាយុកាលរាប់រយឆ្នាំមកហើយ និងជាមណ្ឌលវប្បធម៌មួយដែលបង្ហាញពីប្រពៃណីទំនៀមទម្លាប់របស់ខ្មែរយើង ។

## ២. ផលប្រយោជន៍និងការថែរក្សាសំណង់អគារបុរាណ






*ក្រសួងយុត្តិធម៌* *ស្ថានីយរថភ្លើង*

សំណង់អគារបុរាណ បានផ្ដល់ព័ត៌មាននិងផលប្រយោជន៍ជាច្រើនដល់យើង ។ ផលប្រយោជន៍ទាំងនោះជាចំណេះដឹងខាងបច្ចេកទេស និងទំនៀមទម្លាប់ ។ តាមរយៈអគារបុរាណ យើងអាចយល់ដឹងពីប្រវត្តិនិងការវិវឌ្ឍនៃសំណង់របស់ខ្មែរតាមសម័យកាល និងពេលវេលាច្បាស់លាស់ ។ ទន្ទឹមនឹងនោះយើងអាចរៀនសូត្រពីភាពសម្បូរបែបខាងបច្ចេកទេសនិងសិល្បៈច្នៃប្រឌិតកែលំអលើសំណង់បានទៀតផង ។

សំណង់អគារបុរាណមិនត្រឹមតែផ្ដល់ការយល់ដឹងប៉ុណ្ណោះទេ គឺជាទីដែលអាចទាក់ទាញភ្ញៀវទេសចរមកពីគ្រប់តំបន់ និងគ្រប់ប្រទេសលើសកលលោក ។ ជាពិសេសធ្វើឱ្យយើងបានឃើញស្នាដៃនៃស្ថាបត្យករខ្មែរដ៏ពូកែ ដែលធ្វើឱ្យសំណង់មានអាយុកាលយូរអង្វែង និងប្រកបដោយសិល្បៈច្នៃប្រឌិតខ្ពស់ ។ ម្យ៉ាងទៀត នៅពេលបានឃើញសំណង់បុរាណទាំងនោះ យើងហាក់ដូចជាបានធ្វើដំណើរនិងរស់នៅក្នុងអតីតកាលដ៏រុងរឿងរបស់យើង ។

ដូចនេះ យើងទាំងអស់គ្នា ត្រូវរៀបចំជួសជុលកែលំអសំណង់បុរាណដែលមាននៅក្នុងតំបន់ដែលយើងរស់នៅឱ្យបានត្រឹមត្រូវដោយរក្សា ប្លង់ ពណ៌ និងរចនាបថ ។

## មេរៀនសង្ខេប

• ព្រះបរមរាជវាំងស្ថិតនៅចំណុចប្រសព្វនៃទន្លេបួនមុខ ។ សំណង់នេះកសាងឡើងចំនួនពីរលើក ។ លើកទី 1 ក្នុងឆ្នាំ1434 លើកទី 2 ក្នុងឆ្នាំ1866 ។ ក្នុងព្រះបរមរាជវាំងមានប្រាសាទចំនួន 11 មានកំពែងព័ទ្ធជុំវិញនិងមានទ្វារ 5 ។

• ផ្ទះកឹងជាសំណង់ធ្វើពីឈើប្រណីត ។ ផ្ទះនេះមានដំបូលពីរថ្នាក់ ។ ថ្នាក់លើមានស្លាបដំបូល 2 ។ ថ្នាក់ក្រោមមានស្លាបដំបូល 6 ។ ផ្ទះមានសសរកណ្ដាល 2 ជួរ និងមានស្មៀងតភ្ជាប់សងខាងដើម្បីសម្រាលទម្ងន់ ។ ផ្ទះនេះ មានតាំងពីសម័យអង្គរ ។ ផ្ទះបែបនោះ គេសង់សម្រាប់អ្នកមានឋានៈក្នុងរាជការប៉ុណ្ណោះ ។

• សំណង់ព្រះវិហារភ្នំដូនពេញដំបូងធ្វើពីឈើគគីរ ដែលផ្ដើមសាងសង់ដោយដូនពេញក្នុងឆ្នាំ 1372 ហើយត្រូវបានជួសជុលកែលំអជាវិហារធ្វើពីឥដ្ឋឡើងវិញនៅឆ្នាំ 1434 ដោយព្រះបាទពញាយ៉ាត ។

• សារមន្ទីររោងដំរីកសាងក្នុងឆ្នាំ 1892 សម្រាប់ចិញ្ចឹមដំរី និងដាក់គ្រឿងបំពាក់ដំរី ដើម្បីហែក្បួនក្នុងព្រះរាជពិធីបុណ្យផ្សេងៗ ។ សំណង់នេះ កែលំអឡើងវិញនៅឆ្នាំ1996 ដើម្បីដាក់តាំងបង្ហាញពីប្រពៃណីទំនៀមទម្លាប់របស់ខ្មែរ ។

## សំណួរ

1. តើព្រះបរមរាជវាំងកសាងឡើងប៉ុន្មានដង ? នៅឆ្នាំណាខ្លះ ?
2. តើផ្ទះកឹងមានលក្ខណៈពិសេសដូចម្ដេច ? មានដំបូលប៉ុន្មានថ្នាក់ ?
3. តើព្រះវិហារភ្នំដូនពេញ នរណាជាអ្នកសាងសង់មុនគេ ? សង់ដើម្បីអ្វី ?
4. តើសារមន្ទីររោងដំរីស្ថិតនៅឯណា ? មានអាយុកាលប៉ុន្មានឆ្នាំមកហើយ ?
5. ចូរបង្ហាញពីទីកន្លែង សំណង់អគារបុរាណណាមួយដែលអ្នកបានស្គាល់ ។
6. ហេតុអ្វីបានជាយើងត្រូវរក្សា សំណង់ អគារបុរាណ ?

មេរៀនទី

# 4 សម័យចេនឡា

អាណាចក្រចេនឡា ជាឈ្មោះរាជាណាចក្រខ្មែរ បន្ទាប់ពីអាណាចក្រភ្នំ ។ អាណាចក្រទាំងពីរនេះមានអំណាចលើគ្នាទៅវិញទៅមក ។

## 1. ប្រវត្តិចេនឡា



ចេនឡាជាអាណាចក្រមួយ មានទឹកដីធំទូលាយនិងមានក្សត្រជាអ្នកគ្រប់គ្រង ។ អ្នកស្រុកនៅសម័យចេនឡាមានជំនឿថាពួកគេកើតពីតាបសឈ្មោះកម្ពុនិងទេពអប្សរមេរា ។ តែតាមពិតបុព្វបុរសខ្មែរជាមនុស្សដើមដែលបង្កើតអាណាចក្រចេនឡា ។ អាណាចក្រនេះកាលនៅទន់ខ្សោយ ជារដ្ឋចំណុះរបស់អាណាចក្រភ្នំ ។ ក្នុងឱកាសអាណាចក្រភ្នំបែកបាក់គ្នា អាណាចក្រចេនឡាក៏ក្រោកឡើងប្រឆាំងនិងគ្រប់គ្រងលើទឹកដីដ៏មហាសាលបន្តមកដោយវាតទីពង្រីកទឹកដីទៅផ្នែកខាងលិច ។ រាជាណាចក្រចេនឡា មានទឹកដីធំទូលាយលាតសន្ធឹងខាងជើងទល់នឹងប្រទេសចិន ។ ខាងត្បូងទល់នឹងសមុទ្រខ្មែរនិងឧបទ្វីបម៉ាឡាយូ ។ ខាងកើតទល់នឹងប្រទេសចម្ប៉ា ។ ខាងលិចទល់នឹងប្រទេសភូមា ។

## 2. ព្រះរាជាល្បីៗ និងព្រឹត្តិការណ៍សំខាន់ៗនៅសម័យចេនឡា

ព្រះរាជាដែលសោយរាជ្យនៅសម័យចេនឡាជាក្សត្រដែលភាគច្រើនប្រកាន់នយោបាយពង្រីកទឹកដី ដូចជា :

- ព្រះបាទភវវរ្ម័នទី 1 ព្រះអង្គសោយរាជ្យពីឆ្នាំ 550 - 600 នៃគ.ស. ហើយជាក្សត្រដែលរំដោះចេនឡាឱ្យរួចពីរដ្ឋចំណុះនៃអាណាចក្រភ្នំ និងបានកសាងរាជធានីត្រង់វត្តភូ ។
- ព្រះបាទ មហិន្ទ្រវរ្ម័ន សោយរាជពីឆ្នាំ600 - 615 នៃគ.ស. ជាមេទ័ពដ៏ខ្លាំងពូកែបានបន្តនយោបាយពង្រីកទឹកដីគ្រប់គ្រងទន្លេមូន ។
- ព្រះបាទ ឦសានវរ្ម័នទី 1 សោយរាជ្យពីឆ្នាំ 615 - 635 នៃគ.ស. ជាក្សត្រខ្លាំងពូកែជាងគេក្នុងការប្រមូលរដ្ឋតូចៗជាចំណុះ ហើយបានបញ្ចប់សង្គ្រាមរវាងចេនឡានិងនគរភ្នំ ។ ព្រះអង្គបានផ្លាស់រាជធានីមកតាំងនៅសំបូរព្រៃគុហ៍ ក្រុងឦសានបុរៈ ។
- ព្រះបាទជ័យវរ្ម័នទី 1 សោយរាជ្យពីឆ្នាំ655 - 681 នៃគ.ស. ព្រះអង្គបានពង្រីកទឹកដីដល់ទំនាបទន្លេមេណាម ។

## ១. ចេនឡាបែកបាក់



*ប្រាសាទសំបូរព្រៃគុហ៍*



*ប្រាសាទវត្តភូ*

នគរចេនឡានិងនគរភ្នំបានរស់នៅជាមួយគ្នាដោយសុខសាន្ត ។ នៅឆ្នាំ681 នៃ គ. ស. ព្រះបាទជ័យវរ្ម័នទី 1 ទ្រង់សុគត ។ ព្រះអង្គគ្មានរាជបុត្រស្នង ព្រះមហេសីរបស់ព្រះអង្គព្រះនាមជ័យទេវី ក៏ឡើងសោយរាជ្យបន្ត ។ ពេលនោះភាពវឹកវរចលាចល ក៏កើតមានឡើង ដោយសារការដណ្ដើមរាជសម្បត្តិគ្នា ធ្វើឱ្យនគរបាក់បែកហើយបែងចែកទឹកដីជាពីរ ។

### ក. ចេនឡាដីគោក

មានរាជធានីស្ថិតនៅត្រង់ភូមិភាគចេនឡាពីដើម ។ ទីក្រុងឈ្មោះ ភវបុរៈ (វត្តភូ) ។ ទឹកដីនេះ លាតសន្ធឹងលើប្រទេសឡាវភាគកណ្ដាលនិងភាគខាងត្បូង ។ ចេនឡាដីគោកជារដ្ឋឯករាជ្យ ដាច់ពីចេនឡាទឹកលិច ។ ប្រទេសនេះមានទំនាក់ទំនងខាងផ្លូវទូតជាមួយប្រទេសចិន ។

## ខ. ចេនឡាទឹកលិច

មានទីតាំងស្ថិតនៅភូមិភាគខាងត្បូងជាប្រទេសហ្វូណនពីដើមគឺត្រង់ទំនាប ទន្លេមេគង្គ ចាប់ពីខោនចុះទៅទល់នឹងសមុទ្រ ។ ចេនឡាទឹកលិចមានទំនាស់ផ្ទៃក្នុងដណ្ដើមអំណាចគ្នា រហូតដល់បែងចែកទឹកដីជារដ្ឋតូចៗ ។ ការបែកបាក់គ្នានាសម័យនោះ ធ្វើឱ្យប្រទេសទន់ខ្សោយ ។ ក្នុងចំណោមរដ្ឋតូចៗទាំង 5 មានរដ្ឋមួយឈ្មោះសម្ភុៈបុរៈ ដែលជារាជធានីមានស្ដេចមួយអង្គព្រះនាម ពុស្កុរក្ស សោយរាជ្យនៅទីនោះ ។

## គ. ការវាតត្បាតពីប្រទេសជ្វា



ការបែកបាក់គ្នា ធ្វើឱ្យប្រទេសចេនឡាធ្លាក់ចុះខ្សោយ ហើយជាគ្រោះអាក្រក់មួយបន្ថែមទៀតដែលប្រទេសនេះទទួលរងនឹងការវាតត្បាតពីប្រទេសជ្វានៅចុងសតវត្សទី8 ។ ក្នុងសម័យនោះពួកជ្វាបានប្លន់យកប្រទេសចម្ប៉ា រួចចូលមកប្រទេសចេនឡាទឹកលិច ឡើងតាមទន្លេមេគង្គរហូតដល់សម្ភុៈបុរៈ ។ ពួកទ័ពជ្វាបានចូលលុកលុយដុតទីក្រុងព្រមទាំងធ្វើគតព្រះរាជាផង ។ តាំងពីពេលនោះមកប្រទេសចេនឡាទឹកលិចបានធ្លាក់ជាស្រុកចំណុះប្រទេសជ្វារហូតមកទល់នឹងសតវត្សទី9 ។

## 4. អរិយធម៌ចេនឡា



ថ្វីត្បិតតែមានការបាក់បែក តែការរីកចម្រើនខាងវប្បធម៌នានារមែងមានជាដរាប ។ ចេនឡាជាអាណាចក្រមួយ ដែលទទួលអរិយធម៌ពីឥណ្ឌា ។ ដូចនេះ គេច្រើនគោរពព្រហ្មញ្ញសាសនានិងពុទ្ធសាសនា ។ ដើម្បីចៀសវាងទំនាស់សាសនា គេបានបង្កើតទេវៈមួយព្រះអង្គព្រះនាម " ហរិហរៈ" (តំណាងព្រះវិស្ណុនៅភាគខាងឆ្វេង តំណាងព្រះសិវៈនៅភាគខាងស្តាំ) ។ នៅសម័យនោះមានទេវរូបនៅប្រាសាទអណ្ដែត និងកោះកៀងដែលសាងឡើងប្រកបដោយវិចិត្រសិល្បៈគួរឱ្យស្ងើចសរសើរព្រោះទេវរូបនោះមានរូបរាងដូចមនុស្សសុទ្ធសាធ ។

### ក. ជីវភាពប្រចាំថ្ងៃ

អ្នកស្រុកចេនឡាមានមាឌតូច សម្បុរស្រអែម ប៉ុន្តែស្ត្រីភាគច្រើនសម្បុរស ។ អ្នកស្រុកទាំងស្រី ទាំងប្រុសនិយម បួងសក់ និងពាក់រយ៉ា ។ ពួកគេមានគំនិតវាងវៃហើយរហ័សរហួន ។ ពួកគេចាត់ទុកដៃស្តាំជាដៃបរិសុទ្ធ ។ រៀងរាល់ព្រឹកគេដុសសម្អាតធ្មេញ និងសំបកឈើ រួចអានគម្ពីរ ឬសូត្រធម៌ ។ អាហាររបស់អ្នកស្រុកចេនឡាមានទឹកដោះគោ ស្ករ បាយនិងសាច់ ឬត្រីជាដើម ។ នៅពេលធ្វើដំណើរទៅណាមកណាពួកគេច្រើនពាក់អាវក្រោះនិងកាន់អាវុធ ។

## ខ. ការជ្រើសរើសគូស្រករ



ក្នុងការរើសគូស្រកររបស់អ្នកស្រុកនៅសម័យចេនឡា គឺខាងប្រុសត្រូវទៅដណ្ដឹងខាងស្រី ។ នៅពេលកូនកំលោះស្រឡាញ់ពេញចិត្តកូនក្រមុំណាមួយ គេត្រូវឱ្យចាស់ទុំ ម្ដាយឪពុកកាន់ចំណី ផ្លែឈើទៅលេងផ្ទះគ្រួសារខាងស្រី ។ បន្ទាប់មកឪពុកម្ដាយខាងស្រីជ្រើសរើសរកថ្ងៃល្អដើម្បីនាំកូនស្រីមកលេងផ្ទះកូនប្រុសវិញម្ដង ។ពេលរៀបការរួច ម្ដាយឪពុកទាំងសងខាងចែកទ្រព្យសម្បត្តិឱ្យកូនៗ ដើម្បីបង្កើតគ្រួសារថ្មី និងរស់នៅផ្ទះដោយឡែក ។

## គ. ពិធីបុណ្យសព

ពិធីបុណ្យសពរបស់អ្នកស្រុកចេនឡា មានការរៀបចំយ៉ាងហ្មត់ចត់ គឺនៅពេលធ្វើបុណ្យសព កូនៗត្រូវអត់បាយ 7 ថ្ងៃ និងកោរសក់ ហើយត្រូវស្រែកយំឱ្យខ្លាំងៗ ។ ការដង្ហែសពមានអ្នកចូលរួមជាគ្រួសារសព ញាតិមិត្ត បព្វជិត និងមានភ្លេងប្រគំកំដរផង ។ សពត្រូវបូជាដោយឈើក្រអូបនិងដាក់ធាតុក្នុងកោដ្ឋមាស ឬ ប្រាក់ ឬដីតាមឋានៈធនធាននៃគ្រួសារសព ។

## មេរៀនសង្ខេប

ចេនឡា ស្ថិតនៅភាគខាងត្បូងនៃប្រទេសឡាវសព្វថ្ងៃ ។ ព្រះរាជាដែលសោយរាជ្យក្នុងប្រទេសនេះដំបូងគេបង្អស់ ជាក្សត្រជាប់ព្រះញាតិវង្ស និងតាបសមួយព្រះអង្គ ព្រះនាមកម្ពុ ។ នៅពេលអាណាចក្រភ្នំមានការបែកបាក់គ្នា ចេនឡាបានគ្រប់គ្រងនិងយកនគរភ្នំជាចំណុះវិញ ។ ព្រះរាជាដែលល្បីៗក្នុងការដឹកនាំចេនឡាគឺព្រះបាទភវវរ្ម័នទី១ ព្រះបាទមហិន្ទ្រវរ្ម័ន ព្រះបាទឦសានវរ្ម័នទី១ និងព្រះបាទជ័យវរ្ម័នទី១ ។ ក្នុងរជ្ជកាលនោះចេនឡាមានសេចក្តីក្សេមក្សាន្តរុងរឿងមានទឹកដីធំទូលាយ ។

ក្រោយពីឆ្នាំ៦៨១ ព្រះបាទជ័យវរ្ម័នទី១សុគត ព្រះមហេសីព្រះអង្គព្រះនាមជ័យទេវីគ្រប់គ្រងរាជ្យ ។ តែដោយប្រទេសចេនឡាធំពេក ប្រទេសក៏បែកជាពីរដែលហៅថាចេនឡាដីគោក ចេនឡាទឹកលិច ។ ចេនឡាដីគោកស្ថិតនៅត្រង់ចេនឡាដើម ។ ឯចេនឡាទឹកលិចស្ថិតនៅត្រង់អាណាចក្រភ្នំពីដើម ។ បន្ទាប់មកពួកទ័ពជ្វាបានចូលមកត្រួតត្រាចេនឡាទឹកលិច ។

## សំណួរ

ក. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ :

១. អ្នកស្រុកចេនឡាគោរពសាសនា

☐ ក. ព្រហ្មញ្ញសាសនា

☐ ខ. ពុទ្ធសាសនា

☐ គ. ព្រហ្មញ្ញសាសនានិងពុទ្ធសាសនា ។

2. មនុស្សនៅសម័យចេនឡានិយមតែងខ្លួនដោយ

- [ ] ក. ប្អូងសក់និងពាក់រយ៉ា
- [ ] ខ. ក្រងសក់និងពាក់រយ៉ា
- [ ] គ. កាត់សក់ខ្លីនិងពាក់រយ៉ា ។

3. ពេលធ្វើបុណ្យសព កូនៗអ្នកស្រុកចេនឡាត្រូវ

- [ ] ក. អត់បាយ 7 ថ្ងៃ និងកោរសក់
- [ ] ខ. អត់បាយ7ថ្ងៃ កោរសក់និងស្រែកយំឱ្យខ្លាំងៗ
- [ ] គ. អត់បាយនិងកោរសក់ហើយស្រែកយំ ។

**ខ. ចូរឆ្លើយនឹងសំណួរខាងក្រោម ៖**

1. តើអាណាចក្រចេនឡាស្ថិតនៅឯណា ? មានព្រំប្រទល់ជាមួយប្រទេសណាខ្លះ?
2. តើព្រះរាជាសំខាន់ៗ ដែលមានស្នាដៃក្នុងការពង្រីកទឹកដីមានឈ្មោះអ្វីខ្លះ ?
3. ហេតុអ្វីបានជាចេនឡាបែកបាក់ ?
4. តើមនុស្សអាណាចក្រចេនឡាបានបង្កើតទេវៈអ្វី ? ដើម្បីអ្វី ?
5. តើព្រះហរិហរៈតំណាងអ្វីខ្លះ ?

**គ. ចូរគូរចម្លងព្រួញកាលខាងក្រោមដាក់ក្នុងសៀវភៅកិច្ចការរបស់អ្នក រួចបង្ហាញពីឈ្មោះព្រះរាជានិងស្នាព្រះហស្តរបស់ព្រះអង្គឱ្យបានច្បាស់លាស់ ។**



មេរៀនទី

# 5 សម័យអង្គរ

សម័យអង្គរ ជាសម័យរុងរឿងបំផុតនៃសាវតារខ្មែរ ។ សម័យនោះមានទឹកដីធំទូលាយមានរបៀបមិអរិយធម៌ទំនើបជឿនលឿន និងអភិវឌ្ឍន៍គ្រប់វិស័យ ។



ប្រាសាទអង្គរវត្តមើលពីលើ

## 1. ទីក្រុងអង្គរ

ទីក្រុងអង្គរជារាជធានីចាស់របស់ខ្មែរយើង ។ ទីក្រុងនេះពីដើមមានឈ្មោះយសោធបុរៈ តាំងនៅតំបន់អង្គរដែលជាទីតាំងកណ្ដាលនៃអាណាចក្រអង្គរ ។ ទីក្រុងអង្គរកសាងនៅដើមសតវត្សរ៍ទី ៩ នៃគ.ស. ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី2 ក្នុងខេត្តសៀមរាបបច្ចុប្បន្ន ។ ក្រុងអង្គរមានប្រាសាទតូចធំជាច្រើន ។ ប្រាសាទនីមួយៗមានក្បាច់រចនាដ៏ប្រណីតគួរឱ្យស្ញប់ស្ញែង ពិសេសប្រាសាទបាយ័ន និងប្រាសាទអង្គរវត្ត ។ ក្រៅពីប្រាសាទ ក្រុងអង្គរមានបារាយណ៍ធំៗសម្រាប់យកទឹកប្រើប្រាស់ និងធ្វើកសិកម្ម ។

## ២. ព្រះរាជាល្បីៗនិងព្រឹត្តិការណ៍សំខាន់ៗ

### ក. ព្រះបាទជ័យវរ្ម័នទី2 (802- 850 នៃគ. ស.)



ព្រះបាទជ័យវរ្ម័នទី2 ជាព្រះញាតិវង្សព្រះមហាក្សត្រចេនឡាទឹកលិច ដែលត្រូវពួកជ្វាចាប់នាំយកទៅក្នុងពេលដែលពួកជ្វាចូលលុកលុយរាតត្បាតនគរចេនឡាទឹកលិច ។ ក្នុងគ. ស. 800 ព្រះបាទជ័យវរ្ម័នទី2 ទ្រង់បានលបលួចរត់ចេញពីប្រទេសជ្វាមកកាន់ចេនឡាទឹកលិចវិញ ។ នៅគ. ស. 802 ព្រះអង្គបានរៀបចំកម្លាំងកម្ចាត់សត្រូវឈ្លានពានអស់ពីទឹកដីចេនឡាទឹកលិច ហើយប្រកាសឯករាជ្យលែងជាចំណុះនគរជ្វាទៀត ។ ដោយមានព្រះរាជបំណងបង្រួបបង្រួមចេនឡាទឹកលិចនិងចេនឡាដីគោក ព្រះអង្គបានយាងទៅគង់នៅតំបន់ខាងជើងបឹងទន្លេសាបវិញគឺតំបន់អង្គរសព្វថ្ងៃនេះ ។ ដើម្បីឱ្យព្រះអង្គទៅជាក្សត្រខ្លាំងពូកែ ព្រះអង្គទ្រង់ចាត់ឱ្យគេរៀបចំពិធីមួយតាមបែបព្រហ្មញ្ញសាសនានៅលើភ្នំគូលែន គឺហៅថាពិធីទេវរាជ ដែលចាត់ទុកព្រះអង្គដូចជាព្រះទេវៈដែរ ។ ចាប់ពីពេលនោះមកនគរមានឈ្មោះល្បីរន្ទឺ ។ បន្ទាប់មកព្រះអង្គចាត់ឱ្យកសាងព្រះរាជវាំង និងប្រាសាទមួយចំនួនសម្រាប់ធ្វើពិធីគោរពព្រះទេវៈហើយការបង្រួបបង្រួមចេនឡាទាំងពីរមានការរីកចម្រើនជាលំដាប់ ទើបគេហៅព្រះអង្គថា ជាព្រះរាជាផ្ដើមកសាងសម័យអង្គរមុនគេបង្អស់ ។ ប្រទេសខ្មែរក្លាយជា" អាណាចក្រកម្ពុជា" ចាប់ពីពេលនោះមក ។

## ខ. ព្រះបាទសូរ្យវរ្ម័នទី 2 (1113-1150 នៃគ. ស.)



ប្រាសាទភ្នំជីសូរ



ព្រះវិហារវត្តភូ

ព្រះបាទសូរ្យវរ្ម័នទី 2 បានធ្វើឱ្យប្រទេសមានសុខសន្តិភាពនិងឯកភាពជាតិរួមតែមួយវិញ ។ ព្រះអង្គជាស្តេចសឹកយ៉ាងឆ្នើម ។

• **ផ្នែកការពារប្រទេស** : ទ្រង់បានធ្វើសង្គ្រាមកម្ចាត់សត្រូវឈ្លានពានពីចាម យួន សៀម និងមន ។ នៅក្នុងរជ្ជកាលព្រះអង្គមានចម្បាំងធំៗពីរលើក លើកទី 1 នាឆ្នាំ 1131 នៃគ. ស. បង្ក្រាបចាម យួនតុងកឹងឈ្លានពានខ្មែរ និងលើកទី 2 នាឆ្នាំ 1145 វាយលុកប្រទេសចម្ប៉ាហើយយកនគរនោះជាចំណុះ ។ នៅចុងរជ្ជកាលព្រះអង្គ ប្រទេសមានព្រំប្រទល់ ខាងជើងទល់ប្រទេសចិន ខាងត្បូងទល់សមុទ្រ ខាងកើតទល់នឹងចម្ប៉ាខាងលិចទល់នឹងប្រទេសភូមា ។ ព្រះអង្គទ្រង់កាន់លទ្ធិវិស្ណុ ។

• **ផ្នែកសាងសង់** : ព្រះអង្គបានសាងប្រាសាទមួយដ៏ល្អឆើតដែលល្បីល្បាញពេញពិភពលោក គឺប្រាសាទអង្គរវត្តសម្រាប់ជាទីគោរពបូជាដល់ព្រះវិស្ណុនិងសម្រាប់បញ្ចុះព្រះអដ្ឋិធាតុព្រះអង្គផង ។ ក្រៅពីនេះព្រះអង្គបានសាងប្រាសាទនៅភ្នំជីសូរ ភ្នំសណ្ដក ព្រះវិហារវត្តភូ (សព្វថ្ងៃនៅក្នុងទឹកដីឡាវ) បឹងមាលា ប្រាសាទព្រះខ័ន (កំពង់ស្វាយ) ។

ព្រះបាទសូរ្យវរ្ម័នទី 2 ឡើងសោយរាជ្យគ្រប់គ្រងលើរាជាណាចក្រកម្ពុជាទាំងមូល ដោយទ្រង់គង់នៅក្នុងក្រុងអង្គរ ។

## គ. ព្រះបាទជ័យវរ្ម័នទី7 (1181-1218 នៃគ.ស.)



*ព្រះបាទជ័យវរ្ម័នទី៧*

នៅពាក់កណ្ដាលសតវត្សរ៍ទី12 នគរខ្មែរចុះខ្សោយដោយការជណ្ដើមអំណាចគ្នា ។ ពួកចាមបានលើកទ័ពចូលវាយលុក ហើយគ្រប់គ្រងអង្គរនៅ គ.ស. 1177 ។ ព្រះបាទជ័យវរ្ម័នទី៧ ទ្រង់ឈ្វេងយល់ឃើញថា រាជាណាចក្រកម្ពុជាត្រូវធ្លាក់ក្នុងកណ្ដាប់ដៃចាម ដូចនេះទ្រង់បានប្រមូលទ័ពបណ្ដេញពួកចាមឈ្លានពានអស់ពីព្រះរាជាណាចក្រកម្ពុជា ។ ការប្រយុទ្ធកម្ចាត់សត្រូវឈ្លានពាននេះ បានប្រព្រឹត្តទៅអស់រយៈពេល4ឆ្នាំទើបបានទទួលជោគជ័យ ។ នៅ គ.ស. 1181 ទ្រង់ចាត់ឱ្យរៀបចំពិធីអភិសេកព្រះអង្គឡើងសោយរាជ្យជាព្រះមហាក្សត្រនៅក្រុងអង្គរ ។

បន្ទាប់មកព្រះបាទជ័យវរ្ម័នទី៧ បានបញ្ជាឱ្យទ័ពវាយលុកជណ្ដើមយកប្រទេសចម្ប៉ាដាក់ជាខេត្តមួយរបស់ព្រះរាជាណាចក្រកម្ពុជា ។ ក្នុងរជ្ជកាលព្រះអង្គទឹកដីខ្មែរមានទំហំធំធេងណាស់ គឺរាប់ទាំងប្រទេសចម្ប៉ា លាវ សៀម មាឡាយូ មួយភាគទៀតផង ។

• **ផ្នែកសង្គមកិច្ចនិងវប្បធម៌ :** ព្រះបាទជ័យវរ្ម័នទី 7 ទ្រង់គោរពនិងមានជំនឿលើព្រះពុទ្ធសាសនា ។ ព្រះអង្គទ្រង់ចាត់ឱ្យកសាងវត្តអារាមជាច្រើនដើម្បីជាទីកន្លែងសម្រាប់គោរពព្រះពុទ្ធសាសនាផង និងជាទីកន្លែងសម្រាប់ឱ្យសិស្សានុសិស្សបានចូលទៅរៀនសូត្រផង ។ ព្រះអង្គទ្រង់យកព្រះទ័យទុកដាក់ពីទុក្ខវេទនារបស់ប្រជារាស្ត្ររបស់ព្រះអង្គណាស់ ។ ព្រះអង្គទ្រង់ចាត់ឱ្យសាងមន្ទីរពេទ្យជាច្រើននៅគ្រប់ទីកន្លែងដើម្បីព្យាបាលរោគជូនប្រជារាស្ត្រ ។ ក្រៅពីនេះ ព្រះអង្គចាត់ឱ្យធ្វើផ្លូវគមនាគមន៍សម្រាប់ទាក់ទងពីតំបន់មួយទៅតំបន់មួយទៀតនិងមានសាលាសំណាក់សម្រាប់អ្នកធ្វើដំណើរផ្លូវឆ្ងាយទៀតផង ។



• **ផ្នែកសាងសង់ :** ក្នុងពេលដែលពួកចាមលុកលុយរាជាណាចក្រកម្ពុជានោះទីក្រុងអង្គរ(យសោធបុរៈ2) ត្រូវខូចខ្ទេចខ្ទាំជាច្រើនកន្លែង ។ ម្ល៉ោះហើយ ព្រះបាទជ័យវរ្ម័នទី 7 ទ្រង់ចាត់ឱ្យរៀបចំជួសជុលក្រុងអង្គរឡើងវិញ ។ ក្នុងការរៀបចំនិងជួសជុលនេះ ព្រះអង្គទ្រង់បញ្ជាឱ្យជីកគូទឹកនិងធ្វើកំពែងអំពីថ្មព័ទ្ធជុំវិញប្រវែងប្រហាណ 12 គីឡូម៉ែត្រ ដើម្បីកុំឱ្យខ្មាំងសត្រូវងាយស្រួលវាយលុកក្រុងអង្គរ ។ បន្ទាប់មកទៀត

ព្រះអង្គទ្រង់ចាត់ឱ្យជួសជុលប្រាសាទដែលខូចខាតបាក់បែកដោយសារសង្គ្រាម ព្រមទាំងចាត់ឱ្យកសាងប្រាសាទថ្មីមួយទៀតនៅក្នុងបរិវេណអង្គរធំនេះ គឺប្រាសាទបាយ័ន ។

ក្រៅពីនេះ ព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់បានចាត់ឱ្យកសាងប្រាសាទជាច្រើនទៀត នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដូចជាប្រាសាទព្រះខ័ន (ក្នុងតំបន់អង្គរ) ប្រាសាទតាព្រហ្ម (តាកែវ) ប្រាសាទវត្តនគរ (ខេត្តកំពង់ចាម) និងប្រាសាទបន្ទាយឆ្មារ ជាដើម ។



### ឃ. ចម្បាំងនឹងចាម



ជនជាតិចាមមានប្រទេសឈ្មោះចម្ប៉ាស្ថិតនៅភាគខាងកើតនៃជ្រោយឥណ្ឌូចិន ជាប់នឹងឆ្នេរសមុទ្រ ។ លុះជនជាតិនេះមានបណ្ដាជនកាន់តែកុះករឡើង កិច្ចចាំបាច់ដើម្បីរស់ បានបង្ខំចាមឱ្យច្បាំងយកកម្ពុជាភាគខាងត្បូង ។ ចម្បាំងនឹងចាមមានតាំងពីរជ្ជកាលព្រះបាទជ័យវរ្ម័នទី 2 ។ ប៉ុន្តែចម្បាំងធំ គឺច្បាំងក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី 2 ដែលអូសបន្លាយរហូតដល់រជ្ជកាលព្រះបាទជ័យវរ្ម័នទី 7 ។

នៅឆ្នាំ 1123-1145 ព្រះបាទសូរ្យវរ្ម័នទី2 បានដេញវាយចាមដែលបានមកឈ្លានពានឱ្យខ្ចាត់ខ្ចាយអស់ ។ ព្រះអង្គបង្ខំឱ្យចាមចូលធ្វើសហពលកម្មជាមួយខ្មែរផងនិងទ្រង់បានដាក់ព្រះរាជាខ្មែរមួយអង្គឱ្យគ្រប់គ្រងចម្ប៉ា។ ការគ្រប់គ្រងនោះបានតែ 5ឆ្នាំប៉ុណ្ណោះ ចាមដណ្ដើមយកការគ្រប់គ្រងវិញ ។

នៅឆ្នាំ 1177 ចាមលើកទ័ពមកតាមទន្លេមេគង្គ ចូលដល់បឹងទន្លេសាបវាយយកអង្គរនិងសម្លាប់ស្ដេចខ្មែរ ។ លុះ 5ឆ្នាំក្រោយមក ព្រះបាទជ័យវរ្ម័នទី 7 បានលើកទ័ពដេញកម្ចាត់ចាមចេញអស់ពីប្រទេសវិញ ។

នៅឆ្នាំ 1190 ចាមលើកទ័ពមកឈ្លានពានម្ដងទៀត ។ ពេលនោះព្រះបាទជ័យវរ្ម័នទី 7 បានវាយបកវិញ ។ ព្រះអង្គបានលើកទ័ពចូលដល់ក្រុងវិជ័យ និងគ្រប់គ្រងប្រទេសចម្ប៉ាបាន ។

## ៣. អរិយធម៌ខ្មែរសម័យអង្គរ

នៅសម័យអង្គរ ខ្មែរមានឈ្មោះ ជាមហាអំណាចមួយនៅអាស៊ីអាគ្នេយ៍ ។ ភាពរុងរឿងនេះ គឺខ្មែរមានផ្ទៃដីធំទូលាយលាតសន្ធឹងជិតអស់ផ្ទៃដីឥណ្ឌូចិនទាំងមូល និងមានសិលាចារឹកច្រើនរាប់ពាន់ ប្រកបដោយក្បាច់រចនាល្អឥតខ្ចោះ ។ ផ្ទាំងសិលាចារឹកមានភាសាសំស្ក្រឹត និងខ្មែរបុរាណ នៅលាយចម្រុះជាមួយគ្នា ។ បដិមាគ្រប់ប្រភេទ និងបុរាណវត្ថុជាច្រើន ។ ជាពិសេសមានបារាយណ៍ទំនប់ទឹក ផ្លូវថ្នល់ ស្ពាន ។ល។

## ៤. សាសនា



ព្រះពុទ្ធរូបប្រក់នាគ



ព្រះពុទ្ធរូប



រូបអ្នកតា



ព្រះគោ

នៅសម័យអង្គរ ការប្រតិបត្តិសាសនាតែងផ្លាស់ប្ដូរទៅតាមជំនឿរបស់ព្រះមហាក្សត្រ ។ ព្រះរាជាខ្លះកាន់សាសនាព្រះឥសូរ ព្រះរាជាខ្លះកាន់សាសនាព្រះវិស្ណុ ព្រះរាជាខ្លះកាន់សាសនាព្រះព្រហ្ម និងព្រះរាជាខ្លះទៀតកាន់ព្រះពុទ្ធសាសនា ។ សាសនាទាំងនេះសម្រាប់តែព្រះរាជា និងពួកអភិជនប៉ុណ្ណោះ ។ ឯប្រជារាស្ត្រសាមញ្ញគេគោរព និងជឿលើអារក្សអ្នកតា ។

### មេរៀនសង្ខេប

សម័យអង្គរមានទីក្រុងឈ្មោះ យសោធបុរៈ ស្ថិតនៅតំបន់អង្គរ ។ ទីក្រុងនេះសាងនាដើមសតវត្សរ៍ទី១០ នៃគ. ស. ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី 2 ។

ព្រះរាជាទាំងអស់ជាអ្នកខ្លាំងពូកែ បានពង្រីកទឹកដីយ៉ាងធំទូលាយនិងកសាងប្រទេសឱ្យសម្បូររុងរឿងមានប្រាសាទជាច្រើនជាស្នាដៃរបស់ព្រះបាទជ័យវរ្ម័នទី2 សូរ្យវរ្ម័នទី 2 និងជ័យវរ្ម័នទី 7 ។

នៅសម័យនោះ ខ្មែរជាមហាអំណាចនៅអាស៊ីអាគ្នេយ៍ ។ ទឹកដីលាតសន្ធឹងស្ទើរតែពេញឧបទ្វីបឥណ្ឌូចិនទាំងមូល ។ មានសិលាចារឹកនិងភាសាសំស្ក្រឹត ជាមួយភាសាខ្មែរបុរាណលាយគ្នាយ៉ាងសម្បូរបែប ។ ព្រះរាជា និងអភិជនកាន់សាសនាព្រហ្មញ្ញ និងព្រះពុទ្ធ ។ ប្រជារាស្ត្រ គោរព និងជឿលើអារក្ស អ្នកតា ។

## សំណួរ

ក. **ចូរឆ្លើយនឹងសំណួរខាងក្រោម :**

1. តើទីក្រុងយសោធបុរៈសាងសង់នៅសតវត្សរ៍ទីប៉ុន្មាន ? នៅឯណា ?
2. តើព្រះបាទជ័យវរ្ម័នទី2 សោយរាជ្យនៅឆ្នាំណា ? ព្រះអង្គមានស្នាព្រះហស្ថអ្វីខ្លះ ?
3. តើព្រះបាទសូរ្យវរ្ម័នទី2 បានសាងសង់ប្រាសាទអ្វីខ្លះ ?
4. តើព្រះបាទជ័យវរ្ម័នទី7 គោរពសាសនាអ្វី ? ព្រះអង្គបានកសាងអ្វីខ្លះ ?
5. តើសម័យអង្គរ ខ្មែរច្បាំងជាមួយប្រទេសណាខ្លាំងជាងគេ ? ហេតុអ្វី ?

ខ. **ចូរគូសព្រួញកាលបង្ហាញពីព្រះនាមរបស់ព្រះរាជា និងព្រឹត្តិការណ៍សំខាន់ៗនៅសម័យអង្គរតាមកាលបរិច្ឆេទ :** 802 - 850 **នៃគ. ស.** 1113 -1150 **នៃគ. ស.** 1181-1218 **នៃគ. ស.** ។

**យើងបម្រើសេវាកម្ម ៖**

- អភិវឌ្ឍសៀវភៅនិងសម្ភារឧបទេស
- បោះពុម្ព
- ចែកផ្សាយដល់សាលារៀន

**WE SERVE:**

- book and teaching-aid development
- printing
- distribution to schools

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ (គ.ប.ផ)

PUBLISHING AND DISTRIBUTION HOUSE (PDH)

# បណ្ណាគារ គ.ប.ផ

# PDH BOOKSHOP

**មានលក់ ៖**

សៀវភៅសិក្សាគោលសម្រាប់សិស្ស សម្រាប់គ្រូ សៀវភៅលំហាត់ សៀវភៅអំណានបន្ថែម និង សម្ភារឧបទេស ព្រមទាំងសម្ភារការិយាល័យគ្រប់មុខ ។

**SELLING:**

textbooks , teacher's manuals , workbooks , supplementary readers , teaching-aids and stationary !